បណ្ឌិត ហ្សង់-មីសែល ហ្វីលីពី

# ការស្រាវជ្រាវបឋមអំពីភាសា ជនជាតិភាគតិចនៅកម្ពុជា



បោះពុម្ពផ្សាយដោយមានការគាំទ្រពីអង្គការយូណេស្កូ

UNESCO
United Nations
Educational, Scientific and
Cultural Organization

បណ្ឌិត ហ្សង់-មីសែល ហ្វីលីពី

# ការស្រាវជ្រាវបឋមអំពីភាសា
# ជនជាតិភាគតិចនៅកម្ពុជា

ការបោះពុម្ពផ្សាយដោយមានការគាំទ្រពីអង្គការយូណេស្កូ

កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ : ៣០ កក្កដា ២០០៩

រក្សាសិទ្ធិ : UNESCO និង IDSSC

បោះពុម្ពផ្សាយដោយអង្គការយូណេស្កូ phnompenh@unesco.org

និង IDSSC xunwu@idsse.org

បោះពុម្ព : រោងពុម្ពហ្វូណន funan7@yahoo.fr

រូបថតនៅលើគម្រប : IDSSC

# ការស្រាវជ្រាវបឋម

# អំពីភាសា

# ជនជាតិភាគតិចនៅកម្ពុជា

# អារម្ភកថា

នៅថ្ងៃទី ២០ ខែតុលា ឆ្នាំ២០០៥ សន្និសីទពេញអង្គនៃអង្គការយូណេស្កូ បានគាំទ្រ ដល់អនុសញ្ញាស្តីពីការការពារ និងការលើកស្ទួយវិវិធភាពនៃសំនួនវោហារវប្បធម៌។ អត្ថបទនេះបំពេញបន្ថែមនូវ វិធានច្បាប់មួយដែលបង្កើតឡើងដោយអង្គការយូណេស្កូ ដើម្បីអភិរក្សបេតិកភណ្ឌវប្បធម៌រូបីនិងអរូបីរបស់មនុស្សជាតិ។

ឆន្ទៈនៃការការពារ និងការលើកស្ទួយដែលស្តែងឡើងតាមរយៈអនុសញ្ញានេះ បានផ្តោតទៅលើការសង្កេតឃើញមួយ ចំនួនដែលមិនត្រឹមតែភ្ជាប់វិវិធភាពវប្បធម៌ទៅនឹង «ការសម្រេចដ៏ពេញលេញ នៃសិទ្ធិមនុស្សនិងសេរីភាពជាគ្រឹះ» ប៉ុណ្ណោះទេ ប៉ុន្តែក៏បានបញ្ជាក់ពី «វិភាគទានដ៏វិជ្ជមានក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព» ផងដែរ។ វិវិធភាពវប្បធម៌ដែលត្រូវបានកំណត់ និយមន័យថា «ជាពហុភាពនៃទម្រង់ដែលតាមរយៈនោះ វប្បធម៌នៃក្រុមនិងសង្គមនានាបានបង្កើតជាសំនួន វោហារឡើង» ឆ្លុះបញ្ចាំងនូវភាពសម្បូរបែប នៃពហុអត្តសញ្ញាណកម្មរបស់សហគមន៍ ពាសពេញពិភពលោកនិងនៅក្នុងប្រទេសនានា។ លើកតម្លៃដោយមិនធ្វើឱ្យខុសពីភាពដើម លើកស្ទួយដោយមិនធ្វើឱ្យមានទម្រង់តែមួយ អត្តសញ្ញាណពិសេស នៃសហគមន៍នីមួយៗ អាចក្លាយទៅជាប្រភពនៃការអភិវឌ្ឍន៍ក្នុងវិវិធភាពរបស់ខ្លួន។ អ្វីដែលរដ្ឋហត្ថលេខីនៃអនុសញ្ញា ចង់បន្តធ្វើអោយបាន គឺភាពល្អឥតខ្ចោះ ស្របទៅតាម អាណត្តិដែលមានចែងនៅក្នុងលិខិត ជាបតិដ្ឋាប័នរបស់អង្គការយូណេស្កូ ពោលគឺ ការពារ «វិវិធភាពវប្បធម៌ដ៏សម្បូរបែប»។

ដើម្បីឈានដល់ភាពល្អឥតខ្ចោះនេះ ជាបឋមត្រូវមានភាពប្រាកដប្រជាថា នៅមាន វិវិធភាពវប្បធម៌ពិភពលោក ដោយហេតុថា ទោះបីជានៅមានវិវិធភាពនេះ នាពេលសព្វថ្ងៃនេះក៏ពិតមែន ប៉ុន្តែវិវិធភាពវប្បធម៌នៅតែទទួលរងការគំរាមកំហែង នៅឡើយ ។ សកលភាវូបនីយកម្មដែលមិនអាចចៀសបាន ហើយដែលសម័យកាល យើងជាសក្ខីភាព នោះបង្កើតបានជា កត្តាដ៏អស្ចារ្យមួយនៃការប្រាស្រ័យទាក់ទង និងការផ្លោះប្តូរគ្នា ប៉ុន្តែក៏អាចជាចលករដ៏គួរឱ្យគ្រោះថ្នាក់មួយនៃការធ្វើឱ្យទៅជា ទម្រង់តែមួយឬធ្វើ អោយបាត់តុល្យភាព និងផ្តល់ប្រយោជន៍អោយតែវប្បធម៌មួយ ចំនួនប៉ុណ្ណោះ ។

លក្ខណៈវិនិច្ឆ័យវិវិធភាព នៃភាសាដែលត្រូវបានចាត់ទុកដោយអនុសញ្ញាណថា ជា «ធាតុសំខាន់នៃវិវិធភាពវប្បធម៌» នោះ គឺជាគុណធម៌មួយ : ទោះណាជាគេឃើញ មានភាសាចំនួន ៦ ០០០ ដែលគេនិយាយនៅក្នុងលោកនៅឡើយក៏ដោយ ក៏ពាក់កណ្តាល នៃភាសាទាំងនោះ ត្រូវបានចាត់ទុកថាស្ថិតនៅក្នុង «គ្រោះថ្នាក់» ហើយភាសាមួយ ក្នុងចំណោមភាសាទាំង នោះបានបាត់បង់ទៅរៀងរាល់សប្តាហ៍ ។

គឺក្នុងបរិបទនេះហើយ ដែលអង្គការយូណេស្កូបានបង្កើត និងផ្តល់ដល់ប្រទេស ជាសមាជិករបស់ខ្លួននូវ «មូលនិធិ សម្រាប់ការការពារ និងការលើកស្ទួយវិវិធភាព វប្បធម៌» ក្នុងគោលបំណងលើកទឹកចិត្តដល់ចំណងរវាង វិវិធភាពវប្បធម៌ និងការ អភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ការគាំទ្រដែលបានផ្តល់ជូនវណ្ណកម្មនេះត្រូវបានផ្តល់ ជាថវិកាដោយមូលនិធិនេះ ។

ព្រះរាជាណាចក្រកម្ពុជាដែលបានផ្តល់សច្ចាប័នកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧

លើអនុសញ្ញាស្តីពីការការពារនិង ការលើកស្ទួយវិវិធភាពនៃសំនួនវោហារវប្បធម៌ មានភាពសម្បូរបែបផ្នែកវប្បធម៌និងភាសាដ៏ពិសេស។ ជាតិពន្ធុជាងម្ភៃត្រូវ បានរកឃើញនៅក្នុងប្រទេស ហើយបើទោះណាជាជាតិពន្ធុទាំងនោះមានតិចតួចក្នុងកម្រិតថ្នាក់ជាតិយ៉ាងណាក៏ដោយ ក៏ជាតិពន្ធុទាំងនោះបានបង្ហាញពីវិសេសភាពជាភាគច្រើននៅក្នុងខេត្តមួយចំនួនតាមជាយដែននៃព្រះរាជាណាចក្រដែរ។ នៅពេល ដែលប្រទេសនេះបានងើបចេញបន្តិចម្តងៗពីវិបត្តិដែលគេបានស្គាល់ ដើម្បីដើរឆ្ពោះទៅកាន់មាគ៌ានៃការអភិវឌ្ឍន៍នោះ វាចាំបាច់ណាស់នៅក្នុងការយកចិត្តទុកដាក់ ចំពោះវិវិធភាពវប្បធម៌ដ៏សម្បូរបែបរបស់ប្រទេសនេះ និងលើកទឹកចិត្តដល់ការសិក្សានិងការលើកតម្លៃនៃវិវិធភាពវប្បធម៌នេះ។

វណ្ណកម្មនេះដែលចងក្រងឡើងដោយ លោក ហ្សង់-មីសែល ហ្វីលីពី ដោយផ្តើមចេញពីការងារចុះផ្ទាល់ដល់ទីកន្លែង ដ៏សន្ធឹកសន្ធាប់ គឺជាការរួមវិភាគទានទីមួយដល់ការបង្កើតបញ្ជីសារពើភណ្ឌនៃភាសាជនជាតិភាគតិចនៃកម្ពុជា ហើយដែលជាឧបករណ៍ចាំបាច់សម្រាប់ការអភិរក្សភាសាទាំងនោះ។

សូមឱ្យគំនិតផ្តួចផ្តើមនេះត្រូវបានបន្តដោយការងារជាច្រើនទៀត ដើម្បីឱ្យវិវិធភាពវប្បធម៌ដ៏សម្បូរ ដែលយើងបានប្រកាន់យកដើម្បីការពារនោះអាចមានតួនាទីដ៏ពេញលេញនៅក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព។

**តេរូអូ ជីនណៃ**

តំណាងអង្គការយូណេស្កូប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីផ្តើម

អត្ថបទនេះ គ្មានមហិច្ឆតាក្នុងការផ្ដល់ការពិពណ៌នាពេញលេញអំពីស្ថានភាពភាសានៅកម្ពុជា ដែលត្រូវបានសិក្សា ក្រោមមុំនៃភាសានិយាយរបស់ជាតិពន្ធុនៅប្រទេសនេះទេ។ ការសិក្សាលំអិតដែលតាម ទ្រឹស្ដីអាចធ្វើបាននិងអាចជាក់ស្ដែងអនុវត្តបានដែរនោះ នឹងតម្រូវឱ្យមានធនធានថវិកានិងធនធានមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់និងចារិកនៅក្នុងកាលវេលាមួយដ៏ យូរជាងនេះទៅទៀត។

ប៉ុន្តែ ទោះបីជាយើងប្រើឃ្លាអនាគតកាលដែលចង់មានន័យថា ការពិពណ៌នាបឋមនេះផ្ទុកនូវគំនិតដែលត្រូវធ្វើការបន្តក៏ដោយ ក៏វាជាការពិតណាស់ថា ការងារនេះថ្វីត្បិតតែវាជាជំហានដំបូងមែនពិត ប៉ុន្តែ វាមានគោលដៅច្បាស់លាស់ដូចតទៅ :

- ធ្វើកិច្ចប្រតិបត្តិការទីមួយដោយចុះផ្ទាល់ទៅដល់ទីកន្លែងដែលសព្វថ្ងៃគេមិនសូវស្គាល់ ប៉ុន្តែ ពោរពេញទៅដោយទិន្នន័យផ្ទុយគ្នា។

- ផ្ទៀងផ្ទាត់ខ្លឹមសារ នៃការពិពណ៌នាពីមុន ទៅនឹងទិន្នន័យដែលស្រង់បាននៅក្នុងការអង្កេតដល់ទីកន្លែង។

- ញែកនិងបង្កើតថេរធាតុពិសេស នៃការពិពណ៌នាដែលអាចឱ្យយល់ពីស្ថានភាពនៃភាសាជនជាតិដើមភាគតិចនៅកម្ពុជា។

- បង្កើតផែនទីសាស្ត្រដំបូងស្ដីពីជាតិពន្ធុនៅកម្ពុជា។

ដូច្នេះ អត្ថបទជាបន្តទៅនេះ ផ្ដល់នូវលទ្ធផលដំបូងបំផុតដែលទទួលបាននៅក្នុងការអង្កេតដល់ទីកន្លែងនិងការវិភាគ ប្រភពសំណេរនានារយៈពេលប្រាំពីរខែ។

យើងពន្យល់នៅខាងក្រោមនេះ (សូមអានវិធីសាស្ត្រ និងដំណើរការនៃការអង្កេត) អំពីវិសាលភាពនៃការវិភាគដែល យើងបានប្រកាន់យក។ វិសាលភាពនេះគ្រាន់តែជា

ផ្នែកតូចមួយនៃសម្ភារៈដ៏សម្បូរដែលប្រមូលបានតែប៉ុណ្ណោះ ប៉ុន្តែយើង ត្រូវតែជ្រើសរើសយក។

នៅក្នុងផ្នែកដែលនិយាយអំពីលទ្ធផល យើងបង្ហាញពីទិន្នន័យដែលទាក់ទងទៅនឹងការធ្វើចំណាត់ប្រភេទនៃភាសានិង ជាតិពន្ធុនៅកម្ពុជា។ ទិន្នន័យនេះ មានលក្ខណៈទូទៅផងនិងដោយឡែកផងចំពោះស្ថានភាពកម្ពុជា។ យើងពិនិត្យផងដែរនូវ ថេរធាតុនៃជាតិពន្ធុមួយម្តងៗ : ប្រព័ន្ធសំណេរ ការអប់រំដោយប្រើពីរភាសា។ល។

ការងារនេះពាក់ព័ន្ធផ្ទាល់ទៅនឹងប្រធានបទនៃវិវិធភាពភាសា/វប្បធម៌នៅកម្ពុជា និងពាក់ព័ន្ធទៅនឹងការការពារនិង ការលើកស្ទួយវិវិធភាពនេះ។ គឺដោយហេតុផលនេះហើយដែលការអង្កេតនិងលទ្ធផលដែលទទួលបានផ្អែកលើការវិភាគនៃសញ្ញាណកម្មដូចជា ទ្វេភាសានិយម ភាសាក្នុងភាពគ្រោះថ្នាក់ ភាសាដែលកំពុងតែបាត់បង់ទៅ សំណេរ និងតួនាទីនៃការអប់រំ។ ផែនទីទូទៅមួយនិងផែនទីសាស្ត្រនៃជាតិពន្ធុភាគច្រើនអនុញ្ញាតឱ្យភ្ជាប់ប្រជាជនផ្សេងៗគ្នានេះទៅនឹងចំណែកទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ដោយមិនបានស្រង់តាមភូមិម្តងមួយៗ ទិន្នន័យនេះមានលក្ខណៈជាចំនួនប្រហាក់ប្រហែលនៅឡើយ ហើយត្រូវតែកែតម្រូវនិងបំពេញបន្ថែមនៅពេលអនាគត :

- តាមមធ្យោបាយ ហ្សេ ប៉េ អេស (GPS) និងតាមរយៈការលើកយកជាប្រព័ន្ធនូវកូអ័រដោណេដែលស្រង់បានដាក់ទៅ លើផែនទីភូមិសាស្ត្រយោង។
- តាមទិន្នន័យដែលមានភាពសុក្រិតជាង ស្តីពីប្រជាជននៃជាតិពន្ធុនីមួយៗដែលប្រការនេះអាចទទួលបានតែតាមការងារដល់ ទីកន្លែងផ្ទាល់ប៉ុណ្ណោះ។

អ្នកនិពន្ធសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោក ហ្សាវីយេ ដាប់សាក់ (Xavier D'Abzac) លោក អូលីវីយេ ដឺបែរណុង (Olivier de Bernon) លោក ប៉ាត្រិក ដឺកូបែរ (Patrick Decobert) លោក ហ្សេរ៉ា ឌីហ្វ្លូ (Gérard Diffloth) អ្នកស្រី គ្រីស្យាន ហ្វីលីពី (Christianne Filippi) លោក ហ្សង់-ព្យែរ ហ្វ្រង់ស្ស៊ី (Jean-Pierre Franchi) លោក មីកាអែល ហ្គ្រីម៉ូ (Michael Grimaud) លោក ប្លែស គីលីយ៉ង់ (Blaise Kilian) លោក រ៉េនមង្គល ក្រូចគី (Renmongkol Kraucht) លោក ម៉ាស្ហា លីនស្គី (Masha Linski) លោក ពៅ មុំ (Poeuv Mom) លោក ហ្សង់-ព្យែរ មុន (Jean-Pierre Mons) លោក ឡេអូ ភីវ (Leo Phiv) លោក ប្រុយណូ គីយេ (Bruno Quillet) លោក ក្លូត រ៉ាបូ (Claude Rabour) និងលោក ហ្វ្រង់ស័រ ស៊ីម៉ូណូ (Francois Simoneau) សម្រាប់ការងារ ដ៏លំបាកនៃការពិនិត្យឡើងវិញដែលគេបានស្ម័គ្រចិត្តធ្វើ និងសម្រាប់រាល់ការកែតម្រូវដ៏មានតម្លៃដែលជាលទ្ធផលនៃការពិនិត្យរបស់ពួកគេ។ សូមថ្លែងអំណរគុណផងដែរ ចំពោះសមាជិកនៃក្រុមបោះពុម្ពផ្សាយហ្វូណនដែលបានចំណាយពេលវេលាក៏ដូច ជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីរចនាទំព័រនៃអត្ថបទនេះ។

ទោះជាយ៉ាងណាក៏ដោយ ក៏ខ្លឹមសារនៃអត្ថបទនេះ នៅតែជាទំនួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ។

# ផ្នែកទីមួយ

## វិធីសាស្ត្រនិងដំណើរការនៃការអង្កេត

## ១.១.គោលបំណងនៃការអង្កេត

ការងារដែលបានធ្វើគឺសំដៅទៅដល់ការពិពណ៌នាអំពីស្ថានភាពទីមួយនៃភាសាជនជាតិភាគតិចនៅកម្ពុជា ។

មានអត្ថបទជាច្រើនដែលហួសសម័យទៅហើយស្តីពីជាតិពន្ធុភាគតិចនៅកម្ពុជា និងភាសារបស់គេ ប៉ុន្តែ ការផ្លាស់ប្តូរ ផ្នែកសង្គមនិងនយោបាយដែលមាននៅកម្ពុជាក្នុងរយៈពេលម្ភៃឆ្នាំ (១៩៧០-១៩៩៣) មិនមែនគ្មានឥទ្ធិពលទៅលើជោគ វាសនានៃសហគមន៍ជាតិពន្ធុនៃព្រះរាជាណាចក្រនេះនោះទេ :

- ភាសាមួយចំនួនដែលមាននិយាយនៅក្នុងការសិក្សាពីមុនៗ លែងឃើញមាននៅពេលសព្វថ្ងៃទៀតហើយ ។

- ចំនួនអ្នកនិយាយភាសាជនជាតិភាគតិចនានានៅកម្ពុជាមានការប្រែប្រួលយ៉ាងខ្លាំងជាទូទៅមានការធ្លាក់ចុះ ហើយស្ថិតិនៅ សម័យកាលអាណាព្យាបាលបារាំង និងសង្គមរាស្ត្រនិយមដែលយើងមាន លែងជាបច្ចុប្បន្នភាពតទៅទៀតហើយ ។

- សភាពក្នុងសហគមន៍នៃភាសាជនជាតិភាគតិច ត្រូវតែជាកម្មវត្ថុនៃការសិក្សាថ្មី ។ គឺត្រូវបង្ហាញថា តើអំពើះតទៅ ភាសាទាំងនេះត្រូវបានគេប្រើប្រាស់យ៉ាងដូចម្តេច ។

- សកម្មភាពក្នុងវិស័យអប់រំដែលបានធ្វើដោយអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល មិនមែនគ្មានផលវិបាកទៅលើ អនាគតនៃភាសារបស់ជាតិពន្ធុនៃកម្ពុជានោះទេ ។ ប៉ុន្តែ សកម្មភាពទាំងនោះ និងឥទ្ធិពលរបស់វាដែលអាចមើលឃើញ និង/ឬ ដែលអាចកើតមាននោះត្រូវតែមានការធ្វើជំរឿន ។

- សញ្ញាណនៃ «ភាសាក្នុងគ្រោះថ្នាក់» និងប្រធានបទដែលស្របទៅនឹងសញ្ញាណនេះ

ជាអាទិ៍ការដាក់ចេញនូវគោល នយោបាយនៃការពិពណ៌នា និងការធ្វើឱ្យមានជីវិត រស់រានឡើងវិញ សុទ្ធតែជាប្រធានបទថ្មីទាំងអស់ ដែលកំពុងតែតម្រង់ទិស នៃការស្រាវជ្រាវអំពីភាសាឡើងវិញក្នុងបែបផែនមួយដ៏ធំធេង។

ប្រធានបទជាច្រើនត្រូវបានជ្រើសរើសជាមុន ហើយជម្រើសនេះជាពន្លឺដឹកនាំដំណើរការនៃការស្រាវជ្រាវទាំងផ្នែក ការងារដល់ទីកន្លែងផ្ទាល់ក៏ដូចជាការពិនិត្យពិច័យទៅលើប្រភពសំណោរ :

- ការប៉ាន់ប្រមាណចំនួនប្រជាជននៃជាតិពន្ធុភាគតិចនីមួយៗនៅកម្ពុជា។
- ការធ្វើចំណាត់ប្រភេទភាសាជាក្រុមនិងជាអនុក្រុម។
- ការធ្វើជំរឿនប្រព័ន្ធសំណេរដែលមាន ឬកំពុងបង្កើត។
- វង្វាយតម្លៃនៃសមាមាត្ររវាងអ្នកនិយាយភាសាតែមួយ និងអ្នកនិយាយពីរភាសាសម្រាប់ភាសានីមួយៗ និងការចាប់ផ្តើម ធ្វើការវិភាគលើបញ្ញត្តិទ្វេភាសានិយមនៅក្នុងក្របខណ្ឌហេដ្ឋារចនាសម្ព័ន្ធកម្ពុជា។
- ការបង្កើតប្រភេទជាបឋមមួយ ដើម្បីស្វែងយល់ពីស្ថានភាពនៃភាសានីមួយៗ។

ផែនទីសាស្ត្រទីមួយបានត្រូវបង្កើតឡើងដើម្បីឱ្យបានយល់ពីស្ថានភាពភូមិសាស្ត្រនៃជាតិពន្ធុនីមួយៗ ដែលជាដំបូង ក្រោមរូបភាពនៃផែនទីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា ហើយបន្ទាប់មកក្រោមរូបភាពជាផែនទីសម្រាប់ក្រុមជាតិពន្ធុនីមួយៗ។

## ១.២.វិធីសាស្ត្រនិងការធ្វើអង្កេត

វិធីសាស្ត្រនៃការស្រាវជ្រាវនេះត្រូវបានផ្តោតជាសំខាន់ទៅលើសកម្មភាពបី

ជាអាទិ៍ :

- ការពិនិត្យពិច័យប្រភពសំណេរ
- ការងារចុះដល់ទីកន្លែងជាមួយជនជាតិភាគតិចនានា
- ការអង្កេតជុំវិញអ្នកដែលមានសកម្មភាព ការទាក់ទងនឹងជាតិពន្ធុភាគតិចនៃកម្ពុជា។

សកម្មភាពទាំងបីប្រភេទនេះ ត្រូវបានបង្កើតឡើងតាំងពីពេលចាប់ផ្តើម ហើយវាមានលក្ខណៈបំពេញអោយគ្នាទៅ វិញទៅមក ដោយហេតុថា :

ដើម្បីសាកល្បងពីចម្បាស់ភាពបច្ចុប្បន្ន នៃប្រភពដែលចាស់ៗទៅហើយនោះ ចាំបាច់ត្រូវប្រៀបធៀបប្រភពទាំងនោះទៅនឹង ទិន្នន័យនៃការអង្កេតដល់កន្លែងដែលទទួលបានមកពីជនជាតិភាគតិចនានា។

ជនជាតិទាំងនោះ មិនរស់នៅដាច់ពីគេឯងដោយគ្មានការប្រាស្រ័យទាក់ទងជាមួយនឹងពិភពខាងក្រៅនោះទេ។ ប៉ុន្មានឆ្នាំចុង ក្រោយនេះ គេឃើញមានការបង្កើនកម្មវិធីនៃអង្គការមនុស្សធម៌ដូចជាក្នុងវិស័យអប់រំជាដើម។

### ១.២.១.ការពិនិត្យពិច័យពីប្រភពសំណេរ

យើងបានប្រកាន់យកនូវប្រភពសំណេរនៅសម័យកាលបី :

- សម័យកាលអាណាព្យាបាលបារាំង
- សម័យកាលសង្គមរាស្ត្រនិយម និងសម័យកាលនៃសង្គ្រាមឥណ្ឌូចិនទីពីរ
- សម័យកាលបច្ចុប្បន្ន

ការពិពណ៌នាអំពីប្រភពសំណេរដែលយើងធ្វើបាននៅក្នុងសៀវភៅនេះ ស្របទៅ

នឹងបំណងបឋមពីរ ដែលយើងមិន អាចលាតសន្ធឹងអោយបានទូលាយ [១] :

- ដាក់អត្ថបទទាំងនោះទៅក្នុងបរិបទដែលបានបង្កើតវាឡើង ។
- លើកសំណើអំពីចំណាត់ប្រភេទទីមួយនៃអត្ថបទទាំងនោះ ។

អត្ថបទយោងដែលយើងបានពិគ្រោះនឹងមានដាក់បញ្ចូលទាំងស្រុងទៅក្នុងគន្ថនិទ្ទេស ។ វាមិនមែនជាការធ្វើជំរឿន អត្ថបទដែលមានទាំងអស់នោះទេ ប៉ុន្តែ វាជាការលើកតម្លៃនូវលក្ខណៈដែលលេចធ្លោនៃអក្សរសិល្ប៍នាសម័យកាល ដែលយើងបានផ្តោតអារម្មណ៍ទៅលើ ។

### ១.២.១.១.អាណាព្យាបាលបារាំង (១៨៦៣-១៩៥៣)

គឺជាសម័យកាលដែលសម្បូរជាងគេនូវការនិពន្ធ និងការសិក្សាផ្សេងៗអំពីជាតិពន្ធុនិងភាសារបស់ពួកគេ។ គួរសំគាល់ផងដែរថា នៅក្នុងសម័យអាណាព្យាបាល មិនដែលមានកម្មវិធីពិពណ៌នាអំពីភាសាជនជាតិភាគតិចនៅកម្ពុជាឡើយ ហើយអត្ថបទផ្សេងៗដែលយើងមានសព្វថ្ងៃនេះបានមកពីការស្រាវជ្រាវ និងការសិក្សាដែលបានធ្វើឡើងក្រោមចក្រភពនៃភាពចាំបាច់ និងផលប្រយោជន៍ផ្សេងៗគ្នា ដែលអ្នកមានចំណូលចិត្តតែងតែបន្សល់ទុកជាស្លាកស្នាម ។

សម័យកាលដំបូងបំផុតនោះ មានការងាររបស់អ្នកប្រាជ្ញធម្មជាតិវិទ្យាដែលរួមបញ្ចូលទៅក្នុងចំណោមអត្ថបទមានការស្រាវជ្រាវលំអិត និង ច្បាស់លាស់នូវទិន្នន័យនៃជាតិពន្ធុសាស្ត្រនិងភាសា[២] ព្រមទាំងមានរបាយការណ៍បូកសរុបនៃបេសកម្ម

---

[១] គួរកត់សម្គាល់ថា លើកលែងសម្រង់ផ្នែកសំខាន់១ខ្លះដែលងាកទៅរកប្រវត្តិសាស្ត្រនៃជនជាតិភាគតិច (Bozotte, 1995, Bourdier, 2005) គេមិនដែលសាកល្បងធ្វើការសិក្សា អំពីប្រភេទនៃអក្សរសិល្ប៍ដ៏ធំធេងនេះទេ ។

[២] ជាប់ទាក់ទងនឹងការពិពណ៌នាទាំងនេះ មានឈ្មោះ Moura, Garmier, Mouhot, De Carné ។ល។ ដែលយើងដាក់បញ្ចូលទាំងស្រុងទៅក្នុងគន្ថនិទ្ទេស ។ ផ្នែកនៃការងារដែលផ្តោត ទៅលើការពិពណ៌នាអំពីភាសានេះជាបញ្ជីនៃវាក្យសព្ទតូចៗ ។

យោធាក្នុងទឹកដីកម្ពុជា[៣] ដើម្បីកំណត់ព្រំដែនតំបន់និងសន្និកម្មនៃប្រជាជន។

បើប្រៀបធៀបទៅនឹងការងារដែលបានធ្វើនៅកូសាំងស៊ីន និងនៅតុងកាំងក្នុងសម័យកាលដូចគ្នានោះ ភាសានិយាយនៅកម្ពុជា ហាក់ដូចជាមិនត្រូវបានគេយកចិត្តទុកដាក់ដល់នោះទេ។ ហេតុនេះ នៅកម្ពុជាគ្មានអ្វីដែលអាចប្រៀបធៀបទៅនឹងការពិពណ៌នាពីភាសានៃជនជាតិភាគតិចនៅអាណ្ណាម និងកូសាំងស៊ីន ដូចគ្នានេះដែរ គេក៏មិនឃើញមានការងារណាដែលដូច សកម្មភាពដែលបានធ្វើដោយបុព្វជិតសាសនានៅវៀតណាមនោះដែរ ហើយគេក៏អាចកត់សំគាល់ផងដែរថា វាផ្ទុយទៅនឹង អ្វីៗដែលបានកើតមាននៅក្នុងទឹកដីវៀតណាម : «តាមការស្រាវជ្រាវនិងការពិគ្រោះឯកសារប្រភពភាគល្អសាននៃកម្ពុជា នៅជិតហើយអាចទៅដល់បាន ប៉ុន្តែគ្មានស្លាកស្នាមនៃការផ្សព្វផ្សាយសាសនា (Bourdier,1995) ឡើយ»។ ផលវិបាកមួយនៃបណ្តាផលវិបាកទាំងនោះ គឺគ្មានការងារដែលធ្វើដោយផ្ទាល់ទៅលើភាសាក្នុងស្រុក[៤]។ ការផ្សព្វផ្សាយសាសនាបាន ក្លាយជាមូលហេតុដ៏ធំនៅក្នុងការសិក្សានិងការពិពណ៌នាអំពីភាសា។

ការស្រាវជ្រាវជំហានដំបូងតាមបែបភាសាវិទ្យា ត្រូវបានធ្វើឡើងចាប់តាំងពីសម័យកាល[៥] នោះមកម្ល៉េះ។

---

[៣] បេសកម្ម Pavic ឥណ្ឌូចិនត្រូវបានរៀបរាប់ដូច្នេះឯងនៅក្នុងអត្ថបទរបស់វីរសេនីយឯក គុយពេ (Cupet)

[៤] ប៉ុន្តែយើងអាចឃើញមានប្រព័ន្ធសំណេរឡាតាំងយ៉ាងតិចក៏ពីរដែរ : ទីមួយគឺចំណោមព្នងចាស់នៅមណ្ឌលគីរី ទីពីរក្នុងចំណោមចារាយនៅរតនគិរី។ តាមការស្រាវជ្រាវរបស់យើង ប្រព័ន្ធសំណេរទាំងពីរប្រហែលជាមួយខ្ទីពីម្នងនៅដាឡាត់ ហើយមួយទៀតពីចារាយនៅវៀតណាម។

[៥] ដូចជាសន្ទានុក្រមនៃការនិយាយភាសាស្ទួច (Cabaton,1993) ជាដើម។

សម័យកាលទីពីរដែលបន្តមកដល់សម័យឯករាជ្យនៃប្រទេសកម្ពុជា គឺមានការបង្កើតនូវអត្ថបទភាសាវិទ្យា[៦]សុទ្ធសាធ ផែនទីជាតិពន្ធុភាសាវិទ្យា[៧] ឬការសិក្សាដ៏ច្រើនលើសលប់ដែលផ្តល់នូវទិន្នន័យភាសាវិទ្យា[៨] ។

### ១.២.១.២.សម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) និងសង្គ្រាមឥណ្ឌូចិនលើកទីពីរ (១៩៥៧-១៩៧០)

សម័យកាលដែលបន្តភ្លាមៗពីការទទួលឯករាជ្យ មិនត្រូវបានកំណត់ដោយការផ្លាស់ប្តូរដ៏គួរឱ្យកត់សំគាល់ណាមួយខាងផ្នែកស្រាវជ្រាវឡើយ ហើយភាសាបារាំងត្រូវបានបន្តប្រើប្រាស់ក្នុងការនិយាយតទៅទៀត យ៉ាងហោចណាស់ក៏រហូតដល់ដើមឆ្នាំហុកសិប[៩] ដែរ ។

ការលូកខ្លួនចូលរបស់អាមេរិកទៅក្នុងជម្លោះឥណ្ឌូចិនលើកទីពីរ ដែលបន្តទៅទៀតនោះ មិនមែនមិនជះផលវិបាក ដោយផ្ទាល់ទៅលើការស្រាវជ្រាវទាក់ទងទៅនឹងភាសានិងវប្បធម៌នៃជាតិពន្ធុភាគតិចនោះទេ មុនគេបង្អស់និងជាពិសេសគឺនៅវៀតណាមហើយមួយផ្នែកខ្លះនៅកម្ពុជា។ នៅសម័យនោះ គេឃើញមានកម្មវិធីស្រាវជ្រាវច្រើនទៅលើភាសានៅអាស៊ី អាគ្នេយ៍[១០] :

---

[៦] សទ្ទានុក្រមរបស់ Baradat ស្តីពីភាសាពៀរ (Baradat, 1941) ឬការងាររបស់ Cabaton ស្តីពីភាសាចាម (Cabaton ,1906) ។

[៧] Bitard បោះពុម្ពនៅឆ្នាំ១៩៥២ នូវផែនទីជាតិពន្ធុភាសាវិទ្យានៃតំបន់រឿនសៃដែលមានភាពច្បាស់លាស់ ។

[៨] ការងារបុរាណវិទ្យារបស់ Lévy (Lévy, 1943)

[៩] មិនមែនមានន័យថា បន្ទាប់មកគ្មានការងារប្រកបដោយគុណភាពជាភាសាបារាំងនោះទេ (សូមអាន Matras Troubetskoy, 1975) កម្លាំងជម្រុញអោយមានការស្រាវជ្រាវត្រូវបានភ្ជាប់ យ៉ាងឆាប់រហ័សទៅនឹងភាពដាច់ខាតនៃជម្លោះឥណ្ឌូចិនលើកទីពីរ ។

[១០] គឺមានជាពិសេសភាសាអូស្ត្រូអាស៊ី និងភាសាម៉ាឡាយូប៉ូលីណេស៊ី ។ យើងនឹងកំណត់និយមន័យនិងអោយឧទាហរណ៍លើសញ្ញាណភាសានេះ នៅក្នុងផ្នែកដែលនិយាយអំពីលទ្ធផល ។

- ទស្សនាវដ្ដីដែលនិយាយអំពីក្រុមច្បាស់លាស់នៃភាសា[១១]

- ការសិក្សាទូទៅទីមួយដែលនិយាយអំពីប្រជាជនអាស៊ីអាគ្នេយ៍នាសម័យទំនើប[១២]

- ការងារទីមួយដ៏ធំលើគន្ថនិទ្ទេសយោង និងបញ្ជីអក្ខរក្រមស្ដីពីភាសានៃឧបទ្វីបអាស៊ីអាគ្នេយ៍ [១៣] ។

- ការពិពណ៌នាទីមួយស្ដីពីវេយ្យាករណ៍ ងាយស្រួលនៃភាសាជនជាតិភាគតិចនៅវៀតណាមនិងនៅកម្ពុជាផងដែរ[១៤] ។

### ១.២.១.៣ សម័យទំនើប

ដោយត្រូវបានចាត់ទុកនៅក្នុងមុំពិសេស នៃការបោះពុម្ពផ្សាយស្ដីពីភាសានៅកម្ពុជា សម័យទំនើបចាប់ផ្ដើមនៅដើម ទសវត្សឆ្នាំ៩០ ។ ការពិតព្រឹត្តិការណ៍ដែលកើតបន្តបន្ទាប់ក្រោយថ្ងៃ១៧ មេសា ១៩៧៥ បានរុញច្រានកម្មវិធីស្រាវជ្រាវនិងការសិក្សាទាំងអស់នៅក្នុងវិស័យនេះឱ្យក្លាយទៅជារឿងបន្ទាប់បន្សំ ។ ប៉ុន្តែ ការងារខ្លះត្រូវបានបោះផ្សាយដោយផ្ដើមចេញពី សម្ភារៈដែលប្រមូលបានពីពេលមុន ។

សេចក្ដីព្រួយបារម្ភដែលនាំផ្លូវការងារនៃសម័យចុងក្រោយនេះគឺជារឿងផ្សេងហើយអាចសង្ខេបមកត្រឹមបីចំណុច ។

---

[១១] ឧទាហរណ៍ដ៏ល្អមួយគឺទស្សនាវដ្ដី សិក្សាភាសាមន-ខ្មែរ (MKS) ដែលលេខទីមួយបោះផ្សាយនៅឆ្នាំ១៩៦៤ ។

[១២] ស្នាដៃរបស់ Le Bar, Hickey, Musgrave (១៩៦៤) ។ នេះមិនមែនមានន័យថា គ្មានការសិក្សាទូទៅទៅលើប្រជាជននៃអាស៊ីអាគ្នេយ៍ពីមុនមកនោះទេ តួយ៉ាងជាទូទៅ Coedès (Coedès, ១៩៦២) ប៉ុន្តែមានន័យថា ការសិក្សាទាំងនោះមានគោលបំណងប្រវត្តិសាស្ត្រជាចំបង ។

[១៣] Huffman (1985) កាលបរិច្ឆេទនេះគឺជាកាលបរិច្ឆេទនៃការបោះផ្សាយហើយការងារចងក្រងអត្ថបទជាសៀវភៅចាប់ផ្ដើមឡើងតាំងពីឆ្នាំ១៩៦០ ។

[១៤] សូមអានការងាររបស់ Keller (Keller, 1976) និងការងាររបស់ Miller (Miller, 1976)

### ១.២.១.៣.១.ការងារស្ដីពីវិទ្យាសាស្ត្រជាតិពន្ធុ

វិទ្យាសាស្ត្រជាតិពន្ធុ ត្រូវបានកំណត់ជាទូទៅតាមទម្លាប់ថាជាបណ្ដុំបច្ចេកទេស និងចំណេះដឹងផ្ទាល់របស់ជាតិពន្ធុដែល មិនមានអក្សរដូចការផ្សព្វផ្សាយវិទ្យាសាស្ត្រ ឥណ្ឌាចិន និងលោកខាងលិចទេ។

វិទ្យាសាស្ត្រជាតិពន្ធុឬចំណេះដឹងរបស់ជនអន្តោប្រាណត្រូវបានចាត់ទុកជាយូរមក ហើយថា គ្មានផលប្រយោជន៍សម្រាប់ ពិភពលោកទំនើបដែលជាគោលការណ៍បាន បង្កើតនូវឧត្តមភាពនៃវិទ្យាសាស្ត្ររបស់ខ្លួនរួចមកហើយ។

ក្រោយពីបានឆ្លងកាត់ផ្លូវដ៏វែងអន្លាយរួចមក ការងារជាតិពន្ធុសាស្ត្រដែលអំណើះតទៅហួសសម័យទៅហើយនោះ វិទ្យាសាស្ត្រជាតិពន្ធុត្រូវបានគេយកចិត្តទុកដាក់ជាពិសេសនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រការនេះបានកើតមាននៅកម្ពុជាតាមរយៈការសិក្សាជាច្រើនដែលបង្ហាញថា ការចេះភាសាក្នុងស្រុកជារឿងចាំបាច់បំផុត[១៥] ហើយដែលបាននាំទៅរកការបោះពុម្ព ផ្សាយនូវការស្រាវជ្រាវជាច្រើនដែលរប៉ាត់រប៉ាយគួរឱ្យសោកស្ដាយ។

ការស្រាវជ្រាវទាំងនេះបាននាំទៅដល់ការវិភាគអំពីវាក្យសព្ទនៃបញ្ជីពាក្យជាតិពន្ធុវិទ្យាសាស្ត្រក្នុងស្រុក[១៦]។

### ១.២.១.៣.២.ការមានមនសិការចំពោះការបាត់បង់ភាសា/វប្បធម៌មួយ

ម្ដែឆ្នាំចុងក្រោយនេះ មានការលេចឡើងនូវក្ដីព្រួយបារម្ភដែលទាក់ទងនឹងអនាគតនៃភាសានិងវប្បធម៌របស់ជនជាតិភាគតិច។ ការប្រៀបធៀបទៅនឹងសម័យ

---

[១៥] ការងាររបស់ Bourdier (១៩៩៤ , ២០០៦) ស្ដីពីជាតិពន្ធុទំពូនជាសក្ខីភាពនៃនិន្នាការនេះ។

[១៦] គួរអោយសោកស្ដាយដែលការប្រើសញ្ញាតំណាងការបញ្ចេញសំលេងមិនសូវធំ។

កាលផ្សេងៗគ្នានៃប្រវត្តិភាសារបស់មនុស្សជាតិ អនុញ្ញាតឱ្យយើងបង្កើតបាននូវឯតទ្គកម្មមួយដ៏គ្រៀមក្រំសម្រាប់សម័យទំនើបយើងនេះ នោះគឺការបាត់បង់ភាសា និងវប្បធម៌ដែលមានសន្ទុះកើនឡើងមិន ដែលធ្លាប់មានពីមុនមក។ ការមានមនសិការនេះ បានអនុញ្ញាតឱ្យមានការដាស់ស្មារតីស្ដីពីការពិពណ៌នាភាសាដែលអំណើះ តទៅគេពិពណ៌នាអំពីភាសាជនជាតិភាគតិចប្រកបដោយមនោសញ្ចេតនានិងឆន្ទៈនៃការស្រោចស្រង់ភាសាមួយ។ វិធីសាស្ត្រនេះត្រូវបាន ស្តែងឡើងរួចមកហើយនៅក្នុងការពិពណ៌នាពីភាសាជាច្រើននៅកម្ពុជា[១៧] និងជំរុញឱ្យមានក្នុងពេលអនាគតនូវ ការពិពណ៌នាដទៃទៀត ព្រមទាំងការព្យាយាមសាកល្បងអំពីការធ្វើឱ្យរស់រានមានជីវិតឡើងវិញ។

វិធីសាស្ត្រគិតគូរអំពីភាសាក្នុងនាមជាបេតិកភណ្ឌដែលត្រូវអភិរក្ស និងអភិវឌ្ឍ មានលក្ខណៈអំណោយផលដល់ទស្សនាទានដ៏ថ្មីមួយស្ដីពីហេតុការណ៍ភាសានានា ពោលគឺទស្សនាទាននៃការពិពណ៌នាបែបបុរាណមួយ (សូរវិទ្យា សទ្ទវិទ្យា សម្ព័ន្ធវិទ្យា វចនវិទ្យា អក្សរសិល្ប៍ផ្ទាល់មាត់) ថែមទាំងការតម្រូវផ្សេងទៀត ដូចជាការបង្កើតប្រព័ន្ធសំណេរ និងបង្កើតកម្ម វិធីអប់រំដោយប្រើភាសាជនជាតិភាគតិច។

### ១.២.១.៣.៣.ការធ្វើសកម្មភាពនៅក្នុងវិស័យមនុស្សធម៌

ភាគច្រើនគឺសកម្មភាពដែលផ្ដល់ប្រយោជន៍ដល់ការអភិវឌ្ឍ ការអប់រំសម្រាប់ជនជាតិភាគតិចនៅកម្ពុជា[១៨]។

---

[១៧] ឧទាហរណ៍ដូចជាភាសា ស្ទូចនិងព្នង (Filippi, 2003, Vogel, 2005, Vogel et Filippi, 2007)

[១៨] ទោះបីជាយើងមិនបានបង្ហាញដោយចំហក៏ដោយ ក៏សកម្មភាពដែលធ្វើឡើងក្នុងវិស័យសុខាភិបាលមិនមែនថាគ្មានឥទ្ធិពលទៅលើចំណេះដឹងដ៏ប្រសើរអំពីភាសារបស់ជនជាតិភាគតិចនោះទេ។ ការងារពិពណ៌នាមួយចំនួនបានទទួលថវិកាជាដំបូង ដើម្បីធ្វើឱ្យមានអំណោយផលដល់វិធីសាស្ត្រសិក្សានៅទីកន្លែងដោយបុគ្គលិកសុខាភិបាល (Vogel et Filippi, 2007)

ក្រៅពីលក្ខណៈអន់ថយនៃការអប់រំក្នុងបណ្ដាខេត្តឆ្ងាយដាច់ស្រយាលនៃកម្ពុជា គេឃើញមានជនជាតិដើមភាគតិចខ្លះ និយាយតែភាសាមួយគត់ ហើយអ្នកផ្សេងច្រើនទៀតមានការចេះដឹងភាសាជាតិបន្ដិចបន្ដួចមិនអាចឱ្យពួកគេរៀនសូត្រជា ភាសាខ្មែរប្រកបដោយជោគជ័យបាន គឺការបង្រៀនជាភាសាខ្មែរអាចនឹងឱ្យពួកគេស្ថិតនៅក្នុងស្ថានភាពនៃការរៀនធ្លាក់ ហើយអាចនឹងជាកត្តាធ្វើអោយពួកគេស្ថិតនៅក្រៅសង្គមដែលផ្ទុយពីគោលការណ៍នៃការអប់រំ ។

ដូច្នេះ គំនិតបានជំរុញឱ្យបង្កើតកម្មវិធីជាភាសាកំណើតក្នុងគោលបំណងបង្រៀនសំណេរ និងអំណានជាភាសាកំណើត របស់សិស្សដើម្បីឈានទៅដល់ការសិក្សាទ្វេភាសា : ខ្មែរ-ភាសាជនជាតិភាគតិច ។ នៅកម្ពុជាមានតែភាសាជនជាតិដើមភាគតិចមួយចំនួនតូចប៉ុណ្ណោះដែលមានប្រព័ន្ធសំណេរ ។ ដូច្នេះត្រូវបង្កើតប្រព័ន្ធផ្សេងៗដែលប្រើប្រាស់អក្ខរាវិរុទ្ធខ្មែរ ប្រការនេះ នាំឱ្យមានការសិក្សាជាច្រើនពីទ្រឹស្ដីនៃសទ្ទវិទ្យានៃភាសាទាំងនោះ[១៩] ការសិក្សាពីគ្រាមភាសា[២០] ការសិក្សាពីភាពអាចធ្វើបាន[២១] ព្រមទាំងការបង្កើតយ៉ាងពិតប្រាកដនិងយ៉ាងប៉ិនប្រសប់នូវអក្ខរាវិរុទ្ធ ដែលអាចសម្រេចបានឬដែលបានសម្រេចរួច ហើយទៅនឹងភាសាដែលគេធ្វើការសិក្សានោះ[២២] ។ ការនិយាយត្រួសៗពីសម័យទំនើបនេះ តាមរយៈការបោះពុម្ពផ្សាយដែលមានស្ដីពី

[១៩] ចំពោះទំពួនសូមអាន Crowley (Crowley, 2000) ហើយចំពោះព្នងសូមអាន Filippi (Filippi, 1998) ។

[២០] ការសិក្សាពីគ្រាមភាសាវិទ្យាដ៏សំខាន់មួយរៀបចំឡើងដោយកិច្ចសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានជួយលើកតម្លៃនូវចំណងដែលចងភ្ជាប់ឈ្មោះជាតិពន្ធុផ្សេងៗគ្នាដែលតាមការពិតគឺ ជាគ្រាមភាសានៃភាសាប្រៅ ។

[២១] ចំពោះការអនុវត្តទៅលើភាសានិយាយរបស់ព្នងនៅមណ្ឌលគិរីសូមអាន Filippi (Filippi, 2000)

[២២] ឧទាហរណ៍ដ៏ល្អមួយគឺសៀវភៅរៀនសរសេរភាសាប្រៅ-គ្រឹងដែលមាននិយាយនៅខេត្តរតនគិរី (Keller, 2008)

កម្ពុជា អនុញ្ញាតឱ្យសន្និដ្ឋានបានចំពោះការលេចធ្លោនៃវិស្វកម្មភាសាដ៏ពិតប្រាកដមួយ ដែលនឹងត្រូវឆ្លើយតបបានយ៉ាងឆាប់រហ័ស ទៅនឹងតម្រូវការដែលបញ្ហាផ្សេងៗ ទាក់ទងទៅនឹងវិទ្យាស្ថានីយកម្ម នៃភាសាជនជាតិដើមភាគតិច នៃព្រះរាជាណាចក្រ នឹងបន្តលើកឡើងនៅក្នុងអនាគតខាងមុខនេះ។

### ១.២.២.ទេសកិច្ច

ទេសកិច្ចមានសង្គតិភាពនៅក្នុង :

- ការកំណត់ទីតាំងដើម្បីអង្កេត
- ការធ្វើឱ្យមានសុក្រិតភាពនូវកម្រងសំណួរនិងវិធីអង្កេតផ្សេងទៀត
- ការជ្រើសយកអ្នកផ្ដល់ព័ត៌មាន
- ការពិនិត្យពិច័យនិងការជ្រើសរើសទិន្នន័យ

#### ១.២.២.១.ការកំណត់ទីតាំងអង្កេត

ទីកន្លែងអង្កេតត្រូវបានជ្រើសរើសដោយអនុលោមតាម ប្រភពសំណេរដែលបានពិគ្រោះជាមុននិងអនុលោមតាម ចំណោះដឹងដែលយើងមានស្រាប់ស្ដីពីជនជាតិភាគតិច។

បណ្ដាខេត្តដែលបានជ្រើសយកសម្រាប់ការស្នាក់នៅដែលរយៈពេលមានការប្រែប្រួល គឺមានដូចតទៅ :

- កំពង់ស្ពឺ
- កំពត
- កំពង់ឆ្នាំង
- កំពង់ធំ

- សៀមរាប
- ព្រះវិហារ
- មណ្ឌលគិរី
- ក្រចេះ
- ស្ទឹងត្រែង
- រតនគិរី
- ពោធិ៍សាត់
- កោះកុង
- បាត់ដំបង

### ១.២.២.២.កម្រងសំណួរនិងវិធីអង្កេតផ្សេងទៀត

យើងបានចាប់ផ្តើមដោយបង្កើតកម្រងសំណួរ។ យើងគិតថា កម្រងសំណួរនេះនឹងត្រូវបានប្រើប្រាស់ជាការនាំផ្លូវជា ជាងសេរីនៃសំណួរដែលត្រូវសួរពីទីមួយដល់ទីចុងក្រោយបំផុតនោះ។

យើងជូនសេចក្តីលម្អិតដូចខាងក្រោម :

កម្រងសំណួរ

អ្នកផ្តល់ព័ត៌មានលេខ..........................................................................

ឈ្មោះអ្នកផ្តល់ព័ត៌មាន.......................................................................

កាលបរិច្ឆេទនៃកិច្ចសន្ទនា..................................................................

ទីតាំង................................................................................................

ឈ្មោះអ្នកអង្កេត ...........................................................................

I.ស្ថានភាពគ្រួសារ

១.តើអ្នកអាយុប៉ុន្មាន? ឬឆ្នាំកំណើត?

២.តើអ្នកមានទីកន្លែងកំណើតនៅឯណា?

៣.តើបច្ចុប្បន្នអ្នកប្រកបមុខរបរអ្វី?

៤.តើអ្នកអាចរៀបរាប់ពីសកម្មភាពប្រចាំថ្ងៃរបស់អ្នកបានឬទេ?

៥.តើអ្នកមានបងប្អូនប៉ុន្មាននាក់?

៦.តើអ្នករៀបការហើយឬនៅ?

៧.តើអ្នកមានកូនប៉ុន្មាននាក់?

ក.ភេទ

ខ.អាយុ

គ.មុខរបរ

ឃ.ទីលំនៅ

៨.តើអ្នកកាន់សាសនាអ្វី?

II.ការអប់រំ

១.តើអ្នកបានរៀនសូត្រទេ?

២.តើអ្នកមានអាយុប៉ុន្មាននៅពេលអ្នកចាប់ផ្តើមចូលរៀន?

៣.តើអ្នករៀនបានប៉ុន្មានឆ្នាំ?

៤.តើកូនរបស់អ្នកបានរៀនសូត្រឬទេ?

៥.តើមនុស្សប៉ុន្មាននាក់បានចូលរៀនឬកំពុងរៀនសព្វថ្ងៃនៅក្នុងភូមិរបស់អ្នក?

III.ភូមិ

១.តើភូមិអ្នកមានឈ្មោះអ្វី?

២.តើអ្នកអាចរៀបរាប់ប្រវត្តិភូមិរបស់អ្នកបានឬទេ?

៣.តើប្រជាជនក្នុងភូមិជានរណា ហើយគ្រួសារដែលរស់នៅក្នុងភូមិសព្វថ្ងៃមកពីណាដែរ?

៤.តើមានវត្តឬទេ? នៅចម្ងាយប៉ុន្មាន?

៥.តើមានផ្សារឬទេ? នៅចម្ងាយប៉ុន្មាន?

៦.តើមានសាលាឬទេ? នៅចម្ងាយប៉ុន្មាន?

៧.តើមានមនុស្សច្រើនទេដែលចេញទៅធ្វើការនៅខាងក្រៅ?

IV.ភាសានិងវប្បធម៌

១.តើភាសាដើមកំណើតរបស់អ្នកជាភាសាអ្វី?

២.តើអ្នកនិយាយភាសាអ្វីនៅផ្ទះ?

ក.រវាងប្តីប្រពន្ធ

ខ.ជាមួយកូនៗ

៣.តើអ្នកនិយាយភាសាអ្វីជាមួយមិត្តភក្តិ?

៤.តើអ្នកភូមិទាំងអស់និយាយខ្មែរឬទេ? តើកម្រិតចំណេះដឹងរបស់អ្នកភូមិខុសគ្នាឬទេ?

ក.តាមជំនាន់មនុស្ស

ខ.តាមភេទ

៥.តើនៅពេលណាអ្នកនិយាយភាសាមួយក្នុងចំណោមភាសាទាំងពីរនេះ ?

ក.អាស្រ័យតាមការប្រាស្រ័យទាក់ទងគ្នា

ខ.អាស្រ័យតាមគូសន្ទនា

គ.នៅក្រៅភូមិរបស់អ្នក

៦.តើអ្នកគិតថា ចំណេះដឹងអំពីភាសាកំណើតធ្លាក់ចុះឬទេ?

ក.ជំនាន់មនុស្ស : តើក្មេងៗនិយាយបានល្អដូចចាស់ៗឬទេ?

ខ.ភេទ : តើស្ត្រីឬបុរសដែលប្រើភាសាកំណើតច្រើនជាងគេ?

៧.លក្ខណៈនៃទ្វេភាសានិយម

តើអ្នកគិតទេថា អ្នកភូមិមាន :

ក.ការចេះដឹងល្អអំពីភាសាទាំងពីរឬទេ?

ខ.ការចេះដឹងល្អអំពីភាសាកំណើតឬទេ?

គ.ការចេះដឹងល្អអំពីភាសាខ្មែរឬទេ?

៨.ការចុះអន់ថយនៃភាសាកំណើត

ក.តើនៅពេលណាដែលគេចាប់ផ្តើមមិនសូវនិយាយភាសាកំណើត?

ខ.តើនៅពេលពិសេសណាខ្លះដែលគេចាប់ផ្តើមប្រើភាសាមួយផ្សេងទៀត?

គ.តើមនុស្សជំនាន់ក្រោយអាចសម្តែងមតិជាភាសាកំណើតបានយ៉ាងស្ទាត់ជំនាញ ឬទេ?

៩.ការមានប្រព័ន្ធសំណេរមួយ

ក.តើមានប្រព័ន្ធសំណេរបុរាណដែលអ្នកស្គាល់ឬទេ? តើនរណាជាអ្នកបង្រៀន

អ្នក? បង្រៀនយ៉ាងដូចម្តេច? តើសព្វថ្ងៃនេះអ្នកប្រើវាទៀតឬទេ? នៅពេលណា?

ខ.តើមានប្រព័ន្ធសំណេរទំនើបបែបឡាតាំងដែលអ្នកស្គាល់ឬទេ? តើនរណាជាអ្នកបង្រៀនអ្នក? បង្រៀនយ៉ាងដូច ម្តេច? តើសព្វថ្ងៃនេះអ្នកប្រើវាទៀតឬទេ? នៅពេលណាហើយប្រើដូចម្តេច?

គ.តើមានការសាកល្បងសរសេរភាសាអ្នកដោយប្រើតួអក្សរខ្មែរឬទេ?

ឃ.តើអ្នកចង់រៀនសរសេរភាសាអ្នកឬទេ? មូលហេតុអ្វី?

១០.ការបង្រៀន

ក.តើការបង្រៀនធ្វើឡើងជា :

-ភាសាខ្មែរ?

-ភាសាកំណើត?

ខ.តើអ្នកចង់ឱ្យមានការបង្រៀនជាភាសាកំណើតឬទេ? ព្រោះអ្វី?

គ.តើអ្នកគិតថា ការបង្រៀនជាភាសាកំណើតអាចជួយស្រោចស្រង់ភាសានេះឬទេ?

ឃ.តើអ្នកចង់ឱ្យកូនរបស់អ្នករៀនជាភាសាកំណើតរបស់អ្នកឬទេ?

១១.ការផ្សព្វផ្សាយភាសា

ក.តើមានអ្នកនិទានរឿងដែលប្រើភាសាកំណើតក្នុងភូមិឬក្នុងតំបន់ឬទេ?

ខ.តើអ្នកធ្លាប់ស្តាប់ការនិទានរឿងឬទេ? នៅពេលណា?

គ.តើភាសាកំណើតត្រូវបានប្រើនៅក្នុងចម្រៀងឬកំណាព្យឬទេ?

ឃ.តើមានទម្រង់ល្ខោនប្រើភាសាកំណើតឬទេ?

តាមការពិត កម្រងសំណួរបានក្លាយជាជំនួយស្មារតីដែលអនុញ្ញាតឱ្យផ្ដើមការសន្ទនាឡើងវិញនៅពេលមានការស្ទើរស្ទាក់។ តាំងពីពេលដំបូងនៃអង្កេត យើងចូលចិត្តផ្ដល់ដល់គាត់នូវប្រព័ន្ធកិច្ចសន្ទនាមួយដែលមិនសូវតឹងតែងនោះទេ។

ផលវិបាកនៃកិច្ចសន្ទនាគឺថា នីតិវិធីនេះត្រូវចំណាយពេលច្រើនជាងកម្រងសំណួរ ហើយវាពិបាកនឹងសម្ភាសន៍អោយលើសពី១នាក់ណាស់ក្នុងមួយថ្ងៃ។ ផលប្រយោជន៍ដែលសម្រាលដល់ផលវិបាកនេះគឺ កិច្ចសន្ទនាអនុញ្ញាតឱ្យរឹតចំណងសន្ដានចិត្តល្អរវាងអ្នកទទួលនិងអ្នកផ្ដល់ព័ត៌មាន ហើយអាចឱ្យគេឈានទៅដល់ការសន្ទនាស្និទ្ធស្នាលមួយយ៉ាងឆាប់រហ័ស។ ប្រការនេះ មិនអាចកើតមានទៅបានទេនៅក្នុងករណី នៃសំណួរ-ចម្លើយ។

### ១.២.២.៣.ការជ្រើសយកអ្នកផ្ដល់ព័ត៌មាន

បញ្ហានេះដែលមើលទៅហាក់ដូចជាស្រួល ប៉ុន្តែតាមពិតពិបាកខ្លាំងណាស់។ វាហាក់ដូចជាគ្មានបច្ចេកទេសណាមួយ សម្រាប់ការជ្រើសយកអ្នកផ្ដល់ព័ត៌មាននោះទេ[២៣]។ បើយើងគិតពីពេលខ្លីដែលយើងមានហើយចង់ទទួលព័ត៌មានទាំងអស់ដែលយើងចង់បាន អ្នកផ្ដល់ព័ត៌មានឥតខ្ចោះ នៅក្នុងសហគមន៍ណាមួយនោះគឺត្រូវមានលក្ខណៈដូចតទៅ :

- ចេះភាសាខ្មែរច្បាស់
- ស្គាល់ភូមិនិងតំបន់ជុំវិញភូមិច្បាស់
- មានសមត្ថភាពវាយតម្លៃតម្រូវការនិងអ្វីដែលអ្នកភូមិចង់បាន

[២៣] ការស្រាវជ្រាវភាសាវិទ្យាមួយផ្នែកធំកើតមាននិងបន្តកើតមានបញ្ហាខាងបច្ចេកទេសអង្កេត «ភាពផ្ទុយគ្នានៃអ្នកសង្កេត» ដូចអ្វីដែល W. Labov បានកំណត់ស្រាប់នោះអាចសង្ខេប យ៉ាងខ្លីពីស្ថានភាពនេះ (Labov, 1975)

ប្រការនេះបញ្ជាក់ថា ជារឿយៗយើងបានទៅរកប្រធានភូមិ ( ប្រហែល៥០ភាគរយនៃករណី) គ្រូព្យាបាលជំងឺនិងសាកាវីផ្សេងទៀត ( ប្រហែល៤០ភាគរយនៃករណី) ព្រមទាំងរកបរិស័ទសាសនា ( ប្រហែល១០ភាគរយ នៃករណី) ក្នុងករណីនៃសហគមន៍អ៊ិស្លាម ។ ដំណោះស្រាយផ្សេងទៀតអាចប្រើការបានដែរ ប៉ុន្តែទាមទារឱ្យមានការស្នាក់នៅ ក្នុងសហគមន៍យូរជាងនេះ ។

កិច្ចសន្ទនាត្រូវបានថតទាំងស្រុងទុកក្នុងថាសតូចៗ (MD) ។ កិច្ចសន្ទនាមានធ្វើនៅភ្នំពេញផងដែរ ជាពិសេសនៅ ស្នាក់ការសមាគមន៍ចិន ដើម្បីទទួលបាននូវទិន្នន័យបម្រាប់ទាក់ទងនឹងប្រជាសាស្ត្រ នៃក្រុមជនជាតិចិននានានៅកម្ពុជា និងទិន្នន័យទាក់ទងនឹងសាលារៀនចិនផងដែរ ។

### ១.២.២.៤.ការជ្រើសរើសទិន្នន័យ

ការប្រើប្រាស់វិធី ជាអាទិ៍ កិច្ចសន្ទនាតម្រូវឱ្យមានការថតទិន្នន័យដ៏ច្រើនសន្ធឹកសន្ធាប់ដែលទោះជាវាមានប្រយោជន៍ ច្រើនក៏ដោយ ក៏មិនទាន់មានចម្បាស់ភាពភ្លាមៗសម្រាប់កិច្ចការរបស់យើងនេះនៅឡើយ ។ ដូច្នេះ ត្រូវធ្វើការជ្រើសទិន្នន័យមួយចំនួនក្នុងចំណោមទិន្នន័យទាំងអស់ ហើយយើងអាចទាញយកប្រធានបទមួយចំនួនតូច ដែលទាក់ទងដោយផ្ទាល់ទៅនឹង ស្ថានភាពសង្គមភាសាវិទ្យានៃភាសាដូចអ្វីដែលសហគមន៍ណាមួយគិតឃើញតាមរយៈតំណាងមួយចំនួនរបស់ពួកគេ ។

ប្រធានបទដែលទាញបាន ហើយទាក់ទងទៅនឹងកិច្ចការរបស់យើងមានដូចតទៅ :

- ទិន្នន័យបរិមាណដែលទាក់ទងនឹងចំនួនអ្នកនិយាយក្នុងសហគមន៍ទំហំតូច ។

- ទិន្នន័យទាក់ទងនឹងការប្រើប្រាស់រួមគ្នាជាមួយភាសាមួយផ្សេងទៀត (ខ្មែរ ឬភាសាដទៃទៀត) និងការកំណត់ក្របខណ្ឌនៃ ការប្រើប្រាស់ភាសាទាំងពីរ ។

- ការមានប្រព័ន្ធសំណេរមួយ

- ស្ថានលក្ខណៈនៃការអប់រំ

**១.២.៣.ការស្រាវជ្រាវលើវិធីដែលមានសកម្មភាព នៅក្នុងសហគមន៍ជនជាតិភាគតិចនៅកម្ពុជា**

ប៉ុន្មានឆ្នាំចុងក្រោយនេះ គេឃើញមានការកើនឡើងនូវកម្មវិធីមនុស្សធម៌ក្នុងតំបន់នៃប្រទេសដែលមានជនជាតិភាគ តិចរស់នៅ។ ភាគច្រើននៃកម្មវិធីទាំងនោះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌអនាម័យ និងអក្ខរនីយកម្មនៃជនជាតិដើមភាគតិច។ អំណើះតទៅ អក្ខរនីយកម្មជាសេចក្តីកង្វល់ចម្បងមួយចំពោះអង្គការអន្តរជាតិ (UNICEF, UNESCO) ដែលទទួលស្គាល់ពីភាពចាំបាច់ក្នុងការលុបបំបាត់អនក្ខរកម្មចេញពីពិភពលោក។ សេចក្តីកង្វល់នេះបានជួបការ លំបាកភ្លាមៗទៅនឹងស្ថានភាពនៃតំបន់ជាច្រើនក្នុងពិភពលោក ក្នុងក្របខណ្ឌនៃសភាពមួយដែលមានជនជាតិដើមភាគតិច និយាយតែភាសាមួយឬមិនមានការចេះដឹងភាសាជាតិឱ្យបានគ្រប់គ្រាន់ដើម្បីអាចទទួលបានផលចំណេញពីនយោបាយអប់រំ។

គោលគំនិតគឺជំរុញឱ្យមានការបង្កើត ប្រព័ន្ធសំណេរសម្រាប់ភាសាទាំងឡាយណាដែលរហូតដល់ពេលបច្ចុប្បន្នមិនទាន់ មានប្រព័ន្ធសំណេររបស់ខ្លួន ប្រយោជន៍នឹងដាក់ឱ្យមានគោលនយោបាយអប់រំមួយសម្រាប់ជនជាតិភាគតិច។

ក្នុងករណីប្រទេសកម្ពុជា ជនជាតិភាគតិចដែលមានចំនួនប្រជាជនច្រើនជាងគេ

គឺរស់នៅប៉ែកឦសាន (ខេត្តមណ្ឌលគិរី រតនគិរី និងផ្នែកមួយនៃខេត្តស្ទឹងត្រែង) និងប៉ែកពាយព្យ (ខេត្តកំពង់ធំ និងខេត្តព្រះវិហារ)។

យើងបានពិគ្រោះគ្រប់ឯកសារទាំងអស់ដែលមាន ហើយដែលបង្កើតដោយដៃគូដែលបាននិងបន្តធ្វើការងារតទៅ ទៀតនៅក្នុងវិស័យអប់រំ មានជាអាទិ៍ អង្គការយូនីសេហ្វ (UNICEF) និងអង្គការក្រៅរដ្ឋាភិបាលពីរទៀត : កិច្ចសហ ប្រតិបត្តិការអន្តរជាតិកម្ពុជា និងអង្គការឃែរ (Care)។ ហេតុនេះ យើងបានស្វែងយល់ពីគោលនយោបាយរបស់អង្គការ ទាំងនោះនិងពីសមិទ្ធផលមួយផ្នែកដែលគេសម្រេចបាននៅទីនោះផ្ទាល់។ ប៉ុន្តែដោយកង្វះពេលវេលាគ្រប់គ្រាន់ យើងមិនអាចមានកិច្ចសន្ទនាស៊ីជម្រៅជាមួយដៃគូទាំងនោះ ដែលប្រហែលជាអាចនឹងផ្តល់ដល់យើងនូវវិធីសាស្ត្រមួយដ៏សកម្មស្តីពីកម្មវិធី នានាទាំងនោះ ដូចជាការវិវត្ត បញ្ហាទាក់ទងទៅនឹងការវាយតម្លៃ។ល។

# ផ្នែកទីពីរ

## លទ្ធផល

នៅក្នុងផ្នែកទីពីរនេះ យើងនឹងផ្តល់នូវបទបង្ហាញមានអំណះអំណាងពីលទ្ធផលនៃការអង្កេតទាំងមូលនិងអំណានរបស់យើង។ យើងមិនមានបំណងបង្ហាញបញ្ជីលទ្ធផលទាំងដុលនោះទេ ប៉ុន្តែយើងមានបំណងបង្កើតតារាងមួយដែលដាក់ បញ្ចូលនូវលទ្ធផលទាំងនោះ ដើម្បីស្វែងពីន័យរបស់វា។

វិធីសាស្ត្រដែលជ្រើសរើសយកមានដូចតទៅ :

- *ចំណាត់ប្រភេទ* ពោលគឺ បង្កើតគោលការណ៍ដែលលំឱនទៅនឹងចំណាត់ថ្នាក់នៃភាសាជាក្រុម ហើយអនុវត្តគោលការណ៍ នេះចំពោះភាសានានានៅកម្ពុជា។
- *ភូមិភាសាវិទ្យា*[២៤] ដែលតាមរយៈពាក្យនេះ យើងលើកសំណើវិធីស្តីពីប្រជាសាស្ត្រនិងទីតាំង ។
- *សង្គមភាសាវិទ្យា* ដែលអាចប្រើបានក្នុងបរិបទចង្អៀត។ ការវិភាគនេះផ្តោតទៅលើប្រធានបទទ្វេភាសានិយមនិង បញ្ហាពាក់ព័ន្ធសំណេរ។
-*អេកូភាសាវិទ្យា*[២៥] ដែលយើងផ្តោតទៅលើ «ស្ថានភាពសុខភាព» នៃភាសានិយាយដែលយើងសិក្សា។

---

[២៤] ការប្រើពាក្យ «ភូមិភាសាវិទ្យា»នេះហាក់ដូចមិនចំន័យទេ ពីព្រោះនៅក្នុងអក្សរសិល្ប៍ជំនាញទស្សនទាននេះមានន័យប្រហែលនឹង (សមមូល?)ពាក្យគ្រាមភាសាវិទ្យា (Troubetskoy, 1976)។ យើងប្រើពាក្យនេះក្នុងន័យថ្មី ព្រោះយើងគិតថាការប្រើប្រាស់នេះមិនខុសទាំងស្រុងនោះទេ ហើយម្យ៉ាងទៀត គឺយើងគ្មានពាក្យអ្វីផ្សេងទៀតទេសម្រាប់ប្រើ ដើម្បីបញ្ជាក់ពីទំនាក់ទំនងរវាងភាសានិយាយរបស់ជនជាតិភាគតិចនិងភាសានិយាយរបស់ជនជាតភាគច្រើនក្នុងន័យប្រជាសាស្ត្រនិងទីតាំង។

[២៥] យើងបង្កើតទស្សនាទាននេះ ដើម្បីស្វែងពីបដិសំយោគដែលកើតពីទំនាក់ទំនងរវាងការរួមចំណែករបស់ភាសាក្នុងការបង្កើតលំហសង្គម និងការបង្កើតលំហភាសាវិទ្យា (Filippi, នឹងការបោះពុម្ពផ្សាយនៅខែមេសាឆ្នាំ២០០៨)

## ២.១.ចំណាត់ប្រភេទភាសា

### ២.១.១.គោលការណ៍នៃចំណាត់ប្រភេទភាសា និងការអនុវត្តទៅលើភាសានិយាយនៅកម្ពុជា

វាមិនមែនជាការឥតប្រយោជន៍នោះទេ ក្នុងការផ្តល់នូវទិដ្ឋភាពតូចមួយស្តីពីវិធីសាស្ត្រដែលអនុញ្ញាតឱ្យប្រមូលផ្តុំភាសាជាគ្រួសារភាសា[២៦] ធំៗ។ វិធីសាស្ត្រនេះដែលអាចវាយតម្លៃបានថាជា «វិធីសាស្ត្រប្រៀបធៀប[២៧]» មិនផ្អែកលើភាព ស្រដៀងគ្នានៃធាតុនានាដែលយើងប្រៀបធៀបនោះទេ ប៉ុន្តែស្ថិតនៅលើភាពទាក់ទងគ្នាដែលយើងអាចបង្កើតឱ្យមានឡើង រវាងធាតុទាំងនោះ។ ឧទាហរណ៍មួយនឹងបំភ្លឺសំណើរបស់យើង។ បើយើងប្រៀបធៀបភាសាពីរដូចជាភាសាទួរគីនិងភាសា ហុងគ្រី យើងនឹងឃើញមានពាក្យជាច្រើនដែលដូចគ្នា :

| ទួរគី | ហុងគ្រី | បំណកប្រែ |
|---|---|---|
| çeb | zseb | ហោប៉ៅ |
| elma | alma | ផ្លែប៉ោម |

[២៦] ទិដ្ឋភាពនេះរឹតតែមានចម្បាស់ភាពនៅពេលបច្ចុប្បន្ន ព្រោះថា និន្នាការមនោគមន៍វិទ្យាខ្លាំងជាងនិន្នាការវិទ្យាសាស្ត្រដែលសាកល្បងញែកទ្រឹស្តីប្រពៃណីនៃអំបូរភាសាចេញ ហើយ ប្រកាន់យកគំនិតបែងចែកភាសាជាក្រុមដោយគិតថាភាសាទាំងអស់ប្រហែលជាមានប្រភពមកពីឫសគល់តែមួយគត់ (Ruhlen, 1997)។ វាមិនចាំបាច់បញ្ជាក់ទេថា ទោះជាយ៉ាងណាក៏គ្មានភស្តុតាងចំពោះការអះអាងនេះទេ វាអាចស្ថិតតែក្នុងស្ថានភាពសម្មតិកម្មប៉ុណ្ណោះ ក្នុងពេលដែលគេធ្វើការក្នុងទិសដៅភាសាវិទ្យា។

[២៧] បទបង្ហាញដែលមានលក្ខណៈដ៏ប្រសើរ និងងាយយល់ពីវិធីសាស្ត្រនេះ គឺស្ថិតនៅក្នុងផ្នែកដែលមានចំណងជើងថា «la parenté linguistique générique» នៃវណ្ណកម្ម «le Langage» (Hjemslev, 1963)

សូរ « ç » និង « zs » អានសូរដូចរៀងគ្នាទៅភាសាបារាំង « dj » និង « j » ។

ទោះបីជាមានភាពដូចគ្នាខ្លះដែលស្តែងពីការខ្ចីពាក្យគ្នា ហើយឧទាហរណ៍ពិតជាមានច្រើនក៏ដោយ ក៏ភាសាទួរគីនិង ភាសាហុងគ្រីមិនដូចគ្នាទាល់តែសោះ ហើយក៏មិនមែនមានប្រភពមកពីភាសាដើមតែមួយនោះដែរ ។

ផ្ទុយទៅវិញ បើយើងពិនិត្យភាសាពីរផ្សេងទៀតដែលនិយាយនៅទីកន្លែងពីរឆ្ងាយពីគ្នា : សំស្ក្រឹត និងណ្យូវ័របុរាណ (និយាយកាលពី១៥០០ឆ្នាំមុននៅស្កង់ឌីណាវី) ហើយបើយើងធ្វើលំហាត់ដូចគ្នា :

| សំស្ក្រឹត | ណ្យូវ័របុរាណ | បំណកប្រែ |
|---|---|---|
| Pita | fadar | ឪពុក |

យើងឃើញថាពាក្យទាំងពីរខុសគ្នា តែផ្ទុយទៅវិញភាសាទាំងពីរមានភាពស្រដៀងគ្នា ជាក់ស្តែងយើងអាចយកពាក្យ សំស្ក្រឹតជាច្រើនដែលចាប់ផ្តើមដោយអក្សរ P ពាក្យណ្យូវ័របុរាណដែលមានន័យដូចគ្នានឹងចាប់ផ្តើមដោយ អក្សរ f ទាំងនោះមានន័យថា ជាថេរភាពនៃទំនាក់ទំនង ហើយការណ៍នេះគេពិបាកនឹងថាជារឿងចៃដន្យណាស់ ។

កើតឡើងនៅដើមសតវត្សទីដប់ប្រាំបួន ហើយបន្តអនុវត្តនៅក្នុងពិភពលោកទាំងមូល វិធីសាស្រ្តនេះបានអនុញ្ញាតឱ្យ បង្ហាញពីភាពជាប់ខ្សែស្រឡាយស្រដៀងគ្នានៃភាសាមួយចំនួនធំ និងបានអនុញ្ញាតឱ្យគេប្រមូលផ្តុំភាសាទាំងនោះជាគ្រួសារ ។

### ២.១.២.អំបូរអូស្ត្រូ-អាស៊ី

#### ២.១.២.១.ចំណាប់អារម្មណ៍ប្រវត្តិសាស្ត្រ

ការសិក្សាអំបូរភាសាអូស្ត្រូអាស៊ី ចាប់ផ្ដើមនៅពាក់កណ្ដាលសតវត្សទីដប់ប្រាំបួន ហើយបន្តរហូតមកដល់សព្វថ្ងៃ[២៨] ។ ជាច្រើនដំណាក់កាល ការស្រាវជ្រាវទាំងនោះបាន អនុញ្ញាតឱ្យគេភ្ជាប់ខ្សែស្រឡាយគ្នានូវភាសាឧបទ្វីបអាស៊ីអាគ្នេយ៍ជាច្រើន ហើយបង្ហាញឱ្យឃើញផងដែរថា ភាសាទាំងនោះមានឫសគល់រួមគ្នា ។

អស់រយៈកាលដ៏យូរ ភាសាទាំងនោះត្រូវបានគេចាត់ទុកថាជាភាសា «មន-ខ្មែរ» ឯពាក្យ «អូស្ត្រូអាស៊ី» គឺគេប្រើសម្រាប់ក្រុមដែលមានកម្រិតខ្ពស់ជាង ពោលគឺស្មើ នឹងភាសា «មន-ខ្មែរ» +ភាសាមុណ្ឌា ។ ប៉ុន្តែពេលថ្មីៗនេះ មាននិន្នាការ មួយដែល ផ្ដល់អាទិភាពទៅឱ្យពាក្យអូស្ត្រូអាស៊ី[២៩] ទោះបីជាភាសាណាក៏ដោយឱ្យតែវានៅក្នុង អំបូរភាសានេះ ។

ភាសាក្នុងអំបូរនេះភាគច្រើនមាននៅប្រទេសកម្ពុជា ។

[២៨] គេអាចឃើញទិដ្ឋភាពលម្អិតនៃប្រវត្តិស្រាវជ្រាវបែបប្រៀបធៀបអូស្ត្រូអាស៊ីនៅក្នុងស្នាដៃ លោក Diffloth (Diffloth, 1974, 1980, 1982, 1984) និង Thomas (Thomas, 1964) ។

[២៩] គឺអ្វីៗដែល លោក Diffloth បានធ្វើនៅក្នុងចំណាត់ថ្នាក់ចុងក្រោយរបស់លោក (Diffloth, 2005) ។

## ២.១.២.២.ផែនទីដែលមានវត្តមានភាសាអូស្ត្រូអាស៊ី



តារាងខាងក្រោមនេះ ( Diffloth, 2005 ) បង្ហាញពីទំនាក់ទំនងរវាងក្រុមផ្សេងៗ និងអនុក្រុមនៃភាសាក្នុងអំបូរអូស្ត្រូអាស៊ី ។



គួរកត់សម្គាល់ថា តារាងខាងលើនេះ មិនបានរាប់បញ្ចូលនូវភាសានៃក្រុមពៀរិកទេ។ ហេតុផលគឺ ថាក្រុមនៃភាសា ក្នុងអំបូរអូស្ត្រូអាស៊ីនេះថ្វីត្បិតតែមានទីតាំងភូមិសាស្ត្រវានៅបូព៌ា[៣០] ក៏ដោយក៏នៅចោទជាបញ្ហាក្នុងការធ្វើចំណាត់ប្រភេទដោយហេតុថាភាសាទាំងនេះបង្ហាញពីលក្ខណៈផ្សេងគ្នា ដែលជួនកាលស្រដៀងទៅនឹងមែកធាងបូព៌ា ហើយជួនកាលទៀតទៅនឹងមែកធាងបច្ចិម។ ហើយទោះបីជាវាស្រដៀងទៅនឹងមែកធាងបូព៌ាដែលសព្វថ្ងៃគេហាក់ដូចជា ទទួលស្គាល់ក៏ដោយក៏បញ្ហា ចំណាត់ប្រភេទនៅក្នុងមែកធាងនេះនៅតែចោទ[៣១] ជាបញ្ហាដដែល។ យើងបង្កើតគំនូសបំព្រួយនៃ ក្រុមភាសាទាំងនោះ[៣២]ដូច ខាងក្រោម :




ទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពដ៏គួរឱ្យកត់សម្គាល់ ហើយដែលមើលឃើញនៅលើផែនទីភ្លាមៗនោះ គឺ ការនៅផ្តុំគ្នានៃក្រុមភាសាអូស្ត្រូអាស៊ី :

- ពីភាគកណ្តាលខាងកើតនៃប្រទេសឥណ្ឌាទៅសមុទ្រចិនខាងត្បូង

---

[៣០] គ្រប់ភាសាទាំងនេះនិយាយនៅកម្ពុជានិងថៃ។

[៣១] Gérard Diffloth បទបង្ហាញផ្ទាល់ខ្លួន។

[៣២] Gérard Diffloth បទបង្ហាញផ្ទាល់ខ្លួន។ កន្លែងនេះគឺចង់និយាយអំពីភាសាពៀរិកដែលមាននិយាយនៅក្នុងទឹកដីកម្ពុជាបច្ចុប្បន្នតែប៉ុណ្ណោះ។

- ពីប្រទេសចិនខាងត្បូង( ខាងត្បូងយូណាន) ទៅម៉ាឡេស៊ីកណ្តាល

លើសពីនេះ ភាសាទាំងនេះមាននិយាយនៅលើទ្វីប លើកលែងតែភាសានៅប្រជុំកោះនីកូបារ ។

ហេតុការណ៍ទាំងពីរនេះអនុញ្ញាតឱ្យគេទាញចេញនូវសម្មតិកម្មដ៏គួរអោយចាប់អារម្មណ៍ស្តីពីប្រភពភូមិសាស្ត្រនៃអំបូរភាសានេះ ។

ហេតុការណ៍គួរឱ្យកត់សម្គាល់មួយទៀត គឺការប្រមូលផ្តុំដ៏សំខាន់នៃភាសាអូស្ត្រូអាស៊ីនៅក្នុងតំបន់មួយដែលក្តោប ប៉ែកខាងកើតនៃប្រទេសថៃ ព្រះរាជណាចក្រកម្ពុជា ទឹកដីមួយផ្នែកធំនៃប្រទេសឡាវ និងវៀតណាមផងដែរ ។

តារាងខាងក្រោមនេះបង្ហាញពីភាសាអូស្ត្រូអាស៊ីដែលនិយាយនៅកម្ពុជា :

| អំបូរ | មែកធាង | ក្រុម | អនុក្រុម | ភាសា | ទីតាំង |
|---|---|---|---|---|---|
| អូស្ត្រូអាស៊ី | ខាងកើត | ខ្មែរ | ខ្មែរកណ្តាល | ខ្មែរ , កម្ពុជា | កម្ពុជា<br>ប៉ែកខាងកើតនៃប្រទេសថៃ<br>កូសាំងស៊ីន |
| អូស្ត្រូអាស៊ី | ខាងកើត | បាណារិក | បាណារិកខាងជើង | កាចូ កាន់ចូ<br>ឡាម៉ាម | កម្ពុជា ( រតនគីរី)<br>( វៀតណាម) |
| អូស្ត្រូអាស៊ី | ខាងកើត | បាណារិក | បាណារិកខាងជើង | ប្រៅ | កម្ពុជា<br>( រតនគីរី) |
| អូស្ត្រូអាស៊ី | ខាងកើត | បាណារិក | បាណារិកកណ្តាល | ទំពួន | កម្ពុជា<br>( រតនគីរី) |
| អូស្ត្រូអាស៊ី | ខាងកើត | បាណារិក | បាណារិកខាងត្បូង | មនុង ស្មៀង | កម្ពុជា<br>( ក្រចេះ មណ្ឌលគីរី<br>វៀតណាម) |
| អូស្ត្រូអាស៊ី | ខាងកើត | កាទូ | កាទូខាងលិច | កួយ | កម្ពុជា ( ព្រះវិហារ កំពង់ធំ<br>ក្រចេះ ស្ទឹងត្រែង) ថៃ ឡាវ |
| អូស្ត្រូអាស៊ី | ខាងកើត | វៀត | វៀង -មុង | វៀតណាម | វៀតណាម កម្ពុជា ឡាវ ថៃ |
| អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ពៀរិកខាងលិច | សំរ៉ែ | កម្ពុជា( ពោធិ៍សាត់) |
| អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ពៀរិកខាងកើត | សំរ៉ែ | កម្ពុជា ( កោះធំ) |
| អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ពៀរនៃវាលរេញ | ស្អូច ជុង | កម្ពុជា ( កំពត) |
| អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ពៀរនៃកំពង់ធំ | ព័រ | កម្ពុជា( ព្រះវិហារ) |
| អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ពៀរនៃកំពង់ស្ពឺ | ស្អួយ ស្អុង | កម្ពុជា( កំពង់ស្ពឺ) |
| អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ពៀរនៃសៀមរាប | សំរ៉ែ ( បាត់បង) | កម្ពុជា( សៀមរាប) |

### ២.១.៣.អំបូរអូស្ត្រូណេស៊ី

អំបូរភាសានេះមានវត្តមានតាំងពីដើមសតវត្សទីដប់ប្រាំបី ហើយត្រូវបាន កំណត់យ៉ាងច្បាស់លាស់ចាប់តាំងពីពាក់ កណ្ដាលសតវត្សទីដប់ប្រាំបួន[៣៣] ។

វាជាអំបូរភាសាមួយដែលមានវិសាលភាពធំជាងគេនៅក្នុងពិភពលោក ព្រោះ ភាសាដែលមាននៅក្នុងអំបូរនេះ ត្រូវបានគេនិយាយនៅក្នុងទឹកដីដែលលាតសន្ធឹងពី កោះប៉ាកទៅម៉ាដាហ្គាសស្កា និងពីភូមិភាគកណ្ដាលនៃវៀតណាមទៅ ប៉ូលីណេស៊ី ។

[៣៣] គេនឹងឃើញមានព័ត៌មានមួយចំនួនធំទាក់ទងនឹងអំបូរភាសានេះនៅក្នុង Thurgood (Thurgood, 1999) ដែលយើង យកអត្ថន័យមកសង្ខេបនៅទីនេះ ។

គំនូសបំព្រួញនៃអំបូរភាសាខាងលើនេះ(Thurgood,1999) អាចឱ្យគេឃើញយ៉ាងច្បាស់នូវហេតុការណ៍ដូចតទៅនេះៈ ផ្ទុយពីអំបូរភាសាអូស្ត្រូ-អាស៊ី អំបូរភាសាអូស្ត្រូណេស៊ីភាគច្រើននិយាយនៅតាមបណ្តាកោះ លើកលែងតែ : ភាសាម៉ាឡេ និយាយនៅឧបទ្វីបម៉ាឡេស៊ី ភាសារ៉ាត ចារាយ ជ្រូ និងចាមដែលស្ថិតក្នុងអនុក្រុមចាមិក



ហើយដែលនិយាយនៅវៀតណាម ហើយក្នុងនោះមានភាសាពីរពោលគឺ ចារាយនិង-ចាម[៣៤] ដែលនិយាយនៅកម្ពុជា។

ខាងក្រោមនេះជាគំនូសបំព្រួញលម្អិតពីអនុក្រុមម៉ាឡេ-ចាម (Thurgood, 1999)។




ភាសាចាមនិយាយសព្វថ្ងៃនៅវៀតណាម និងនៅកម្ពុជាដូចជាមិនមែនភាសាជាតិដើមទេ ហើយប្រជាជនដែលនិយាយភាសាចាមនេះ ប្រហែលជាមកពីភាគខាងជើងនៃប៉ែកណេអូ[៣៥]។

---

[៣៤] កាលពីមុនមានជនជាតិ *រ៉ាដេ* បួនដប់គ្រួសានៅកម្ពុជា។ យើងអាចដឹងបានដោយសារព័ត៌មានដែលបានផ្ដល់ឱ្យយើងដោយអ្នកភូមិដាក់ដាំក្នុងខេត្តមណ្ឌលគិរី។ ជនជាតិនេះ មានចំនួន ច្រើននៅវៀតណាមក្នុងខេត្តដាក់ឡាក់ជិតខេត្តមណ្ឌលគិរី។ សព្វថ្ងៃភាសានេះ ហាក់ដូចជាបាត់បង់អស់ពីកម្ពុជាទៅហើយ។

[៣៥] «The Sa Huynh sites reflect the Austronesian-speaking group that settled on the coast of Vietnam from an earlier homeland in perhaps Malaya or, more likely, Borneo, sometime before 600 BC... » (Bellwood, 1985) voir aussi Thurgood (Thurgood, 1999).

នៅប្រទេសកម្ពុជា ជនជាតិចារាយ២០ ០០០នាក់រស់នៅក្នុងខេត្តរតនគិរី ប៉ុន្តែជនជាតិនេះភាគច្រើនរស់នៅ វៀតណាមក្នុងខេត្តដែលជាប់នឹងខេត្តរតនគិរី [៣៦] ។

ចំពោះជនជាតិចាមវិញ ស្ថានភាពមានសភាពស្មុគស្មាញ។ ទំនាក់ទំនងជាមួយប្រជាជនខ្មែរ ហាក់ដូចជាមានតាំងពី ដើមគ្រឹស្តសករាជ ហើយជារឿយៗតែងមានសង្គ្រាមជាមួយគ្នា (Vickery, 2004) ។

ការធ្វើអន្តោប្រវេសន៏ដ៏ច្រើននៃជនជាតិចាមឆ្ពោះមកទឹកដីកម្ពុជាបានចាប់ផ្តើមឡើងតាំងពីសតវត្សទី១៥ស្របពេល នឹងការវាយយកបានវិជ័យ (១៤៧១) ដោយដាយវៀត ហើយបន្តរហូតដល់សតវត្សទី១៩។

ចំណុចចុងក្រោយមួយដែលសក្តិសមនឹងលើកមកបង្ហាញ : លោកអាចារ្យកាតូលិក Wilhelm Schmidt[៣៧] ជនឆ្នើមម្នាក់ក្នុងវិស័យភាសាវិទ្យាអូស្ត្រូអាស៊ី បានស្នើឱ្យប្រមូលផ្តុំអំបូរភាសាអូស្ត្រូអាស៊ី និងអូស្ត្រូណេស៊ីទាំងអស់ធ្វើជាក្រុមមួយដែលគាត់ហៅថា «អូស្ត្រីក» (Austrique) ។ នៅពេលនោះ ទោះជាមានអ្នកគាំទ្រខ្លះៗក៏ដោយ (Hayes, 1992, Reid, 1994) វាហាក់ដូចជាមិនមានអំណះអំណាងគ្រប់គ្រាន់ដែលអាចឱ្យជឿបានដើម្បីបុកស្រាយពីសម្មតិកម្មនេះ (Diffloth, 1994) ។

### ២.១.៤.ភាសាចិន

#### ២.១.៤.១.សភាពបញ្ហា

អ្វីដែលយើងហៅជាទូទៅថា «ភាសាចិន» តាមពិតទៅ ជាប្រធានបទមួយដែល

---

[៣៦] វាហាក់ដូចជាលែងមានព្រំដែនធម្មជាតិក៏ដូចជាព្រំដែនភាសារដែររវាងតំបន់ទាំងពីរ ។

[៣៧] អត្ថបទស្ថាបនិករបស់គាត់ដែលធ្លាប់ដើមជាភាសាអាល្លឺម៉ង់ត្រូវបានបកប្រែភ្លាមៗជាភាសាបារាំង (Schmidt,1905, 1906) ។

ពោរពេញដោយភាពចម្រូងចម្រាស់។ ការពិភាក្សា ត្រូវបានធ្វើឡើងតាំងពីជាងមួយសតវត្សកន្លះមកម្ល៉េះដើម្បីកំណត់ថា តើភាសាចិនខុសៗគ្នាគួរត្រូវចាត់ទុកជា ភាសាឬជាគ្រាមភាសា។

តាមពិត ភាពចម្រូងចម្រាស់នេះបណ្ដាលមកពីមូលហេតុផ្សេងវិញ :

- ចក្ខុវិស័យប្រទេសចិនផ្អែកលើទៅលើអត្តសញ្ញាណអារ្យធម៌គាំពារដោយប្រព័ន្ធសំណេរអក្សរតែមួយគត់។

- ឆន្ទៈមិនចង់បែងចែកនិងលើកស្ទួយឯកភាពជាតិពន្ធុនៃសមាសភាពចិននៅលើទឹកដីប្រទេសចិន។

គេត្រូវបន្ថែមទៅលើអ្វីដែលបានលើកឡើងនេះ នូវលក្ខណៈពាក់ព័ន្ធដែលមានក្នុងទស្សនាទាននៃគ្រាមភាសា[៣៨]។

និយមន័យទំនើបនៃពាក្យគ្រាមភាសា គឺជាភាសានិយាយដែលគេប្រើអោយយល់គ្នាទៅវិញទៅមក ហេតុនេះហើយ បានជាគេបង្កើតគំនិតច្រវាក់គ្រាមភាសាដែលប្រជុំទៅដោយភាសានិយាយជាច្រើន គេអាចយល់គ្នាបានលើកលែងតែភាសាដែលនៅខាងចុងសងខាងនៃច្រវាក់នេះ។

ប៉ុន្តែចិនវិទូ[៣៩]ជាច្រើនបានចាត់ទុកថានៅក្នុងពិភពនៃភាសាចិនទាំងអស់មានរបាំងដែលមិនអាចឱ្យគេយល់គ្នាទៅវិញ ទៅមកបាន[៤០]។

---

[៣៨] ចំពោះប្រធានបទនេះ សូមអាន Bloomfield, 1933; Kratochvil, 1964; Haugen, 1966; Trudgill, 1974; Chao, 1976។

[៣៩] ក្នុងនោះមានលោក De Francis (De Francis, 1990) និង Baxter (Baxter, 1992)

[៤០] «ចិនមិនមែនជាភាសាមួយទេ ប៉ុន្តែជាអំបូរភាសាដែលកើតឡើងដោយភាសានានាដែលមិនអាចយល់គ្នាបាន» (De Francis, 1999)។

ចំណាប់អារម្មណ៍ទាំងនេះ ទីបំផុតសម្រេចហៅថា «ភាសាចិន» ហើយវាស្ទើរតែក្លាយទៅជាវិធាន[៦៩] មួយទៅហើយ ។ ចំណែកឯពាក្យ «គ្រាមភាសាវិញ» គេបានរក្សាទុកសម្រាប់ហៅភាសាចិននានា ដែលអាចយល់គ្នាបាននៅក្នុងរង្វង់នៃភាសាផ្សេងៗទាំងនោះ ។

គួរកត់សម្គាល់ផងដែរថា គេកាន់តែមាននិន្នាការទៅរកការជំនួសពាក្យ «ភាសាចិន» ដោយសំនួនវោហារសព្ទ «ក្រុមភាសាចិន» ដែលយើងនឹងប្រើក្នុងពេលអំណើះតទៅនេះ ។

### ២.១.៤.២.ចំណាត់ប្រភេទនៃក្រុមភាសាចិន

គំនូសតាងខាងក្រោមនេះ គឺចំលងចេញពីសៀវភៅលោក De Francis, (De Francis, 1990)




[៦៩] ឧទាហរណ៍នៅក្នុងស្នាដៃរបស់ Wang, (Wang, 1991)

ភាសាចិននិងភាសាទីបេជាសមាជិកនៃក្រុមស៊ីណូទីបេតាំង[៤២] ។ ទោះបីជាចំនុចនេះនៅមានភាពចំរូងចំរាស់ក៏ដោយ ក៏គេបាន ព្រមព្រៀងគ្នានៅលើភាសាចិនចំនួន៨ ដែលភាសានីមួយៗមានគ្រាមភាសារបស់ខ្លួនមួយចំនួន ។

ផែនទីមួយនឹងបង្ហាញពីវត្តមាននៃភាសាទាំងនេះនៅតាមទីកន្លែងនានា :




[៤២] ការបញ្ចូលទៅក្នុងក្រុមនេះនូវភាសាតៃទាំងអស់ដែលការនេះត្រូវបានគេធ្វើរហូតមកដល់ពាក់កណ្ដាលសតវត្សទី២០នោះ សព្វថ្ងៃនេះកំពុងឈានទៅរកការបោះបង់ចោលហើយទោះបី មានអ្នកការពារខ្លះៗក៏ដោយ ។ វត្តមាននៃភាសាតៃនៅក្នុងតារាងដែលមានភាសាចិននិងភាសាទីបេ ក៏ដោយសារតារាងនេះត្រូវបានគូរកាលពីមុនយូរមកហើយ ។

### ២.១.៤.៣. ក្រុមភាសាចិននៅកម្ពុជា

វាជាការចាំបាច់ដែលត្រូវនិយាយអំពីភាសាទាំងនេះ ព្រោះក្រុមភាសាចិនចំនួនប្រាំមួយមាននិយាយ នៅកម្ពុជា :

- ទាជីវ
- កន្តាំង
- ហៃណាំ
- ខិ
- ហុកកៀន
- គ្រាមភាសាចិនប៉ែកខាងជើង

មានវត្តមានជនជាតិចិននៅកម្ពុជាតាំងពីសម័យនគរភ្នំ[៤៣] តាមរយៈស្នាដៃ លោកជីវតាក្វាន់[៤៤] (Zhou Da Guan) យើងបានដឹងផងដែរពីវត្តមានរបស់ជនជាតិចិនដែលមកតាំងទីលំនៅក្នុងតំបន់អង្គរចាប់តាំងពីសតវត្សទី១៣។

ប៉ុន្តែ គឺចាប់ពីសតវត្សទី១៦តែប៉ុណ្ណោះដែលគេអាចនិយាយពីចំនួនប្រជាជនចិនដ៏ច្រើននៅកម្ពុជា ពិសេសនៅតំបន់ ចតុមុខ[៤៥]។

ជំរឿនលើកទីមួយដែលបានធ្វើនៅសម័យអាណាព្យាបាលបារាំង ក្នុងឆ្នាំ១៩២១ បានឱ្យដឹងថាមានជនជាតិចិនចំនួន ៩១ ២០០នាក់។ ការប៉ាន់ប្រមាណដែលធ្វើឡើង

---

[៤៣] គឺពង្សាវតាចិននៃសម័យកាលថាំងដែលបានផ្តល់ដល់យើងនូវព័ត៌មានស្តីពីនគរភ្នំ (Pelliot, 1903)។

[៤៤] មានការបោះពុម្ពផ្សាយជាភាសាចិន ប៉ុន្តែយើងប្រើឯកសារបោះពុម្ពជាភាសាបារាំងដែលបានបកប្រែដោយ Pelliot

[៤៥] សម្រាប់ព័ត៌មានពិស្តារសូមអាន Willmott (Willmott, 1967)

ក្នុងសម័យកាល១៩៥០-១៩៦៦បង្ហាញថាមានប្រជាជនចិនចំនួន៤២៥ ០០០ នាក់នៅកម្ពុជា ។

សព្វថ្ងៃនេះ ក្រៅពីតួលេខរបស់សមាគមចិន យើងមិនទាន់មានស្ថិតិច្បាស់លាស់ណាមួយទេ ។

ពីមុនក៏ដូចសព្វថ្ងៃដែរ មានបញ្ហាមួយទៀតគឺសំណួរស្ដីពីលក្ខណៈវិនិច្ឆ័យដែលកំណត់ពីស៊ីនីភាពនៅកម្ពុជា (Willmott, 1970) ។ យើងមិនចូលទៅក្នុងកិច្ចពិភាក្សាដ៏ចម្រូងចម្រាសនេះទេ ប៉ុន្តែយើងផ្ដោតអារម្មណ៍តែទៅលើវង្វាយ តម្លៃប្រហាក់ប្រហែលនៃចំនួនអ្នកចេះភាសាចិននីមួយៗ ទោះបីជាការវាយតម្លៃនេះស្ថិតក្នុងកំរិតប្រហាក់ប្រហែលក៏ដោយ ។

## ២.១.៥.ភាសាតៃកាដាយ

ភាសាចុងក្រោយមួយដែលមាននិយាយនៅកម្ពុជា ហើយមិនបានបញ្ចូលទៅក្នុងក្រុមនានាខាងលើនោះ គឺភាសាឡាវ ។

ដូចភាសាតៃដទៃទៀតដែរ ការភ្ជាប់ទៅឬសគល់វែងឆ្ងាយរបស់វាក៏មានភាពចម្រូងចម្រាស់ខ្លះៗដែរ ។ ដូចនេះ តារាងដែលនិយាយពីភាសាស៊ីណូទីបេតាំង មានបញ្ចូលមែកធាងតៃនៅក្នុងកម្រិតស្មើគ្នាជាមួយភាសាចិននិងភាសាទីបេដែរ ។ ការចងជាក្រុមនេះមាន ការតវ៉ានាពេលសព្វថ្ងៃនេះ ពីព្រោះតាំងពីពាក់កណ្ដាលសតវត្សទី២០មក គេបានចាត់ទុកថា មានក្រុម តៃកាដាយដែលអាចហៅថាដាយអ៊ីកហើយដែលខុសស្រលះពីក្រុមស៊ីណូ-ទីបេតាំង[៤៦] ។

[៤៦] ចំណាត់ថ្នាក់ចុងក្រោយទៅលើទិន្នន័យ «ជាតិពន្ធុវិទ្ធ» បែងចែកយ៉ាងដាច់ស្រលះរវាងអំបូរទាំងពីរ ។

តារាងខាងក្រោមនេះ ត្រូវបានយើង សម្រួលអោយសាមញ្ញបំផុត :




**២.១.៦.បញ្ហាទាក់ទងទៅនឹងចំណាត់ប្រភេទភាសា :**

**ចំណេះដឹងវិទ្យាសាស្ត្រនិងចំណាត់ប្រភេទក្នុងស្រុក**

ចំណាត់ប្រភេទដែលយើងបានប្រើខាងលើនេះ ជាចំណាត់ប្រភេទដែលភាសាច្រើនប្រើដោយភាសាវិទូប្រៀប ធៀបឬអ្នកជំនាញខាងភាសាអូស្ត្រូអាស៊ី ឬអ្នកជំនាញខាងភាសាអូស្ត្រូណេស៊ី ឬអ្នកខ្លះទៀតជាអ្នកជំនាញខាងភាសាសចិន ហើយអ្នកខ្លះទៀតជាអ្នកជំនាញខាងភាសាតៃ-កាដាយ ។

បំណងដែលភាសាវិទូប្រៀបធៀបចង់បាន គឺពិនិត្យទំនាក់ទំនងរវាងភាសាមួយចំនួនដើម្បីរកឱ្យឃើញការភ្ជាប់ ទៅនឹងក្រុមណាមួយជាយថាហេតុហើយផ្ដើមចេញ

ពីនោះគឺលើកសំណើស្ដីពីការបង្កើតឬសគល់ភាសារួមមួយឡើងវិញ[៤៧] ។ ដូច្នេះវាជាចំណេះដឹងវិទ្យាសាស្ត្រ ដែលមានមូលដ្ឋានផ្អែកលើការគណនាមួយដែលបានមកពីការវិភាគលើទំនាក់ទំនងជាក់ស្ដែង ហើយដែលមានការទាក់ទងតិចតួចឬគ្មានសោះជាមួយបាតុភូតដែលគេចងជាក្រុមរួមគ្នាក្រោមពាក្យ «វប្បធម៌» ។ ប្រការនេះអាចនឹងបញ្ជាក់តាមហេតុការណ៍ដែលជាតិពិន្ទុពីរមានភាសាដើម ខុសគ្នាទាំងស្រុងតែមានលក្ខណៈវប្បធម៌រួមគ្នាមួយចំនួនដូចជា ចំណីអាហារ រចនាសម្ព័ន្ធសង្គម ប្រព័ន្ធគ្រួសារ ។ល។ រីឯជាតិពន្ធុពីរដែលនិយាយភាសាពីរដែលមានប្រភព ដើមតែមួយអាចនឹងឃ្លាតឆ្ងាយពីគ្នាផ្នែកវប្បធម៌ ។

ដូច្នេះយើងត្រូវបែងចែកដោយប្រុងប្រយ័ត្នជាពិសេសនៅកម្ពុជា រវាងចំណេះដឹងវិទ្យាសាស្ត្រនិងចំណេះដឹងប្រជាប្រិយ ដែលចំណេះដឹងចុងក្រោយនេះ ជាទូទៅសង្ខេបពីចក្ខុវិស័យនៃអត្តសញ្ញាណកម្មជាជាងអ្វីដែលជាតិពន្ធុមួយមានដោយខ្លួនឯងផ្ទាល់ ។

នៅទីនេះយើងមិនមានបំណងពិពណ៌នាលំអិតនោះទេ ពីព្រោះនៅកម្ពុជាការស្រាវជ្រាវក្នុងវិស័យនេះគឺស្ថិតក្នុងដំហាន ដំបូងនៅឡើយ ប៉ុន្តែយើងនឹងឱ្យឧទាហរណ៍ខ្លះៗដែលនឹងរំលេចពីភាពលំបាកនៃបញ្ហានេះ ។

## ២.១.៦.១.វិធីសាស្ត្រប្រៀបធៀបហើយដំបូងបំផុតគឺវប្បធម៌

យើងបានដាក់ចូលទៅក្នុងតារាងខាងលើនូវក្រុមនៃភាសាវៀទិកដែលរួមមានភាសាវៀតណាមក្នុងអំបូរអូស្ត្រូ អាស៊ី ។ វាមិនមែនជាការស្មាននោះទេ ពីព្រោះចំណាត់

---

[៤៧] ឫសគល់ភាសាសំដៅយកស្ថានភាសាដែលមិនបញ្ជាក់តាមសំណេរនិងមានចំណាស់ជាងគេ ហើយមានលក្ខណៈរួមទៅនឹងក្រុមនៃភាសាដែលគេបានសិក្សាហើយដែលវិធីសាស្ត្រ ប្រៀបធៀបអាចអនុញ្ញាតឱ្យបង្កើតឡើងវិញបាន ។

ប្រភេទនៃអនុក្រុមដែលភ្ជាប់ទៅនឹងអំបូរនេះត្រូវបានលើកឡើងតាំង ពីជាង១៥០ឆ្នាំមុនមកម្លេះ ហើយដែលសព្វថ្ងៃនេះ គេមានការសិក្សាវិទ្យាសាស្ត្ររឹងមាំ[៦៨] ដែលបង្ហាញពីការជាប់សន្តាននេះ ដោយមិនអាចប្រកែកបាន[៦៩] ។

ទោះជាយ៉ាងណាក៏ដោយ ភាពផ្សាភ្ជាប់ទៅនឹងអំបូរភាសានេះបន្តបង្កើតឱ្យមានការជំទាស់ដ៏សម្បើមព្រោះក្នុងគំនិត នៃមនុស្សជាច្រើន វៀតណាមត្រូវបានចាត់ទុកថាស្រដៀងគ្នាទៅនឹងភាសាចិន ។

ជំនឿនេះ អាចបកស្រាយបានតាមប្រវត្តិសាស្ត្រ២០០០ឆ្នាំ ដែលភាសាវៀត-ណាមបានខ្ចីពាក្យមួយចំនួនធំពីភាសាចិន ខាងត្បូង សំណេរចិននិងធាតុសំខាន់ៗនៃវប្បធម៌ចិន (សាសនា ការអប់រំ ។ល។) ។ ត្រង់ចំណុចនេះមានជម្លោះជារឿយៗរវាង ខ្សែស្រឡាយពិន្ទុនិងលក្ខណៈវប្បធម៌ដែលបានមកពីកម្ចី ។

ទោះជាយ៉ាងណាក៏ដោយ ក៏វានៅតែជាការលំបាកក្នុងការធ្វើឱ្យគេទទួលយកនូវការជាប់ខ្សែស្រឡាយរវាងភាសា វៀតណាម និងភាសាខ្មែរណាស់ ទោះបីជាក្នុងក្របខណ្ឌនៃមេរៀនតាមសាកលវិទ្យាល័យនានា ដោយមានភស្តុតាងជាបង្អែកក៏ដោយ ។

## ២.១.៦.២.ចំណោទស្តីពីជាតិពន្ធនាម

យើងនឹងសិក្សានៅទីនេះជាមួយឧទាហរណ៍ យកមកពីជាតិពន្ធុមួយចំនួននៃកម្ពុជានូវការលំបាកជាច្រើន ដែលយើង ជួបប្រទះជាមួយនឹងការកំណត់ឈ្មោះផ្សេងៗគ្នាដែលជាតិពន្ធនានាបានបង្កប់នៅក្នុងនោះ ។

[៦៨] សូមអាន Diffloth (Diffloth, 1989),Ferlus(Ferlus,1998) និង Haudricourt (Haudricourt, 1952,1953)

[៦៩] វាមិនមែនជាការច្បាស់លាស់ទាំងស្រុងទេ ប៉ុន្តែវាជាប្រភេទនៃបច្ចេកទេសដែលគេយកមកប្រើជាអាទិវិធីសាស្ត្រប្រៀបធៀប (Ferlus, 1996) ។

### ១.១.៦.៣.ករណីចំនួនបីស្ដីពីសាលារៀន

របៀបដែលជាតិពន្ធុមួយហៅខ្លួនគេឬដែលគេហៅជាញឹកញាប់ គឺប្រាប់ព័ត៌មានពីទំនាក់ទំនងរបស់ជាតិពន្ធុនោះទៅនឹង ជាតិពន្ធុជិតខាងរបស់គេឬជាតិពន្ធុដែលមានចំនួនភាគច្រើន។ យើងលើកយកឧទាហរណ៍បីដើម្បីរំលេចពីបាតុភូតនេះ។

#### ១.១.៦.៣.១.ភាសាស្អូច

គឺជាក្រុមជាតិពន្ធុតូចមួយស្ថិតនៅលើផ្លូវជាតិលេខបួន ក្បែរវាលរេញក្នុងភូមិសម្រោងលើ [៥០] ហើយដែលនិយាយភាសា មួយនៃក្រុមពៀរិក។ តាមធម្មតា គេស្គាល់ជាតិពន្ធុនេះក្រោមការកំណត់ហៅថា ស្អូច ឬអង់រ៉ាក់ [៥១]។

ពាក្យស្អូចត្រូវបានបដិសេធចោលដោយសមាជិកនៃជាតិពន្ធុនេះ ដែលចាត់វាទុកថាជាពាក្យខុសឬមានលក្ខណៈមើលងាយ [៥២] ហើយនៅពេលគេសួរពីឈ្មោះជាតិពន្ធុពិតប្រាកដរបស់អ្នកទាំងនោះ ពួកគេឆ្លើយជាឯកច្ឆន្ទថា ជុង ពាក្យមួយដែល អ្នកជំនាញខាងភាសាពៀរិកស្គាល់យ៉ាងច្បាស់ ព្រោះជាតិពន្ធុដទៃទៀតនៃក្រុមដូចគ្នាហៅឈ្មោះខ្លួនដូច្នេះឬស្រដៀងនេះ។

ជាងនេះទៅទៀត នៅក្នុងការសន្ទនានិងដើម្បីឱ្យយល់ច្បាស់ពីការពាក់ព័ន្ធនឹងក្រុមដែលបានសន្មតនោះ ពួកគេជាច្រើនបានប្រកាសប្រាប់យើងថា តាមពិតទៅឈ្មោះ

---

[៥០] កាលពីដើមពួកគេរស់នៅក្នុងភូមិដែលត្រូវបានបោះបង់ចោលតាំងពីសម័យសង្គ្រាមហើយស្ថិតនៅម្ដុំវាលទំនាបព្រៃនប់។

[៥១] ពាក្យនេះដែលគេជួបប្រទះនៅក្នុងអត្ថបទជាច្រើនឬនៅក្នុងផែនទីជាតិពន្ធុភាសាវិទ្យា (Headley, 1977, 1978) ហាក់ដូចជាគ្មានន័យទេ ព្រោះយើងមិនដែលឮនរណាម្នាក់ប្រើវាទេ។ លើសពីនេះទៅទៀត ទោះជាសមាជិកជាតិពន្ធុស្គាល់ពាក្យថា «ស្អូច» ក៏ដោយ ហើយទន្ទឹមនឹងនោះ ពួកគេក៏បដិសេធមិនទទួលស្គាល់ពាក្យនេះដែរ គ្មានអ្នកផ្ដល់ព័ត៌មានណាម្នាក់ដែលយើងបានសួរនិយាយថាធ្លាប់ឮពាក្យ «ជាតិពន្ធុអង់រ៉ាក់» ទេ។

[៥២] ប្រហែលមកពីមូលហេតុពាក្យ *ស្អូច* ជាភាសាខ្មែរមានន័យថា *ជំងឺស្អូច* (Headley, 1977)។

ពិតប្រាកដរបស់ពួកគេគឺ «ខ្មែរដើម[៥៣]» ។ ផ្អែកលើនិក្ខេបនេះ គេពន្យល់ថា ភាសារបស់ពួកគេមានប្រភពមកពីសំស្ក្រឹតផ្ទាល់តែម្តង ហើយថា ពួកគេយល់យ៉ាងច្បាស់នូវការសូត្រធម៌ជាភាសាបាលីរបស់ ព្រះសង្ឃនៅវត្តជិតខាង[៥៤] ។

រឿងនិទានដែលគួរឱ្យចង់សើច ហាក់ដូចជាស្តែងប្រាប់យើងពីគ្រប់ទិដ្ឋភាពនៃការបង្កើតឈ្មោះជាតិពន្ធុ ហើយម្យ៉ាង ទៀត វាបានបង្ហាញពីផលប្រយោជន៍សង្គមភាសាវិទ្យាដែលសក្តិសមនឹងធ្វើការសិក្សាស៊ីជម្រៅ ឬអាចរហូតដល់ការបង្កើតវចនានុក្រមឈ្មោះជាតិពន្ធុនៃជនជាតិភាគតិចនៅកម្ពុជា ។

### ២.១.៦.៣.២.ជ្វាពាក្យជ្វា

ពាក្យជ្វាដែលត្រូវនឹងពាក្យ *java* សំដៅដល់ក្រុមមួយនៃប្រជាជនកម្ពុជាកាន់សាសនាអ៊ីស្លាមដែលដូចជាមិនមាន ភាសាផ្ទាល់របស់ខ្លួននោះទេ ហើយដែលប្រើភាសាខ្មែរជាមធ្យោបាយប្រាស្រ័យទាក់ទងគ្នា ។

គេច្រើនជួបប្រទះជនជាតិប្រភេទនេះ ជាពិសេសនៅតំបន់កំពត និងនៅជាយក្រុងភ្នំពេញ ។

ដើមកំណើតរបស់គេគឺងងិតសូន្យសុង ពីព្រោះឈ្មោះជាតិពន្ធុរបស់គេប្រហែលជាមកពីភាសាអារ៉ាប់ «Jawa» ដែល សំដៅទៅកោះ Java ផងនិងកោះស៊ូម៉ាត្រាផង (Collins, 1996) ។

ពួកគេរស់នៅក្នុងភូមិរបស់គេផ្ទាល់ ហើយគេចេញពីភូមិខ្មែរដោយសារតែវត្តមាននៃសាច់ជ្រូក ហើយក៏ចៀសវាងភូមិចាមផងដែរ ព្រោះគេមិនចេះភាសានេះ (Collins, 1996) ។

---

[៥៣] ទោះបីពួកគេមិនមានជាប់ពាក់ព័ន្ធជាមួយខ្សែស្រឡាយខ្មែរក៏ដោយ លើកលែងតែរាប់ពាន់ឆ្នាំមុន ។

[៥៤] ពួកគេកាន់សាសនាអាណាម ។

យើងនឹងមិនរំឭកពីពួកគេទៀតទេ ពីព្រោះពួកគេមិនមានភាសាផ្ទាល់ខ្លួន ហើយការសិក្សានាពេលនេះ ផ្តោតចំណាប់ អារម្មណ៍ទៅលើជាតិពន្ធុភាសាវិទ្យាជាចម្បង ។

នៅក្នុងសហគមន៍ចាមនៃកម្ពុជា ការបែងចែកជាក្រុមឱ្យច្បាស់ជាច្រើនអាចធ្វើទៅបាន[៥៥] ប៉ុន្តែ យើងនឹងប្រកាន់យក មួយដែលផ្តោតលើលក្ខណៈវិនិច្ឆ័យសាសនា។ មានចាមពីរក្រុមធំៗ :

- ក្រុមភាគច្រើនកាន់សាសនាអ៊ីស្លាមអ័រតូដូកស៍ ដែលមានជាអាទិ៍ការប្រតិបត្តិធម៌ប្រាំដងក្នុងមួយថ្ងៃ ការប្រើតួអក្សរ jawi ដែលប្រើសម្រាប់សរសេរភាសាចាម និងម៉ាឡេ[៥៦] ។ល។

- ក្រុមភាគតិច (១០ %នៃជនជាតិចាមទាំងមូល) ដែលគេចាត់ទុកជាចាមភ្ញឺឬចាមធម្មតា [៥៧] ដែលមានលក្ខណៈសំគាល់តាមរយៈចក្ខុវិស័យមួយផ្សេងអំពីការប្រតិបត្តិសាសនា : សូត្រធម៌ម្តងនៅថ្ងៃសុក្រ ការតមអាហារ រ៉ាម៉ាដង់ ប្រតិបត្តដោយ បរិស័ទតែប៉ុណ្ណោះ លទ្ធភាពអាចធ្វើធម្មយាត្រាបង្គ្រប់កិច្ចឆ្ពោះទៅកាន់ឡា ម៉ិក ដោយបន្ថែមនូវទំនៀមទំលាប់ បុរេអ៊ីស្លាម ដែលជាទូទៅមានប្រភពដើមពីសាសនាហិណ្ឌូបញ្ចូលទៅក្នុងសាសនាអ៊ីស្លាមរបស់គេ និងការប្រើប្រាស់សំណេរមានប្រភពមក ពីឥណ្ឌាដើម្បីសរសេរភាសារបស់គេ ។

[៥៥] គេឃើញមានការរាប់ឈ្មោះក្រុម និងការវិភាគនៅក្នុង Collins (Collins, 1996) ។

[៥៦] ដោយមិនមែនជាអ្នកនិយាយភាសាម៉ាឡេពីកំណើត ពួកគេអនុម័តយកភាសានេះជាភាសាក្នុងការអប់រំ ។

[៥៧] ការពិព័ណ៌នាលម្អិតពីទំនៀមទំលាប់និងការយល់ឃើញពីអ៊ីស្លាមរបស់គេ មាននៅក្នុងស្នាដៃរបស់ Agnès de Féo: L'Islam de l'Imam San, les soufis du Cambodge ។

ភាសានិយាយរបស់ចាមអ៊័រតូដូកស៍ និងចាមធម្មតាអាចទុកដូចជាគ្រាមភាសាពីរនៃភាសាតែមួយ[៥៨] ហើយគ្មានអ្វីរំខានជាដុំកំភួនដល់ការយល់គ្នានោះទេ។ សហគមន៍ទាំងពីរមិនដែលសេពគប់គ្នាទាល់តែសោះ លើកលែងតែក្នុងពេលផ្សព្វផ្សាយ មនោគមន៍សាសនាដែលធ្វើឡើងដោយពួកចាមអ៊័រតូដូកស៍ ។

មិនគ្រាន់តែសហគមន៍ភាសាមិនជំរុញអោយមានការពិចារណាអំពីអត្តសញ្ញាណប៉ុណ្ណោះទេ ប៉ុន្តែ ចាមធម្មតាមិនត្រូវ បានគេហៅថា «ចាម» ទៀតផង ហើយត្រូវបានពួកចាមអ៊័រតូដូកស៍ចាត់ទុកថាជា « ជ្វា » ។ ពាក្យ « ជ្វា » នៅទីនេះមាន ន័យជាពាក្យប្រមាថដែលស្មើនឹងភាពមិនស្មោះ ។

ដោយមិនបរិយាយវែងឆ្ងាយពីប្រធានបទនេះ ព្រោះវាមិនមែនជាប្រធានបទសំខាន់របស់យើនោះ យើងអាចកត់ សម្គាល់ថា សហគមន៍ភាសាមិនប្រាប់ពីអ្វីដែលជាការជាប់ទាក់ទងនឹងវប្បធម៌ទេ ហើយការប្រើប្រាស់ពាក្យ ជ្វា ត្រូវបានបង្ខំ ដោយពួកចាមអ៊័រតូដូកស៍ទៅលើជនរួមជាតិរបស់គេ ដែលពួកជ្វាពិតប្រាកដក្នុងមជ្ឈដ្ឋានទីក្រុងក្បែរខាងជាមួយចាម[៥៩] បាន ពេញចិត្តនឹងការហៅខ្លួនគេថា «ចាវ៉ា»[៦០] ។

### ២.១.៦.៣.៣.ពាក្យថា ព្នង

ពាក្យថា ព្នង ត្រូវបានប្រើប្រាស់សម្រាប់ហៅជាតិពន្ធុភាគច្រើនក្នុងខេត្តមណ្ឌលគីរី(៩០%នៃប្រជាជនក្នុងខេត្ត)ពោល គឺជាតិពន្ធុមួយដែលនិយាយភាសាមួយ

---

[៥៨] យើងបានធ្វើការផ្ទៀងផ្ទាត់ពីរឿងនេះដោយផ្ទាល់តែម្តង ។

[៥៩] យើងបានផ្ទៀងផ្ទាត់ជាច្រើនសារមកហើយ ។

[៦០] ពាក្យដែលតាមពិតមានប្រភពមកពី ជ្វា។ កម្លាយសូរដែលអាចឱ្យឆ្លងពីពាក្យមួយទៅពាក្យមួយទៀតគឺមានលក្ខណៈទៀងទាត់នៅក្នុងភាសាខ្មែរ ។

ក្នុងអំបូរអូស្ត្រូ-អាស៊ី ក្រុមបាណារិក អនុក្រុមបាណារិកខាងត្បូង[៦១] ។ ដើមកំណើតនៃជាតិពន្ធុនាមនេះ ដែលមានការប្រើប្រាស់ជាទូទៅនោះ គឺជាការបែកចេញពីពាក្យ ប៊ូនង បកប្រែឱ្យចំគឺ ប៊ូ = មនុស្ស ហើយ នង=ក្រុមជាតិពន្ធុមួយ ហេតុនេះ មានន័យថាមនុស្សនងឬប្រជាជននង ។

ដោយហេតុផលប្រវត្តិសាស្ត្រដែលប្រហែលជាមកពីភាពជិតគ្នាយ៉ាងខ្លាំងរវាងជាតិពន្ធុខ្មែរនិងព្នង[៦២] រវាងខ្មែរនិងជាតិ ពន្ធុផ្សេងទៀតនៃខ្ពង់រាបលើពាក្យ ព្នង ត្រូវបានប្រើក្នុងភាសាខ្មែរដើម្បីស្តែងពីប្រជាជនទាំងឡាយណាដែលមានលក្ខណៈជាមនុស្សព្រៃ[៦៣] ហើយសព្វថ្ងៃ ពាក្យនេះប្រើជារួមសម្រាប់ប្រមាថខ្មែរគ្នាឯង ។

### ២.១.៦.៤.ការជាប់ទាក់ទងជាតិពន្ធុភាសាវិទ្យានិងសង្គម

យើងមានចំណាប់អារម្មណ៍ទៅលើករណីពីរ ម្យ៉ាងទៅលើបាតុភូតកន្ទ្រាញ ហើយម្យ៉ាងទៀតទៅលើចំណោទនៃជាតិ ពន្ធុនាមនៅក្នុងទំនាក់ទំនងជាមួយគ្រាមភាសាវិទ្យា ។

### ២.១.៦.៤.១.បាតុភូតកន្ទ្រាញ

ករណីដែលស្តែងឡើងច្បាស់ គឺករណីពួកកាចូនៅខេត្តរតនគិរី [៦៤] ។ ជាតិពន្ធុនេះហៅខ្លួនឯងនិងត្រូវបានគេហៅតាម រយៈជាតិពន្ធុនាមទីពីរថា «ឡាម៉ាម» ។

---

[៦១] ដើម្បីឱ្យជាក់ច្បាស់គួរតែនិយាយពីក្រុមភាសាមួយដែលព្នងជាផ្នែកមួយនៃភាសានេះ ភាសាទាំងនេះមាននិយាយនៅកម្ពុជានិងនៅវៀតណាមជាពិសេសខេត្តដាឡាត់ ។

[៦២] ហេតុការណ៍ពីរសម្រាប់ជាចន្លល់នៃអំពោះអំណោងនេះ : ១- ភូមិជាច្រើនចន្លោះមេគង្គនិងខេត្តមណ្ឌលគិរីជាភូមិចាស់របស់ព្នង ។ ២-ការប្រព្រឹត្តទាសភាព : ភូមិខ្មែរជាច្រើននៅក្នុង ខេត្តក្រចេះមានទាសករព្នង នេះបើតាមការចងចាំរបស់មនុស្ស ។

[៦៣] លក្ខណៈនេះគួរសិក្សាបន្ថែមដោយប្រៀបធៀបទៅនឹងនិយមន័យខ្មែរ : គ្មានសំណេរ ការដាំដំណាំលើចំការដុត គ្មានរដ្ឋអំណាច ។ល ។

[៦៤] គេហៅកាន់ចូផងដែរ ។

តាមការ ពិត គឺជាការបែកចេញពីពាក្យសម្រាប់ហៅកន្ទ្រាញ ចារ៉ាយ[៦៥] ដែលពួក កាចូ ខ្លះត្រូវ បានរាប់បញ្ចូលទៅក្នុងនោះ តាមរបៀបដូចភាសាទំពួនដែរ ។

គេអាចដឹងពីវត្តមាននៃជាតិពន្ធនាមមួយ ដែលភ្ជាប់សមាជិនៃជាតិពន្ធុពីរក្នុង អំបូរអូស្ត្រូអាស៊ីទៅនឹងជាតិពន្ធុក្នុងអំបូរ អូស្ត្រូណេស៊ី ។

### ២.១.៦.៤.២.គ្រាមភាសាវិទ្យានិងជាតិពន្ធនាម

នៅមានទិដ្ឋភាពមួយទៀតនៃជាតិពន្ធុនាមកម្មដែលច្រើនតែគេរំឭកឡើងតែមិន សូវសិក្សា ហើយដែលស្ថិតនៅក្នុង សេចក្ដីសង្ខេបចេញពីភាពផ្ទុយគ្នារវាងភាពបម្រែ បម្រួលផ្នែកជាតិពន្ធុនាមដ៏ធំធេង និងទិន្នន័យភាសាដែលអ្នកស្រាវជ្រាវរក បានហើយ ដែលអនុញ្ញាតឱ្យសន្និដ្ឋានថាមានតែគ្រាមភាសានានា ប៉ុន្តែ មិនមែនជាភាសាខុសៗគ្នា នោះទេ ។

ករណីនៃភាសាប្រាវដែលនិយាយនៅខេត្តរតនគីរីហាក់ដូចជាតំណាងឱ្យស្ថាន ភាពនេះណាស់ ។ នៅលើផែនទីជាតិពន្ធុ ភាសាវិទ្យានៃវើនសៃ (Bitard, 1964) គេឃើញផ្នែកប្រាវ-គ្រឹងចែកដាច់ពីផ្នែកក្រវែតរហូតដល់អ្នកនិពន្ធផ្ដល់នូវការតាង ភូមិសាស្ត្រនៃប្រជុំកោះប្រាវតូចៗក្នុងទឹកដីក្រវែតទៀតផង ប៉ុន្តែ វាដូចជាមិនមែន ជាភាសាពីរផ្សេងគ្នានោះទេ ។ នៅលើ ផែនទីរបស់វិទ្យាស្ថានអន្តរជាតិភាសាវិទ្យា[៦៦]

[៦៥] រចនាសម្ព័ន្ធគ្រួសារផ្នែកលើកន្ទ្រាញដែលឈ្មោះបន្តវេនត្រូវផ្ដល់ដោយស្ត្រីខ្សែលោហិតខាងម្ដាយ ។ ក៏ប៉ុន្តែគេពុំឃើញមាន ឯកភាពរវាងសមាជិកនៃក្រុមតែមួយទេ ទោះបីជាគេទាមទារ ថា មានដូនតារួមក៏ដោយ ។ ការជាប់ទាក់ទងទៅនឹងកន្ទ្រាញ ស្ដែងចេញតាមរយៈវិន័យហាមឃាត់ (ទំនាក់ទំនងផ្លូវភេទ អាពាហ៍ពិពាហ៍ តមម្ហូបអាហារ) ប៉ុន្តែ មិនតម្រូវឱ្យមានកាតព្វកិច្ច ដល់សមាជិកណាម្នាក់ចំពោះសមាជិកណាផ្សេងទៀតទេ ។ មានតែត្រឹមកម្រិតក្រោមប៉ុណ្ណោះ ដែលគេឃើញត្រកូលរួម និងឯកភាពគ្រួសារ (Lafont, 1963)

[៦៦] ពាក្យពេញរបស់វិទ្យាស្ថាននេះជាភាសាអង់គ្លេសគឺ Summer Institute of Linguistics ។

ដែលមាននៅក្នុងអ៊ិនធឺណែត ហើយប្រហែលជាធ្វើឡើងនៅប៉ុន្មានឆ្នាំចុង ក្រោយនេះ ទោះបីជាគ្មានកាលបរិច្ឆេទច្បាស់លាស់ក៏ដោយ គឺមានការបែកចែករវាងភាសាប្រាវ គ្រឹង និងក្រាវែត ។

ប៉ុន្តែវិទ្យាស្ថានដដែលនេះ បានបោះពុម្ពនៅខែមិនាឆ្នាំ២០០០ នូវឯកសារមួយ ដែលបង្ហាញពីបម្រែបម្រួលភាពនៃគ្រាម ភាសារវាងពាក្យចំនួន ២៨៣ ដែលបាន ពិនិត្យនិងកត់ចម្លងពីភាសានិយាយដូចតទៅ : គ្រឹង អូជុំ ប្រាវ តាណោប់ លុន តាវែង កាវែត អូដ្រាក ប្រាវ ខាំប៉ា ឡាវែន ( អាតូប៉ឺ ) ។ សេចក្តីសន្និដ្ឋានដែលទាញបានពីការ ពិនិត្យឯកសារនោះគឺយើង ឃើញភាពបម្រែបម្រួលនៃភាសាទាំងនេះ ភាសាច្រើនគឺ ដូចគ្នាឬប្រហាក់ប្រហែលគ្នា ហើយឈ្មោះដែលប្រើហាក់ដូចជាគ្មានអ្វី ក្រៅពីបម្រែ បម្រួលភាពគ្រាមភាសានោះទេ ។

ដោយកង្វះការស្រាវជ្រាវស៊ីជម្រៅ វាពិបាកនឹងអារកាត់ទៅលើហេតុផល ជ្រៅជ្រះនៃបម្រែបម្រួលភាពផ្នែកជាតិពន្ធុ នាមណាស់ : ភាពខ្វែងគ្នានៃរចនាសម្ព័ន្ធ សង្គម ឥទ្ធិពលនៃទិដ្ឋភាពភូមិសាស្ត្រពិសេស ការគ្មានអត្តសញ្ញាណរដ្ឋបាលខ្ពស់ជាង ថ្នាក់ភូមិ ផលវិបាកនៃនយោបាយក្នុងសម័យខ្មែរក្រហម ។ល។ ប៉ុន្តែ នៅតែមានចំនុច មួយ : ការផ្តាច់ចេញពីគ្នារវាងចំណាត់ ប្រភេទភាសា ដែលផ្តោតទៅលើវិធីសាស្ត្រ ប្រៀបធៀបនិងប្រភេទនៃជាតិពន្ធុ ។

សរុបសេចក្តីមកគេគួរតែប្រកាន់យកការសិក្សាអំពីប្រភេទភាសា ។ មានតែការ សិក្សាចុងក្រោយនេះតែមួយគត់ ដែលអាចឱ្យមានវិធីសិក្សាជាសត្យានុម័តស្តីពី ចំណាត់ប្រភេទដោយសារតែវិធីសាស្ត្រដែលគេបានយកមកអនុវត្តរួចហើយ ។

ក្រៅពីចំណាត់ប្រភេទ ដែលមានមូលដ្ឋាននៅលើវិធីសិក្សាសេនេទិចនៃភាសា ហើយដែលភាសាវិទ្យាប្រៀបធៀបអាច ឱ្យបង្កើតឡើងនោះ ការវិលទៅរកការសិក្សាអំពីប្រភេទភាសា ឧទាហរណ៍ដូចជា ជាតិពន្ធុនាមកម្ម គឺមិនមែនឥតប្រយោជន៍នោះទេ ប៉ុន្តែ បានផ្តល់ព័ត៌មានអំពីចិត្តសាស្ត្រសង្គមដ៏សំខាន់សម្រាប់ជាតិពិន្ទុវិទូ និងសង្គមភាសាវិទូ ។

យើងគ្រាន់តែអាចផ្តល់ជូនអនុសាសន៍ អោយធ្វើការសិក្សាដោយឡែកមួយស្តីពីជាតិពន្ធុនាមទាំងនេះ ហើយប្រវត្តិសាស្ត្ររបស់ពួកគេនឹងធ្វើឱ្យទិន្នន័យប្រវត្តិសាស្ត្រដែលយើងមានស្រាប់ហើយកាន់តែសម្បូរថែមទៀត ព្រមទាំងការបង្កើត វចនានុក្រមពិស្តារមួយ ។

## ២.២.ភូមិសាស្ត្រភាសាវិទ្យា

### ២.២.១.ប្រជាជន : បញ្ហានៃការប្រមូលសម្ភារៈនិងលទ្ធផលបឋម

នាពេលបច្ចុប្បន្ន វាពិបាកនឹងមានចក្ខុវិស័យច្បាស់លាស់ណាស់អំពីប្រជាសាស្ត្រនៃជនជាតិដើមភាគតិចនៅកម្ពុជា ព្រោះតួលេខខុសគ្នាច្រើនណាស់ ហើយការកំណត់ឈ្មោះក៏ចោទជាបញ្ហា : ទន្ទឹមនឹងជនជាតិភាគតិចដែលនៅមានជីវិតប្រភព មួយចំនួនដែលស្រង់ចេញពីអ៊ីនធឺណែតមិនញញើតនឹងនិយាយអំពីជនជាតិភាគតិចដែលបាត់បង់ពីកម្ពុជានាពេលសព្វថ្ងៃនេះ ទៅហើយ ។ ឧទាហរណ៍ ជនជាតិកូឡា នៅប៉ៃលិនបែរជាថាជនជាតិភូមា[៦៧] ប្រភពខ្លះទៀត មានកំហុសធ្ងន់ធ្ងរក្នុងការធ្វើ ចំណាត់

---

[៦៧] ជនជាតិភាគតិចប្រភេទនេះពិតជាមានវត្តមាននៅកម្ពុជាមែនមុនសង្គ្រាម ហើយប្រមូលផ្តុំគ្នារស់នៅប៉ៃលិននិងជាអ្នកជំនាញខាងថ្មត្បូង ទទឹមនិងកណ្តៀង ។ ផ្ទុយទៅវិញភាសារបស់ ពួកគេមិនមែនជាភាសាភូមាទេ ប៉ុន្តែ ជាភាសាសានដែលស្ថិតនៅក្នុងអំបូរតៃកាដាយ ។

អំបូរភាសាដោយបានដាក់ភាសាកួយ (អូស្ត្រូអាស៊ី, កាទូអ៊ិក) ទៅក្នុងចំណោមភាសាដ្រាវីឌៀន[៦៨] ហើយចំណាត់ ប្រភេទមួយចំនួនទៀត បានកំណត់ឈ្មោះអំបូរភាសាដែលអំណើះតទៅគួរប្រុងប្រយ័ត្ន (អូស្ត្រូតៃ)។

ជួនកាល តួលេខបង្ហាញពីគម្លាតដ៏គួឱ្យភ្ញាក់ផ្អើល។ ប្រសិនបើយើងប្រៀបធៀបតួលេខរបស់អង្គការ Ethnologue និង តួលេខរបស់ Center for Advanced Studies (វិទ្យាស្ថានសិក្សាជាន់ខ្ពស់) ចំពោះជនជាតិភាគតិចស្ទួច យើងទទួលបានរៀងគ្នានូវតួលេខ២០០០និង១៧៥។ បើប្រៀបធៀបតួលេខនៃវិទ្យាស្ថានសិក្សាជាន់ខ្ពស់និងតួលេខរបស់ Ethnic Cambodia (ជាតិពន្ធុកម្ពុជា) ចំពោះជនជាតិទំពួន យើងទទួលបានរៀងគ្នាគឺ ១៨ ០០០ និង ២៥ ០០០ ។ល។ សំណួរបន្ថែមមួយដើម្បី ឱ្យដឹងថាតើភាសាមួយមានចំនួនអ្នកនិយាយប៉ុន្មាននាក់នោះ បានក្លាយទៅជារឿងមួយស្ទើរតែហួសពីការពិត។

រីឯជំរឿនវិញ វាផ្អែកតែទៅលើការប្រកាសប្រាប់របស់អ្នកដែលយើងបានសួរតែប៉ុណ្ណោះ ហើយដែលជួនកាល ដោយហេតុផលកិត្យានុភាពឬដើម្បីចៀសវាងភាពនៅក្រៅសង្គមគេក៏ប្រកាសថាខ្លួនជាខ្មែរ[៦៩]។

---

[៦៨] ទោះណាជាមានភាសាដ្រាវីឌៀនដែលគេហៅថា កួយ ហើយមាននិយាយនៅភាគខាងត្បូងនៃប្រទេសឥណ្ឌាក៏ពិតមែនប៉ុន្តែវាគ្រាន់តែជារឿងចៃដន្យតែប៉ុណ្ណោះ។

[៦៩] គេអាចកត់សម្គាល់នូវបម្រែបម្រួលភាពដ៏សម្បើមនៅក្នុងតួលេខផ្លូវការជាក់ស្តែងតួលេខរបស់នាយកដ្ឋានជនជាតិដើមភាគតិចនៃក្រសួងធម្មការនិងសាសនាដែលបញ្ជាក់ថានៅកម្ពុជា ក្នុងឆ្នាំ១៩៩២ មានជនជាតិដើមភាគតិចចំនួន៣០៩ ០០០នាក់ ដែលស្មើនឹង៣.៥% នៃប្រជាជន រីឯតួលេខដែលទទួល តាមជំរឿនក្នុងឆ្នាំ១៩៩៧មានតែ១០ ១០០០នាក់ដែលស្មើនឹង០.៩% នៃប្រជាជន។

បញ្ហានៃទីតាំងក៏ជាចំណោទមួយដែរ ហើយទោះជាមានផែនទីជាតិពន្ធុភាសាវិទ្យាដ៏មានគុណភាពសម្រាប់តំបន់មួយ ចំនួននៃប្រទេសក៏ដោយ ក៏ផែនទីទាំងនោះលែងមានបច្ចុប្បន្នភាពទៀតហើយ ។ យើងសូមផ្តល់ជាឧទាហរណ៍លើជាតិពន្ធុកួយដែលរស់នៅភាគឦសាននៃប្រទេសកម្ពុជា ក្នុងខេត្តកំពង់ធំនិងព្រះវិហារ ។ ទោះជាមានភូមិកួយសុទ្ធសាធមួយ ដូចជាភូមិ ស្វាយដំណាក់ (ស្រុករវៀង) ក៏ដោយ ក៏សព្វថ្ងៃនេះ ប្រជាជនកួយមួយភាគធំរស់នៅក្នុងភូមិដែលមានប្រជាជនលាយឡំគ្នា ដែលប្រការនេះ ធ្វើឱ្យភារកិច្ចអ្នកស្រង់ព័ត៌មានមានការលំបាកយ៉ាងខ្លាំង ។

នៅថ្ងៃអនាគត ដំណោះស្រាយដ៏លំបាកមួយ ប៉ុន្តែអាចប្រកាន់យកបាននោះគឺការស្រង់ពីភូមិទៅភូមិមួយ ។

តួលេខដែលយើងផ្តល់ក្នុងពេលនេះ ចំពោះភាសាទាំងអស់ដែលយើងសិក្សានោះគឺបានមកពីស្ថិតិក្នុងស្រុក ដែលជា រឿយៗគ្មានការបោះផ្សាយ និងពីស្ថិតិជាតិ និងការប៉ាន់ប្រមាណផ្ទាល់[៧០]ខ្លួនផងដែរ ។

តារាងខាងក្រោមបានមកពីការគណនា ដែលឈរលើទំនាក់ទំនងរវាងការប៉ាន់ប្រមាណផ្សេងៗ និងអ្វីដែលយើងបាន ដោយផ្ទាល់ខ្លួន[៧១] ។

---

[៧០] ក្នុងចំណោមជនជាតិដើមភាគតិចទាំងអស់ ការប៉ាន់ប្រមាណនៃប្រជាជនចិនចោទជាបញ្ហាសម្បើមជាងគេ : «In fact, ethnic Chinese were a significant minority group before the Khmer Rouge era, and Chinese immigration to Cambodia dates back as far as the Angkor period. The current official population is estimated at a little over 200,000, more than half of whom reside in Phnom Penh. Independent observers suggest a total of at least 300,000 56». (Pen Dareth, 1996).

[៧១] យើងផ្តល់តែតួលេខគត់ប៉ុណ្ណោះ ។ យោងតាមស្ថានភាពដែលយើងដឹងនាពេលបច្ចុប្បន្ន វាពិបាកមានចម្បាស់ភាពណាស់ ។ យើងនឹងយកទិន្នន័យនេះទៅប្រើម្តងទៀតនៅក្នុងផ្នែកផែនទី ប្រជាសាស្ត្រ ។ យើងបង្ហាញថានៅពេលនេះគឺមានគោលបំណងសម្រួលដល់ការអានអត្ថបទនិងមិនមែនបង្កើតឱ្យមានភាពច្រំដែលនោះទេ ។

| ជាតិពន្ធុនាម | ភាសា | គ្រួសារ | មែកធាង | ក្រុម | អនុក្រុម | ប្រជាជន |
|---|---|---|---|---|---|---|
| ចារ៉ាយ | ចារ៉ាយ | អូស្ត្រូអាស៊ី | ម៉ាឡាយូប៉ូលីណេស៊ី | ចាមិក | ចាមិកខ្ពង់រាបលើ | ២០ ០០០ |
| ចាម | ចាម | អូស្ត្រូអាស៊ី | ម៉ាឡាយូប៉ូលីណេស៊ី | ចាមិក | ចាមខាងលិច | ២៤០ ០០០ |
| ឡាវ | ឡាវ | អូស្ត្រូអាស៊ី | កាំតៃ | តៃ សេក | តៃ និរតី | ២២ ០០០ |
| វៀតណាម | វៀតណាម | អូស្ត្រូអាស៊ី | ខាងកើត | វៀតិក | វៀតមុង | ៤៥០ ០០[៧២] |
| កាចូ/កាន់ចូ ឡាម៉ាម | កាចូ | អូស្ត្រូអាស៊ី | ខាងកើត | បាណារិក | បាណារិកខាងជើង | ១៣០០ |
| ប្រាវ/គ្រឹង/លុន/ក្រវៃត | ប្រាវ | អូស្ត្រូអាស៊ី | ខាងកើត | បាណារិក | បាណារិកខាងលិច | ២៣ ៨០០ |
| ទំពួន | ទំពួន | អូស្ត្រូអាស៊ី | ខាងកើត | បាណារិក | បាណារិកកណ្ដាល | ២៤ ០០០ |
| ព្នង | ព្នង | អូស្ត្រូអាស៊ី | ខាងកើត | បាណារិក | បាណារិកខាងត្បូង | ២០ ០០០ |
| ស្មៀង | ស្មៀង | អូស្ត្រូអាស៊ី | ខាងកើត | បាណារិក | បាណារិកខាងត្បូង | ៤ ០០០ |
| កួយ | កួយ | អូស្ត្រូអាស៊ី | ខាងកើត | កាទូអ៊ិក | កាទូអ៊ិកខាង លិច | ៣០ ០០០ |
| សំរែ | សំរែ | អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ពៀរិកខាងលិច | ៣០០ |
| សំរ៉ៃ | សំរ៉ៃ | អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ពៀរិកខាងកើត | ៤០០ |
| ស្អូច/ជុង | ជុង | អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ពៀរវាលវេញ | ១៥០ |
| ព័រ | ព័រ | អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ព័រកំពង់ធំ[៧៣] | ៣០០ |
| ស្អូយ/ស្អូង | ស្អូយ | អូស្ត្រូអាស៊ី | ខាងកើត | ពៀរិក | ព័រកំពង់ស្ពឺ | ៥០០ |

[៧២] ចំនួនប្រជាជនវៀតណាមនៅកម្ពុជាគឺមិនសូវច្បាស់លាស់ទេ ហើយប្រែប្រួលពីមួយទៅបីដង។ ទិន្នន័យជាតួលេខនៅក្នុងឯកសារ «Ehnologue» : ៣៩៣ ១២១នាក់ ហាក់ដូចជា ចាស់បន្តិចហើយ។ ហេតុនេះយើងផ្អែកលើតួលេខនៃប្រភពរដ្ឋាភិបាលកម្ពុជាវិញ : ៤៥០ ០០០នាក់។ ម្យ៉ាងទៀតយើងបានរកឃើញតួលេខដល់ ទៅ ១ ០០០ ០០០ ទៀតផងនៅក្នុងឯកសារផ្សេង។

[៧៣] ទោះជាឈ្មោះដូច្នេះក៏ដោយ ជនជាតិព័ររស់នៅក្នុងភូមិចំនួនបីដែលស្ថិតនៅខេត្តព្រះវិហារ។ ហេតុផលគឺថាទឹកដីនៅខេត្តព្រះវិហារបច្ចុប្បន្នដែលទើបបង្កើតថ្មីជាអតីតផ្នែកមួយនៃខេត្ត កំពង់ធំក្នុងសម័យអាណាព្យាបាលបារាំង។

| | | | | | | |
|---|---|---|---|---|---|---|
| ទាជីវ | ទាជីវ | ស៊ីណូទីបេតាំង | ចិន | មិនខាងត្បូង | ទាជីវ | ១៨១ ០០០ |
| កន្ទាំង | កន្ទាំង | ស៊ីណូទីបេតាំង | ចិន | យ៉េ | កន្ទាំង | ១០ ០០០ |
| ហៃណាំ | ហៃណាំ | ស៊ីណូទីបេតាំង | ចិន | មិនខាងត្បូង | ហៃណាំ | ១៣ ០០០ |
| ខិ | ខិ | ស៊ីណូទីបេតាំង | ចិន | ខិ | ម៉ីសាន | ៨០ ០០០ |
| កុកងឺ | ការហៅឈ្មោះផ្សេងៗគ្នា[៧៤] | ស៊ីណូទីបេតាំង | ចិន | កុកងឺ | ត្បូង | ២ ០០០ |
| ហុកគៀន | ហុកគៀន | ស៊ីណូទីបេតាំង | ចិន | មិនខាងត្បូង | អាមួយ | ៥ ០០០ |

## ២.២.២.ទីតាំងជនជាតិភាគតិចនៅកម្ពុជា

យើងអាចកំណត់ទីតាំងជនជាតិភាគតិចមួយចំនួន នៅលើផែនទីបានភ្លាមៗ ពោលគឺ សុទ្ធសឹងជាជនជាតិភាគតិច «ប្រូតូឥណ្ឌូចិន» នៃគ្រួសារអូស្ត្រូអាស៊ី និងអូស្ត្រូណេស៊ីដែលរស់នៅតាំងពីរាប់សតវត្សមកហើយ រហូតដល់រាប់សហសវត្ស ទៀតផង នៅលើទឹកដីដដែលដោយគ្មានការប្រែប្រួលធំដុំឡើយ។ ទឹកដីនោះស្ថិតនៅជិតទឹកដីកម្ពុជាបច្ចុប្បន្ន ក្នុងទិសឦសាន ទិសពាយព្យ និងនៅតាមជួរភ្នំក្រវាញ។

[៧៤] គេឃើញមានប្រជាជនដែលបានតាំងទីលំនៅនៅកម្ពុជាអស់កាលដ៏យូរមកហើយ គឺក្នុងទសវត្សឆ្នាំ៦០ ហើយនិយាយគ្រាមភាសាខាងត្បូង( ហឺណាន់និងហ៊ូណាន់) នៃចិនកុកងឺ។

យើងអាចបញ្ជាក់ប្រាប់ពីជនជាតិភាគតិចដែលមិនប្រែប្រួលផងដែរ ដូចជាស្ទួយនៅកំពង់ស្ពឺ ស្ទួចនៅវាលវេញ។ល។ និងមានប្រជាជនមួយចំនួនតូចរស់នៅផ្នែកកណ្ដាលនៃប្រទេស។

ប្រឈមទៅនឹងការប្រមូលផ្ដុំនេះ ជនជាតិភាគតិចមួយចំនួនមិនអាចកំណត់ទីតាំងនៅលើផែនទីកម្ពុជាបច្ចុប្បន្នបានទេ ព្រោះគេរស់នៅបែកខ្ញែកពេកឬតាមរបៀនប្រជាជនចិនដែលរស់នៅប្រមូលផ្ដុំក្នុងទីក្រុង។

ភាពផ្ទុយនៃទីក្រុង /ជនបទ មានសារប្រយោជន៍តិចតួចណាស់នៅទីនេះ ព្រោះជនជាតិភាគតិចចិននិយាយភាសាទាជីវ ដែលជាក្រុមសំខាន់ជាងគេក្នុងចំណោមជនជាតិចិននៅកម្ពុជានោះ ក៏មានវត្តមាននៅតាមជនបទពាសពេញផ្ទៃប្រទេសរហូតដល់ថ្នាក់ភូមិទៀតផង។

បញ្ហានៃទីតាំងអាចនិយាយតាមទម្រង់ នៃការតកូនតចៅក្នុងកម្រិតខុសៗគ្នានៃការប្រមូលផ្ដុំ ឬការរាយប៉ាយ ដោយមូលហេតុដែលត្រូវពិនិត្យមើលម្ដងមួយករណីៗ។ ដូចគ្នាដែរ ការរាយប៉ាយនៃជនជាតិចិនទាជីវ ជនជាតិវៀតណាម និងជនជាតិចាមទាក់ទងទៅនឹងហេតុផលប្រវត្តិសាស្ត្រ សេដ្ឋកិច្ច និងនយោបាយខុសៗគ្នាយ៉ាងដាច់ស្រឡះ។

បើនិយាយអំពីទីតាំង យើងអាចសង្ខេបទំនាក់ទំនងរវាងជាតិពន្ធុផ្សេងៗនៅកម្ពុជាទៅនឹងជាតិពន្ធុភាគច្រើន(ខ្មែរ) ដូចតទៅ :

- ទឹកដីដែលជាតិពន្ធុដើមឥណ្ឌូចិនជាភាគច្រើនរស់នៅ (មណ្ឌលគិរីនិងរតនគិរី) ឬក៏មានចំនួនសមល្មម (ព្រះវិហារ) គឺស្ថិតនៅ តំបន់ដែលមានប្រយោជន៍ (ជុំវិញបឹងទន្លេ

សាប និងផ្នែកខាងក្រោមទន្លេមេគង្គ) ។ គឺជាទឹកដីដ៏ធំធេងជាមួយនឹងប្រជាជនដែលមានចំនួនតិចតួចបំផុត : ខេត្តដែលមានផ្ទៃដីធំជាងគេនៅកម្ពុជា (មណ្ឌលគិរី) គឺជាខេត្តដែលមានប្រជាជនតិចជាងគេ ពោលគឺ ជាងពីរនាក់ក្នុងមួយគីឡូម៉ែត្រក្រឡា (Guyant, 1998) ។ ក៏ប៉ុន្តែ នៅមានសំណល់ខ្លះនៅតាមតំបន់ដែលមានប្រយោជន៍ (ស្ទួយ ស្ទួច) ជាសក្ខីភាពបញ្ជាក់ពីវត្តមានដ៏ច្រើននិងដ៏ចំណាស់មួយ ។

- ជនជាតិភាគតិចដទៃទៀត មានលក្ខណៈរាយប៉ាយក្នុងកម្រិតផ្សេងៗគ្នានៅក្នុងផ្ទៃប្រទេសតាមតំបន់មានប្រយោជន៍ ហើយករណីរាយប៉ាយដ៏ធំបំផុតនោះ គឺការរាយប៉ាយនៃជនជាតិចិនទាជីវ ។

## ២.៣.សង្គមភាសាវិទ្យា

យើងសិក្សានៅទីនេះនូវទិដ្ឋភាពពីរ :

- បញ្ហានៃទ្វេភាសានិយម
- ចំណោទនៃសំណេរ

### ២.៣.១.បញ្ហានៃទ្វេភាសានិយម

#### ២.៣.១.១.និន្នន័យនៃបញ្ហា

បើនិយាយត្រឹមនិយមន័យ បញ្ហាហាក់ដូចជាសាមញ្ញ : «បុគ្គលម្នាក់ហៅថាអ្នកចេះភាសាចម្រុះ (ពីរភាសា បីភាសា. ..) បើសិនជាគេចេះភាសាច្រើន ដោយរៀនភាសានីមួយៗដូចភាសាកំណើត (ក្នុងន័យនេះ អ្នកចេះពហុភាសាមិនមែនជាអ្នកចេះភាសាចម្រុះនោះទេ ប៉ុន្តែ តាមពិតមិនមានការខុសគ្នាដាច់ស្រឡះទេ រវាងការសិក្សាតាម «ធម្មជាតិ» និងការសិក្សាតាម «សាលា» នៃភាសាមួយដោយក្មេង

[៣៨] ក្នុងអត្ថបទនេះយើងប្រើនិយមន័យរបស់ Ducrot និង Schaeffer(Ducrot et Schaeffer, 1995)

ម្នាក់)»[៧៥]។ នៅក្នុងកិច្ចពិភាក្សាស្ដីពីចម្រុះភាសានិយម នៅមានបញ្ហាបច្ចេកទេស ដូចជា ឥទ្ធិពលនៃប្រព័ន្ធសទ្ទតារបស់ភាសាមួយទៅលើប្រព័ន្ធសទ្ទតានៃភាសាមួយទៀត ការបង្កើតភពយោងនៃបុគ្គលទ្វេភាសា។ល។ ទាំងនេះសុទ្ធតែជាបញ្ហាដែលមិនពាក់ព័ន្ធផ្ទាល់ទៅនឹងប្រធានបទយើងពេលនេះទេ។

ក្នុងករណីនៃទំនាក់ទំនងរវាងភាសា នៃជនជាតិភាគតិចនៅកម្ពុជានិងភាសាខ្មែរ គេប្រាកដជាជួបប្រទះបុគ្គលដែលស្ថិត ក្នុងស្ថានភាពកំណត់ដោយនិយមន័យខាងលើ។ យើងបានជួបផ្ទាល់ជាមួយក្មេងទ្វេភាសា ដែលមានម្ដាយជាជនជាតិព្នង និង ឪពុកជាជនជាតិខ្មែរ ហើយដែលក្មេងនោះនិយាយភាសាពីរនេះបានស្ទាត់។ ក៏ប៉ុន្តែ ស្ថានភាពនេះដែលកើតចេញពីអាពាហ៍ ពិពាហ៍ចម្រុះដោយគ្មានអ្វីពិសេសនោះ មិនមានទម្ងន់សង្គមនោះទេ។

ដូច្នេះ យើងត្រូវចោទសួរជាថ្មីអំពីទ្វេភាសានិយមនៅក្នុងទំនាក់ទំនងជាមួយភាសាគោលដែលជាភាសាខ្មែរ ហើយប្រការនេះតម្រូវឱ្យយើងគិតដល់បរិបទដែលក្នុងនោះបញ្ហាទ្វេភាសានិយមត្រូវបានចោទសួរខាងដើមមកហើយ ជាអាទិ៍នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិដូចជាអង្គការយូនីសេហ្វដែលបានបង្កើតកម្មវិធីមនុស្សធម៌សម្រាប់ ជនជាតិភាគតិចជាទូទៅនៅក្នុងវិស័យអប់រំ និងសុខភាព។

នៅក្នុងវិស័យអប់រំ សំណួរត្រូវបានលើកឡើងដូចតទៅ : តើភាសាខ្មែរអាចប្រើនៅក្នុងរង្វង់ជនជាតិភាគតិចណាមួយ ដើម្បីបញ្ជូនសារណាមួយបានឬទេ? ឬក៏ត្រូវវិលទៅរកភាសាជនជាតិភាគតិចវិញ? ទាំងនេះនាំឱ្យមានការចោទសំនួរដូចតទៅនេះ :

តើជនណាដែលអាចយល់ខ្មែរ? ហើយតើយល់ក្នុងកម្រិតណា? ចម្លើយមានភាពប្លែកៗគ្នារហូតដល់ផ្ទុយគ្នាទៀតផង ហើយស្ថានភាពនេះត្រូវតែពិនិត្យក្នុងមុំជាច្រើន :

- តាមជនជាតិភាគតិចម្តងមួយៗ
- នៅក្នុងរង្វង់នៃជនជាតិភាគតិចនីមួយៗទៅតាមជំនាន់មនុស្ស
- នៅក្នុងរង្វង់នៃជនជាតិនីមួយៗទៅតាមទីកន្លែង។

លើសពីនេះទៅទៀត យើងពិបាកប្រើទិន្នន័យដែលបោះផ្សាយដោយអង្គការដែលធ្វើការងារនៅក្នុងរង្វង់ជនជាតិភាគ តិចណាស់ ពីព្រោះការគិតគូរលើទេ្វភាសានិយមពិសេសមួយនឹងទាក់ទងទៅនឹងកម្មវិធីមួយច្បាស់លាស់ ហើយមិនដូចគ្នាទៅនឹងកម្មវិធីផ្សេងទេ : ជាក់ស្តែងកម្មវិធី សម្រាប់គោលការណ៍មូលដ្ឋាននៃអនាម័យម្ហូបអាហារឬការប្រើប្រាស់មុងមិនផ្អែកលើ លក្ខខណ្ឌ ដូចគ្នានៃការចេះដឹងភាសាខ្មែរក្នុងកម្មវិធីសម្រាប់ការបង្រៀននោះទេ។

ប្រការទាំងនេះធ្វើឱ្យបញ្ហាកាន់តែស្មុគស្មាញ ហើយការបង្កើតតារាងនៃឯកភាសានិយមឬទេ្វភាសានិយមនៃជនជាតិ ភាគតិចនីមួយៗអោយប្រាកដមិនអាចធ្វើទៅបានភ្លាមៗនោះទេ បានត្រឹមប្រហាក់ប្រហែលប៉ុណ្ណោះ។

ជាបន្តទៅទៀតនេះ យើងសាកល្បងបង្កើតមាត្រដ្ឋានមួយដើម្បីបំភ្លឺស្ថានភាព[៧៦] នេះ។

[៧៦] យើងសូមបញ្ជាក់ថា ទិន្នន័យដែលមានជាបន្តទៅនេះគឺមានលក្ខណៈប្រហាក់ប្រហែលសុទ្ធសាធ ហើយបានមកពីបទពិសោធន៍ផ្ទាល់របស់យើងជាភាសាវិទូដែលចុះទៅដល់មូលដ្ឋាន។

បញ្ហាចុងក្រោយមួយចោទឡើង នៅក្នុងករណីនៃជាតិពន្ធុដែលសមាជិករស់នៅបែកខ្ញែកគ្នាពេញផ្ទៃប្រទេស។ នៅក្នុងករណីមួយចំនួន (ចិនទាជីវ) យើងសាកល្បងធ្វើការវាយតម្លៃទៅលើមូលដ្ឋាន នៃតួលេខបានមកពីអ្នកផ្តល់ព័ត៌មានរបស់យើងទៅលើមូលដ្ឋាននៃស្ថានភាពក្នុងសាលាចិននិងក្នុងទីស្នាក់ការសមាគម។ ក្នុងករណីផ្សេងទៀត (ប្រជាជនវៀតណាមនៅកម្ពុជា) យើងមិនអាចមានទិន្នន័យពិតប្រាកដទេ។ម្យ៉ាងទៀត អត្ថបទស្តីពីជនជាតិភាគតិច វៀតណាមនៅកម្ពុជាដែលជាទូទៅជាការសិក្សាពីជាតិពន្ធុវិទ្យាហើយវិភាគពីបញ្ហានៃភាសាវៀតណាមនៅកម្ពុជាក្នុងមុំនៃចំណោទបញ្ហាអត្តសញ្ញាណកម្មឬសមាហរណកម្មក្មេងៗវៀវណាមទៅក្នុងសាលាខ្មែរ ប៉ុន្តែ មិនមានការវាយតម្លៃណាមួយ ដែលទាក់ទងនឹងចំនួនអ្នកនិយាយភាសានេះនិងបញ្ហាទ្វេភាសានោះទេ (Bertrand ១៩៩៦)។

### ២.៣.១.២.ឯកភាសានិយមនិងទ្វេភាសានិយមក្នុងជនជាតិភាគតិចនៅកម្ពុជា

ស្ថានភាពបែងចែកច្បាស់លាស់ (ទ្វេភាសានិយមនិងឯកភាសានិយម) គ្មានន័យប៉ុន្មានទេ នៅក្នុងប្រធានបទនេះ តាមការពិតគឺការបន្តកូនចៅដែលជាបញ្ហាត្រូវលើកឡើង។

#### ២.៣.១.២.១.ឯកភាសានិយមក្នុងភាសានៃជនជាតិភាគតិច

គឺនៅក្នុងផ្នែកនេះហើយដែលត្រូវដាក់បញ្ចូលនូវ ភាសាជនជាតិភាគតិចជាច្រើននៃពាយព្យកម្ពុជាក្នុងខេត្តមណ្ឌលគីរី រតនគីរី និងមួយភាគនៃខេត្តស្ទឹងត្រែង។

ការដែលបុគ្គលម្នាក់ចេះពាក្យខ្មែរពីរបីម៉ាត់មិនអាចចាត់ទុកថាគេជាជនចេះពីរភាសា[៧៧] បាននោះទេ។

---

[៧៧] នៅក្នុងសៀវភៅដែលមានគុណភាពខ្ពស់ស្តីពីខេត្តរតនគីរី (Bourdier, 2006) អ្នកនិពន្ធដោយបានលើកឡើងពីស្ថានភាព

ប្រជាជនដែលស្ថិតក្នុងបញ្ជីតទៅនេះ ភាគច្រើនលើសលប់ជាជនចេះតែមួយភាសា ( ជនឯកភាសា)

| ជាតិពន្ធ | ភាសាកំណើត | ប្រជាជន |
|---|---|---|
| ចារាយ | ចារាយ | ២០ ០០០ |
| កាចូ | កាចូ | ១ ៣០០ |
| ទំពួន | ទំពួន | ២៤ ០០០ |
| ប៉ាវ ( លុន ក្រាវ៉េត គ្រឹង)[៧៨] | ប្រាវ | ២៣ ៨០០ |
| ព្នង ( បៀត) | ព្នង | ២០ ០០០ |

អ្នកដែលបានបង្កើតឱ្យមានកម្មវិធីមនុស្សធមិនៅពាយព្យនៃប្រទេសបានគូសបញ្ជាក់ពីការចាក់ឫសតិចតួចនៃភាសាខ្មែរនៅក្នុងផ្នែក នេះនៃកម្ពុជា[៧៩] និងពីពិការភាពនានាដែលកើតចេញពីប្រការនេះ ជាអាទិ៍ផ្នែកអប់រំ។ គឺដោយហេតុផលនេះហើយបាន

[៧៨] ផ្ទុយពីអ្នកនិពន្ធដទៃទៀត យើងសម្រេចរក្សាទុកពាក្យ «ប្រាវ» ហើយចាត់ទុកភាសានិយាយ លុន ក្រាវ៉េត គ្រឹង ថាជាគ្រាមភាសារបស់ប្រាវ។ ត្រូវចងចាំថា ចំណាត់ថ្នាក់ពីរនៅតែ អាចធ្វើទៅបាន : ចំណាត់ថ្នាក់បែបជាតិពន្ធុវិទ្យាដែលនឹងលើកឡើងពីភាពខុសគ្នានៃសង្គមវប្បធមិនិងមជ្ឈដ្ឋានដើម្បីពន្យល់ពីបម្រែបម្រួលភាពនៃជាតិពន្ធុនាមនោះ : « It is impossible to know how far back the dicision of the Brao into subgroups of Kreung, Kravet, Lun and the present Brao goes. But everything leads one to think that this differentiation took place once these groups had occupied different territories, for historicalreasons unknown to us (demographic, ecological constraints) », (Bourdier, 2006). នឹងមានចំណាត់ថ្នាក់មួយទៀតគឺចំណាត់ថ្នាក់ភាសាដែលប្រសិនបើទៅរួចនឹងនិយាយអំពីបញ្ហានៃបម្រែបម្រួលគ្រាមភាសា។

[៧៩] Norlander, (Norlander, 2003) ស្តីពីគម្រោងបង្កើតឡើងដោយអង្គការ Care ការយល់ឃើញដូចគ្នានេះមាននៅលើទំព័រអ៊ីនធឺណែតរបស់អង្គការ International Cooperation Cambodia (ICC)

ជាជំណោះស្រាយដែលបានប្រកាន់យកនៅក្នុងវិស័យនេះ គឺត្រូវបង្កើតឱ្យមាននយោបាយអនក្ខរកម្មក្នុងភាសាជនជាតិភាគតិច ដើម្បីអាចឈានទៅរៀនជាភាសាខ្មែរចាប់ពីឆ្នាំទីបីនៃសាលាបឋមសិក្សា។ ការសម្រេចនេះបានចោទជាបញ្ហាស្តីពីការ បង្កើតអក្សរនៅលើមូលដ្ឋាននៃអក្សរខ្មែរដូចអ្វីដែលយើងឃើញនៅពេលបន្ទាប់ទៅនេះ។

ប្រហែលជាគេត្រូវបញ្ជាក់ប្រាប់នៅក្នុងផ្នែកនេះ នូវប្រជាជននៃជាតិពិន្ទុកួយក្នុងខេត្តព្រះវិហារ។

ដោយហេតុផលទាក់ទងនឹងប្រវត្តិសាស្ត្រ (ការងារធ្វើដែកតាំងពីសម័យអង្គរ) សាសនា (ឥទ្ធិពលដ៏ខ្លាំងក្លាពីពុទ្ធ សាសនា ទោះបីជាគ្មានការឯកភាពគ្នាជារួមក៏ដោយ) និងវត្តមានដ៏ច្រើននៃចំនួនប្រជាជនខ្មែរតាំងពីសម័យបុរេអង្គរពួកកួយសុទ្ធតែជាជនទ្វេភាសា កួយ-ខ្មែរ ទោះបីជាភាសាកំណើតរបស់គេភាគច្រើនជាភាសាកួយក៏ដោយ។ ក៏ប៉ុន្តែ មានប្រជាជនកួយ មិនតិចទេដែលចេះតែមួយភាសា ដូចយើងបានប្រទះរួចមកនៅក្នុងតំបន់ស្វាយដំណាក់។

ដោយសារប្រជាជនកួយរស់នៅបែកខ្ញែកគ្នានោះ យើងពិបាកនឹងផ្តល់តួលេខច្បាស់លាស់ណាស់អំពីចំនួននៃអ្នកចេះ ភាសាកួយតែមួយ[៨០] ក្នុងពេលភ្លាមៗនេះ។

## ២.៣.១.២.២.ទ្វេភាសាក្នុងប្រយោជន៍នៃភាសាជនជាតិភាគតិច

នៅក្នុងក្រុមនេះ យើងមិនមែនចង់ដឹងចំនួនអ្នកចេះភាសាខ្មែរ ឬសួរនាំអ្នកដែលយើងបានជ្រើសរើសអំពីចរិតភាសា ដែលគេចូលចិត្តនោះទេ។ យើងដាក់បញ្ចូលក្នុងផ្នែកនេះនូវជាតិពន្ទុកួយមួយភាគធំនៃខេត្តព្រះវិហារ[៨១]។

---

[៨០] វិធីសាស្ត្រវាយតម្លៃប្រកបដោយសុក្រិតភាពតែមួយគត់គឺផ្តោតលើការវិភាគប្រភពរបស់អាជ្ញាធរអប់រំក្នុងស្រុក ហើយត្រូវផ្ទៀងផ្ទាត់ទៅនឹងការវាយតម្លៃដល់ទីកន្លែង។

ការណ៍ដែលជនជាតិកួយនៅកម្ពុជា[៨២] ត្រូវបានធ្វើសមាហរណកម្មទៅក្នុងជីវភាពរស់នៅរបស់ជនជាតិកម្ពុជានៃតំបន់ទំនាប[៨៣] មិនបានរារាំងការអភិរក្សភាសានោះទេ ហើយក៏មិនបានរារាំងចំណូលចិត្តផ្សេងទៅរកជនជាតិកួយនៅក្នុងជីវភាព ប្រចាំថ្ងៃនោះដែរ។ ម្យ៉ាងទៀតវាមិនមែនជាការចៃដន្យទេ ការដែលក្រសួងអប់រំបានបកប្រែសៀវភៅភាសាខ្មែរឆ្នាំទីមួយនៃ សាលាបឋមសិក្សាជាភាសាកួយនោះទេ។ ការសម្រេចនេះនឹងស្តែងចេញទៅថ្ងៃអនាគត់ ជាការរៀនសរសេរនៅលើមូលដ្ឋាន នៃភាសាកួយមិនមែននៅលើមូលដ្ឋានភាសាខ្មែរទេ។

ជាតិពន្ធុក្រុមទីពីរ ពោលគឺចាម[៨៤] ហាក់ដូចជាចូលទៅក្នុងក្រុមនេះ។ វាដូចជាពិបាកបន្តិចក្នុងការផ្តល់ការវាយតម្លៃ ប្រាកដប្រជាមួយស្តីពីទ្វេភាសានិយម ដោយហេតុថាមានការរាយប៉ាយនៃជនជាតិចាមនៅលើទឹកដីប្រទេសកម្ពុជា។ អង្កេត ដែលយើងបានធ្វើនៅក្នុងខេត្តកំពង់ឆ្នាំង កំពង់ចាម និងក្រចេះអាចឱ្យយើងវាយតម្លៃថាជាង៧០%

---

[៨១] ជនជាតិកួយមានចំនួនប្រហាក់ប្រហែល៣០ ០០០នាក់ រស់នៅក្នុងខេត្តបួននៃកម្ពុជា : ស្ទឹងត្រែង កំពង់ធំ ក្រចេះ និងព្រះវិហារ។ គឺនៅក្នុងខេត្តចុងក្រោយនេះហើយ ដែលពួកកួយភាគ ច្រើនរស់នៅ២០-២៣ ០០០នាក់ (Markowski, 2005)។

[៨២] កួយ៣០ ០០០នាក់ដែលរស់នៅប្រទេសថៃ (Grimes, 2000)និង ៥០ ០០០នាក់នៅប្រទេសឡាវ (Chazée, 1999)។

[៨៣] ជីវភាពរស់នៅរបស់ជនជាតិកម្ពុជាតំបន់ទំនាបសំដៅដល់ការធ្វើកសិកម្មដែលខុសពីការធ្វើកសិកម្មនៅខ្ពង់រាប (ដុតព្រៃធ្វើចំការ) និងការប្រតិបត្តិសាសនា ដែលរាប់បញ្ចូលទាំងពុទ្ធ សាសនាខ្មែរដោយធៀបទៅនឹងការកាន់អារក្សអ្នកតានៅខ្ពង់រាប។ យើងគិតផងដែរថា តួនាទីនៃក្ទមដែលជាបាតុភូតវប្បធម៌ដ៏សំខាន់នោះគឺពាក់ព័ន្ធទៅនឹងជីវិតអ្នកនៅខ្ពង់រាបខុសពីទំនាប។

[៨៤] តួលេខទាក់ទងនឹងជនជាតិចាមនៅកម្ពុជាប្រែប្រួលសម្បើមណាស់ : ៣២១ ០០០(Ethnie Cambodia),៤៧៤ ០០០ (Royaume du Cambodge),២២០ ០០០ (Ethnologue)។ បម្រែបម្រួលទាំងនេះដូចជាបណ្តាលមកពីវិធីសាស្ត្រដែលគេយកមកប្រើនិងសម័យផងដែរ។ បញ្ហាទីពីរចោទជាសំណួរថា តើពួកជ្វា (ដែលគ្មានការវាយតម្លៃជាចំនួន) កាន់សាសនាអ៊ីស្លាមតែមិនមែនចាមត្រូវបានបញ្ចូលឬមិនបញ្ចូលទៅក្នុងតួលេខ។ តួលេខមួយដែលគួរឱ្យយើងជឿគឺជនជាតិចាមមានចំនួនប្រហែល២៤០ ០០០នាក់។

នៃជនជាតិចាមចូលចិត្តប្រើ ភាសាចាមជាង ប៉ុន្តែ ពួកគេក៏ចេះភាសាខ្មែរ[៨៥] ដែរ ។

ក្រុមទីបីគឺក្រុមចិនខិនៃវើនសៃក្នុងខេត្តរតនគិរី[៨៦] និងខេត្តស្ទឹងត្រែង។ ភាសាដែលគេប្រើប្រចាំថ្ងៃគឺចិនខិ ហើយអ្នកដែលមានការអប់រំអាចនិយាយភាសាចិនកុកងឺបានសម្រាប់ការសន្ទនា ផ្ទុយទៅវិញកម្រិតនៃការប្រើប្រាស់ភាសា ខ្មែរនៅទាបនៅឡើយ ។

ជាតិពន្ធឡាវ[៨៧] ហាក់ដូចជាប្រើភាសាពីរដែរ ប៉ុន្តែមិនសូវប្រើភាសាខ្មែរទេ[៨៨] ។ យើងអាចវិភាគស្ថានភាពនៅក្នុងស្រុក ពីរ[៨៩] តែប៉ុណ្ណោះ ដែលភាសាប្រើប្រចាំថ្ងៃគឺភាសាឡាវនិងភាសាខ្មែរដែលគេចេះដឹងច្រើនគួរសម។ គឺតាមរយៈភាសាខ្មែរនេះហើយដែលអង្កេតរបស់យើងត្រូវបានធ្វើឡើង។

### ២.៣.១.២.៣. ទ្វេភាសានិយមពិតប្រាកដ

គឺជាក្រុមមួយពិបាកនឹងកំណត់ណាស់ ។ ពួកនេះអាចនិយាយភាសាខ្លួនបានយ៉ាងល្អនិងនិយាយភាសាខ្មែរក៏បានល្អដែរ ហើយអាចនិយាយផ្លាស់ប្តូរពីភាសាមួយទៅភាសាមួយទៀតស្របទៅតាមតម្រូវការក្នុងជីវិតប្រចាំថ្ងៃ ។

---

[៨៥] គួរបញ្ជាក់ថានេះជាការវាយតម្លៃលើកទីមួយដែលនឹងត្រូវកែតម្រូវក្នុងពេលអនាគត ។

[៨៦] គឺជាជនជាតិភាគតិចចិនតូចមួយដែលយើងអាចវាយតម្លៃថាមានចំនួន៨ ០០០នាក់នៅក្នុងផ្ទៃប្រទេសកម្ពុជាទាំងមូល ។ ក្នុងតំបន់វើនសៃ និងខេត្តស្ទឹងត្រែង យើងគិតថាមានជនជាតិនេះ ប្រមាណ១ ០០០នាក់ ។

[៨៧] ឡាវរស់នៅជាពិសេសក្នុងខេត្តស្ទឹងត្រែងនិងរតនគិរី ។ មានភូមិខ្លះៗជាភូមិឡាវហើយបានធ្វើខ្មែរូបនីយកម្ម ក្នុងខេត្តស្វាយរៀង (Escoffier, 1996) ។ យើងមិនបានរាប់បញ្ចូលទេ ព្រោះអំណើះតទៅអ្នកទាំងនោះបានចាត់ទុកខ្លួនគេដូចជាខ្មែរទៅហើយ ។

[៨៨] ស្ថានភាពខុសគ្នាទាំងស្រុងនៅក្នុងខេត្តភាគខាងជើងនៃប្រទេសកម្ពុជាដែលឡាវមិនមែនគ្រាន់តែនិយាយនៅក្នុងផ្ទះ ក្នុងភូមិប៉ុណ្ណោះទេ ប៉ុន្តែជាភាសានៃការប្រាស្រ័យទាក់ទងជាមួយ អ្នកស្រុក (ដែលនិយាយឡាវល្អជាងខ្មែរ) ។ ដូច្នេះ ភាសាជាកត្តាឯកភាពមិនត្រឹមតែក្នុងកម្រិតសហគមន៍ឡាវផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងកម្រិតសហគមន៍ផ្សេងៗទៀតនៅជិតៗគ្នាដែលអាចឱ្យមានការផ្លោះប្តូរគ្នា (Escoffier, 1996) ។

[៨៩] ក្នុងខេត្តស្ទឹងត្រែង ស្រុកសេសាន និង ក្នុងខេត្តរតនគិរី ស្រុកលំផាត់ ។

ក្រុមជាតិពន្ធុសួយ[៥០] ក្នុងខេត្តកំពង់ស្ពឺហាក់ដូចចូលទៅក្នុងក្រុមនេះ ទោះបីជាត្រូវនិយាយអំពីស្ថានភាពពួកគេក្នុងក្តី មន្ទិលក៏ដោយ។ មនុស្សជំនាន់មុនចូលចិត្តនិយាយភាសាសួយដោយអាចនិយាយភាសាខ្មែរបានទៀតផង ហើយអ្នកដែលយើងបានសាកសួរនោះបានប្រកាសថាចង់អោយក្មេងជំនាន់ក្រោយនេះរក្សានិយាយភាសាសួយ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ កើតមានការទាមទារអត្តសញ្ញាណកម្មដែលទាក់ទងទៅនឹងការគោរពអារក្ស អ្នកតារបស់ខ្លួននៅក្នុងពិធីផ្សេងៗដែលចាំបាច់ត្រូវប្រើភាសាសួយ ព្រមទាំងឆន្ទៈនៃការបង្កើតអនក្ខរកម្មនៅលើមូលដ្ឋាននៃភាសាសួយ ហើយដែលឆន្ទៈនេះបានសម្តែងតាម រយៈគូសន្ទនារបស់យើង។ ចំណែកឯក្មេងជំនាន់ក្រោយវិញ ភាគច្រើនអាចនិយាយបានទាំងពីរភាសា ទោះបីជាពួកចាស់ៗ និយាយថាមានឥទ្ធិពលកាន់តែខ្លាំងឡើងនៃភាសាខ្មែរ នៅក្នុងវិស័យវចនសព្ទ និងនៅក្នុងរចនាសម្ព័ន្ធឃ្លាក៏ដោយ។

ចិនទាជីវ[៥១] បង្ហាញពីស្ថានភាពស្មុគស្មាញគួរសម ព្រោះគេពិបាកនឹងកំណត់ចំនួននៃអ្នកនិយាយភាសានេះណាស់។ នៅ ភ្នំពេញ ចិនភាគច្រើនគឺជាចិនទាជីវ។ ការអង្កេតដែលយើងបានធ្វើផ្តល់លទ្ធផលដូចទៅ :

---

[៥០] ត្រូវប្រុងប្រយ័ត្នចំពោះបញ្ហាជាតិពន្ធុនាមមួយនេះ។ គេអាចហៅភាសានេះខុសគ្នាបន្តិចបន្តួចទៅតំបន់ផ្សេង។ ភាសា *សួយ* មាននិយាយជាពិសេសនៅ ឡាវ។ គឺជាភាសាមួយនៃអំបូរ អូស្រ្តូ-អាស៊ីនៃក្រុមកាទូអ៊ិក អនុក្រុមកាទូអ៊ិកខាងលិចដែលតាមពិតជាគ្រាមភាសានៃ ភាសាកួយ។ ជាតិពន្ធុនាមសួយដែលគេប្រើដើម្បីហៅជនជាតិភាគតិចរស់នៅក្នុងខេត្តកំពង់ស្ពឺគឺជា ការក្លាយពីពាក្យ *ស្អូង* ដែលជាជាតិពន្ធុនាមពិតប្រាកដរបស់ពួកគេ ហើយដែលជាភាសាអូស្រ្តូ-អាស៊ីមួយនៃក្រុមពៀរិក។

[៥១] យើងឃើញមានតួលេខចិនទាជីវចំនួន១៨១ ០០០នាក់នៅកម្ពុជា (Ethnic Cambodia) ដែលជាក្រុមជនជាតិចិនច្រើនជាងគេនៅកម្ពុជា ប៉ុន្តែគេក៏ត្រូវប្រើតួលេខនេះដោយប្រុង ប្រយ័ត្ន ព្រោះគេគ្មានគោលការណ៍ជាក់លាក់ក្នុងការវាយតម្លៃចំនួននៃក្រុមនេះទេ។ ហេតុផលគឺសាមញ្ញបំផុត :១.បើធៀបទៅនឹងក្រុមចិនដទៃទៀត ចិនទាជីវជាជនជាតិរស់នៅបែកខ្ញែក

- អ្នកនិយាយភាសាទាជីវដែលមានអាយុលើសពី៣០ឆ្នាំ ភាគច្រើនលើសលប់អាច ត្រូវបានចាត់ទុកជាជនទ្វេភាសាទាជីវ-ខ្មែរ។

- អ្នកនិយាយភាសាទាជីវដែលមានអាយុតិចជាង៣០ឆ្នាំ មកពីខេត្តជាប់ភ្នំពេញ ក្រោយឆ្នាំ១៩៨៦ ភាគច្រើន( ៦០% )ជា ជនទ្វេភាសា។

- អ្នកដែលមានកំណើតនៅភ្នំពេញ នៅដើមទសវត្សឆ្នាំ៨០ឬក៏មកដល់តាំងពីក្មេង ក្នុងសម័យនោះ ភាគច្រើនជាជនឯក ភាសាខ្មែរឬគ្រាន់តែចេះទាជីវ[៩២] បន្តិចបន្តួច ប៉ុណ្ណោះ។

ចិនកន្តាំងចោទបញ្ហាធំនៅក្នុងន័យថា ស្ថិតិធ្វើឡើងក្នុងឆ្នាំ៦០ស្តីពីជាតិពន្ធុ ចិននៅកម្ពុជាបានដាក់ជាតិពន្ធុនេះនៅក្នុងចំ ណាត់ថ្នាក់ទីពីរបន្ទាប់ពីចិនទាជីវ[៩៣] ។ សព្វថ្ងៃយើងគ្មានទិន្នន័យចំនួនដែលអាចយកជាការបានពីប្រធានបទនេះទេ ហើយ

---

ជាងគេនៅលើផ្ទៃប្រទេស ដោយគេបានជួបជនជាតិនេះរហូតដល់តាមភូមិដែលពួកគេធ្វើជំនួញតូចតាច ហើយបង្កើតបានជាកាំទីមួយនៃច្រវាក់ពាណិជ្ជកម្មស្រូវ។ ២. ត្រូវបង្កើតលក្ខខណ្ឌ ច្បាស់លាស់ដើម្បីកំណត់អត្តសញ្ញាណនៃសមាជិកជាតិពន្ធុភាគតិចនេះ ហើយការចេះឬភ្លេចភាសាមិនមែនជាលក្ខខណ្ឌទេ។ យើងបានជួបមនុស្សជាច្រើនដែលបានប្រកាសថាខ្លួនជាចិនទាជីវ ទោះជាគេមិនចេះភាសានេះក៏ដោយ។ ៣.តួលេខដែលផ្តល់ដោយសមាគមន៍ចិនទាជីវមិនអាចក្តោបពីសមាជិកជនជាតិ ភាគតិចនេះបានទេ។ បើចង់ដឹងកាន់តែច្បាស់សូមអាន Wilmott (Wilmott, 1967) ។

[៩២] ភាពខុសគ្នានេះទាមទារនូវការពន្យល់មួយ។ ដោយមិនធ្វើបុរេវិនិច្ឆ័យអ្វីទាំងអស់ នៅសម័យសាធារណរដ្ឋប្រជាមានិត កម្ពុជា សម័យរដ្ឋកម្ពុជា (១៩៧៩-១៩៩២) គេហាក់ដូចជាមាន ការមិនទុកចិត្តជាផ្លូវការមួយចំពោះជនជាតិភាគតិច ចិន-ខ្មែរ ដោយសារតែជម្លោះប្រដាប់អាវុធរវាងវៀតណាមនិងចិនដែលជំរុញឱ្យខ្មែរកំណើតចិនមួយចំនួនបោះបង់អត្តសញ្ញាណចិនរបស់ ខ្លួន ដែលចាត់ទុកដូចជាការបន្ទុចបង្អាក់ដល់ការធ្វើសមាហរណកម្មចូលទៅក្នុងសង្គម។ យើងអាចផ្ទៀងផ្ទាត់ការណ៍នេះបាននៅក្នុងកិច្ចសន្ទនារបស់យើង។ សូមអាន Edwards, (Edwards,1996) ផងដែរ។

[៩៣] សម្រាប់ឆ្នាំ១៩៦២-១៩៦៣ យើងមានតួលេខដូចតទៅ : ចិនទាជីវ=៣២៤ ០០០ នាក់ ចិនកន្តាំង=៤៣ ០០០ នាក់ ហៃណាំ=៨ ០០០ នាក់ (Willmott, 1967) ។

ប្រហែលជាសារៈសំខាន់ នៃចំនួនរបស់គេនាពេលបច្ចុប្បន្នលែងជារឿងធំដុំដូចក្នុងស្ថានភាពឆ្នាំ៦០ទៀតហើយ ។ អ្នកចេះចិន កន្តាំងខ្លះដែលយើងអាចសួរបាៗ[៥៤] សុទ្ធតែជាជនទ្វេភាសាហើយបានប្រកាសប្រាប់យើងថាបងប្អូន និងអ្នកដែលគេស្គាល់ក៏ជាជនទ្វេភាសាដែរ ។ ពេលយើងសាកល្បងប៉ាន់ប្រមាណជាមួយពួកគេនូវចំនួនប្រជាជនចិនកន្តាំងនៅភ្នំពេញ អ្នកផ្តល់ព័ត៌មាន របស់យើងយល់ស្របថា ចិនកន្តាំងមានចំនួនតិចតួចបំផុត ។

ជនជាតិចិនខាងជើងជាករណីលំបាកកំណត់គួរសម ពីព្រោះនៅប៉ុន្មានឆ្នាំចុងក្រោយនេះ (២០០០-២០០៧) មានអន្តោប្រវេសដែលមានប្រភពមកពីខេត្តខាងជើងនៃចិនប្រជាមានិតដែលយើងគ្មានទិន្នន័យណាមួយច្បាស់លាស់និងជាក់លាក់ឡើយ ។ ប្រការនេះអាចបញ្ជាក់ តាមរយៈការតាំងទីលំនៅថ្មីៗរបស់ពួកគេ និងតាមរយៈក្របខណ្ឌរបស់ពួកគេដែលមិនទាន់ ច្បាស់លាស់នៅក្នុងសហគមន៍កម្ពុជា[៥៥] ប៉ុន្តែយើងអាចកត់ត្រានៅកម្ពុជានូវជនជាតិចិននិយាយភាសាកុកងឺ[៥៦] ដែលមានជាយូរមកហើយ ហើយជាទូទៅមានប្រភពមកពីខេត្តហ៊ូប៉ី អ្នកក្រុងទាំងនេះ មានចំនួនប្រមាណជាង

---

[៥៤] ក្នុងខេត្តកំពត ប៉ុន្តែជាពិសេសនៅភ្នំពេញ ។ យើងមិនធ្វើអធិប្បាយពីប្រភេទថ្នាក់នោះទេ ដោយហេតុតែអ្នកផ្តល់ព័ត៌មាន របស់យើងមានចំនួនតិច ។

[៥៥] មានទិន្នន័យមិត់ចត់ដែលកំណត់ចំនួនអ្នកចេះភាសាចិនកុកងឺត្រឹម៣៥០ ០០០នាក់ (Ethnologue) ។ ចំពោះយើងទិន្នន័យនេះមិនប្រាកដទេព្រោះថាតើនេះជាតួលេខជាអ្នកចេះចិន កុកងឺពីកំណើតឬជាអ្នកចេះតាមការរៀនសូត្រនៅសាលា? អត្ថបទនោះរឹតតែមានមន្ទិលថែមទៀតដោយវាមិនបានរៀបរាប់ពីភាសាចិនផ្សេងទៀតដែលគេនិយាយនៅកម្ពុជាទេ ។

[៥៦] ន័យជាទូទៅនៃភាសាចិនកុកងឺជាភាសាទាំងឡាយនិយាយនៅចិនខាងជើងដែលគេយកទៅបង្កើតជាភាសាជាតិ ។ ប៉ុន្តែក្នុងពេលជាច្រើនសតវត្ស ចំណាកស្រុកឆ្ពោះទៅភាគខាងត្បូងបាន រួមចំណែកក្នុងការនាំយកភាសានេះទៅភាគខាងត្បូងនៃប្រទេស : យូណាន ស៊ីឈ័ន ហឺណាន ហ៊ូណាន ហ៊ូប៉ី ។

មួយពាន់នាក់ក្នុងទសវត្សឆ្នាំ ហុកសិប ហើយត្រូវបានរាប់បញ្ចូលទៅក្នុងសមាគមន៏ចិនខិ (Willmott, 1967) ។ តាមការអង្កេតរបស់យើងក្នុង សង្កាត់តាមបណ្ដោយផ្លូវសុកហុកនៅភ្នំពេញយើងបានប៉ាន់ប្រមាណថា មានប្រជាជននៃសមាជិកក្រុមនេះចំនួនប្រមាណ ២ ០០០នាក់ ដែលសុទ្ធតែជាជនទ្វេភាសា ។ អ្នកផ្ដល់ព័ត៌មានរបស់យើងសុទ្ធតែប្រកាសថាគេប្រើភាសាខ្មែរនៅខាងក្រៅ ហើយរក្សាការប្រើប្រាស់ភាសាចិនតែនៅក្នុងគ្រួសារតែប៉ុណ្ណោះ ។

### ២.៣.១.២.៤.ទ្វេភាសានិយមធ្វើអោយភាសាជនជាតិភាគតិចចុះខ្សោយ

គឺជាស្ថានភាពមួយដែលភាសាជនជាតិភាគតិច ប្រើដោយមនុស្សចាស់ៗដែលមានចំនួនកាន់តែតិចទៅៗ ។ មនុស្សជំនាន់ក្រោយនៅចេះភាសាពួកគេ ប៉ុន្តែពួកគេប្រើតែក្នុងស្ថានភាពប្រាស្រ័យទាក់ទងគ្នាបន្ទាប់បន្សំខ្លះៗប៉ុណ្ណោះ បើធៀបទៅ នឹងការប្រើប្រាស់ភាគ ច្រើនជាភាសាខ្មែរនៅក្នុងជីវិតប្រចាំថ្ងៃ ។ ការប្រើប្រាស់ដែលមាននៅសល់ខ្លះៗនេះ មាននៅក្នុងពិធី ដែលមានចរិតជាអត្តសញ្ញាណកម្មដូចជាពិធីសាសនាដែលគេអាចឮកំណាត់ឃ្លាមួយចំនួនក្នុងសុន្ទរកថាទូទៅជាភាសាខ្មែរ ។

នៅក្នុងផ្នែកនេះ យើងនិយាយអំពីក្រុមភាសាចិនពីរ :

- ភាសាចិនហៃណាំ ។ ពីដើម និយាយនៅក្នុងតំបន់កំពតដែលបន្ទាប់មកជនជាតិភាគតិចហៃណាំបានចាកចេញទៅភ្នំពេញ ស្រែ អំបិល និងស៊ីសូផុន ។ ភាសានេះសព្វថ្ងៃនៅសេសសល់តិចតួច[៦៧]នៅកំពត កំពង់ត្រាច និងទូកមាស[៦៨] ។ ចាស់ៗខ្លះបន្តនិយាយ ភាសាហៃណាំនេះទៀត ពិសេសអ្នកដែលយើងបានជួបនៅក្នុងព្រះវិហារ

---

[៦៧] យើងមានឱកាសស្គាល់ការសន្ទនាជាភាសាហៃណាំពិតប្រាកដតែចំនួនពីរដងគត់ ។

[៦៨] សម្រាប់ព័ត៌មានបន្ថែមសូមអាន Willmott(Willmott 1967, 1970)

ហៃណាំនៅភ្នំពេញ ប៉ុន្តែចំណោះភាសារបស់គេមិន បានផ្ទេរទាល់តែសោះទៅឱ្យក្មេងជំនាន់ក្រោយ ដែលនិយាយខ្មែរនិងរៀនភាសាចិនកុកងឺក្នុងសាលាចិន ។

- ភាសាចិនហុងកៀន ។ ជនជាតិចិនហុកកៀនជាជនជាតិចាស់ជាងគេនៅប្រទេសកម្ពុជា ហើយដែលរស់នៅជាពិសេសក្នុងក្រុងភ្នំពេញ ។ គេក៏ធ្លាប់ប្រទះឃើញជនជាតិហុកកៀនស្រុកស្រែ ក្នុងតំបន់បាត់ដំបង[៩៩] ផងដែរ ។ ឥឡូវនេះ ចិនហុកកៀនអាចត្រូវបានចាត់ទុកជាភាសាដែលមានប្រើកាន់តែតិច[១០០] ទៅជាងចិនហៃណាំទៀត ។

បន្ថែមពីលើក្រុមភាសាចិនទាំងពីរនេះ យើងអាចរៀបរាប់ពីភាសាអូស្ត្រូ-អាស៊ីពីរទៀតនៃក្រុមពៀរិក ។ ភាសាទាំងពីរ នោះដែលមាននិយាយនៅតាមជួរភ្នំពេញក្រវាញ គឺ សំរែ (ពៀរិកខាងលិច)និងសំរែ (ពៀរិកខាងកើត) ។ ក្នុងពេលបច្ចុប្បន្ន នេះ ភាសានីមួយៗក្នុងចំណោមភាសាទាំងពីរមានអ្នកចេះនិយាយមិនលើសពីប៉ុន្មានរយនាក់ប៉ុណ្ណោះ[១០១] ។

ករណីភាសាស្ទៀងស្មុគស្មាញបំផុត ព្រោះភូមិដែលយើងបានទៅទស្សនាក្នុងស្រុកស្នួលបង្ហាញពីសក្តីភាពនៃឥទ្ធិពល ខ្មែរដ៏ធំធេងដែលបណ្តាលមកពីការរីកចម្រើនជាអាទិ៍ផ្នែកសិក្សាធិការ ។ តាមពិត ភាសាខ្មែរជះឥទ្ធិពលដ៏ខ្លាំងក្លាទៅលើជីវិតប្រចាំ

---

[៩៩] ទិន្នន័យនេះបានមកពី Willmott(Willmott 1967, 1970) ។ ប៉ុន្តែ យើងប្រើ *អតីតកាល* ព្រោះការអង្កេតរបស់យើងមិនអាចឱ្យយើងរកឃើញពួកគេនៅទីនោះឡើយ ។

[១០០] អ្នកចេះនិយាយភាសាចិនហុកកៀនដ៏កម្រដែលយើងបានជួបនៅភ្នំពេញបានប្រាប់យើងថា គេលែងមានឱកាសប្រើភាសាគេទៀតហើយ ។

[១០១] តួលេខអ្នកចេះភាសាសំរែចំនួន២ ០០០នាក់ (Wurm et Hattori, 1981) ទោះក្នុងឆ្នាំ១៩៨១ក៏ដោយ ក៏ហាក់ដូចជាច្រើនជ្រុលពេកដែរ ។

ថ្ងៃមិនមែនតែក្នុងចំណោមក្មេងជំនាន់ក្រោយនេះទេ។ ការណ៍នេះត្រូវបានទទួលស្គាល់និងឯកភាពទាំងស្រុងពីសំណាក់ អ្នកផ្ដល់ព័ត៌មានរបស់យើង។

ផ្ទុយទៅវិញ អ្នកផ្ដល់ព័ត៌មានរបស់យើងម្នាក់បានរំឭកពីភូមិឆ្ងាយៗ ដែលប្រហែលជាមានស្ថានភាពទ្វេភាសាដែល ស្មៀងជាភាសាលប់។ យើងមិនអាចទៅកាន់ទីនោះបានទេដោយសារតែកង្វះពេលវេលាគ្រប់គ្រាន់ហើយមិនបញ្ចេញយោបល់ របស់យើងចំពោះប្រធានបទនេះទេ។

ចំពោះសំណួរដែលចង់ដឹងថា តើសព្វថ្ងៃនេះមានសហគមន៍ស្មៀងឯកភាសាទៀតទេនោះ អ្នកផ្ដល់ព័ត៌មានរបស់យើង សុទ្ធតែបានឆ្លើយថាគ្មានទេ ប៉ុន្តែ យើងគិតថាត្រូវតែមានការសិក្សាលំអិតតាមមូលដ្ឋាន។

### ២.៣.១.២.៥.ឯកភាសានិយមខ្មែរ

ជាការច្បាស់ណាស់ គេមិនត្រូវដាក់បញ្ចូលក្នុងផ្នែកនេះ នូវអ្នកចេះនិយាយភាសាខ្មែរពីកំណើតទេ ប៉ុន្តែ ត្រូវបញ្ចូល អ្នកចេះនិយាយភាសាជនជាតិភាគតិចដែលរក្សាបាននូវការចេះភាសារបស់ខ្លួន ប៉ុន្តែបែរជាឈប់និយាយភាសានេះហើយប្រើតែភាសាខ្មែរមួយមុខគត់។

ប៉ុន្តែស្ថានភាពនេះមិនមែនជារឿងចំលែក ប៉ុន្តែ ជាករណីពិសេសមួយនៅកម្ពុជា។ ជាទូទៅ ការលែងពេញនិយមនៃ ភាសាមួយដែលធ្វើឡើងដោយអ្នកនិយាយភាសានោះគឺស្របគ្នាទៅនឹងអភិក្រមនៃការសឹករិចរឹលដ៏យូរលង់មួយដែលឆ្លុះបំភ្លឺតាមរយៈការកែប្រែភាសាជនជាតិភាគតិចនៅពេលមានការជួបប្រសព្វជាមួយភាសាជនជាតិភាគច្រើន[១០២] ប៉ុន្តែករណីយើងនេះ មិនអញ្ចឹងទេ ភាសាទាំងពីរបានចូលទៅក្នុង

[១០២] ហើយប្រការនេះ គឺដោយសារការប៉ះពាល់បន្តិចម្ដងៗទៅលើវចនសព្ទ ប្រព័ន្ធសទ្ទៈ និងវចនាសម្ព័ន្ធឃ្លា។

ស្ថានភាពនេះ និងមិនមានការប៉ះពាល់ទេ ប៉ុន្តែ ត្រូវបានឈប់ប្រើប្រាស់ភ្លាមៗនៅសម័យរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយសារហេតុផលដែលមិនទាន់ពន្យល់ច្បាស់ទាំងស្រុងនៅឡើយទេ ក្រៅពីហេតុផលដែលថា របបខ្មែរក្រហមបង្ខំអោយប្រើតែភាសាខ្មែរ។

ភាសាជនជាតិភាគតិចពីរនៅកម្ពុជាចូលទៅក្នុងប្រភេទនេះ :

- ភាសាស្អូច[១០៣]។ ភាសានេះដែលប្រហែលជាបាត់បង់ទាំងស្រុងត្រូវបានគេសិក្សាពិព័ណ៌នាពិសេសក្នុងវិស័យវចនសព្ទនិង សទ្ទវិទ្យា[១០៤]។ ការសិក្សាទាំងនេះ បញ្ជាក់ថាស្អូចជាភាសាដែលមានការប៉ះពាល់តិចតួចដោយភាសាជនជាតិភាគច្រើន[១០៥] ហើយការចេះដោយអ្នកមួយចំនួនតូចដែលឈប់ប្រើវាហើយនោះ ហាក់ដូចជានឹងផ្តល់គ្មានការវិវត្ត[១០៦]។

- ភាសាព័រ[១០៧]។ ភាសានេះស្ថិតក្នុងស្ថានភាពមួយដែលអាចប្រៀបធៀបទៅនឹង

---

[១០៣] ជាតិពិន្ទុស្អូចនិងជង (ភាសាពួកគេអានថា ជូអ៊ុង) ត្រូវបានគេរកឃើញនៅសំរោងលើ ស្រុកវាលរេញខេត្តកំពត ហើយពេលបច្ចុប្បន្ន មានចំនួនតិចជាងមួយរយនាក់ដែលក្នុងនោះមាន ជាងសាមសិបនាក់ដែលចេះភាសារបស់ខ្លួននៅឡើយ។

[១០៤] ស្តីពីប្រធានបទនេះ យើងអាចពិគ្រោះការងារមួយចំនួន : (Cabaton, 1905 Headley, 1977, 1978; Filippi, 2000 Ueda et Okada, 2003)។

[១០៥] ជាការពិតណាស់ បើគេលើកលែងស្តុកវចនសព្ទដ៏ច្រើនដែលមានប្រភពកម្ចីពីភាសាខ្មែរក្នុងពេលជាច្រើនសតវត្ស ប៉ុន្តែវាចាំបាច់ត្រូវបញ្ជាក់ថា ស្ថានភាពនេះគ្មានអ្វីពិសេសចំពោះភាសា ស្អូចនោះទេ ហើយថាភាសាអូស្ត្រូ-អាស៊ីជាច្រើននៃតំបន់នេះមានមូលដ្ឋានវចនសព្ទខ្ចីពីភាសាខ្មែរ ហើយប្រការនេះអាចរំខានអភិក្រមនៃការស្ថាបនាឡើងវិញនូវភាសាដើមនៃក្រុម ផ្សេងៗ។

[១០៦] យើងគិតថាយើងនៅអាចប្រើចំណេះដឹងនេះដើម្បីសរសេរវេយ្យាករណ៍អត្ថាធិប្បាយដែលរហូតមកដល់ពេលនេះមិនទាន់មាននៅឡើយ។

[១០៧] តាមពិជាភាសាពៀរនៅកំពង់ធំ (តាមពិត សព្វថ្ងៃក្នុងខេត្តព្រះវិហារ) ជាភាសារបស់ជាតិពិន្ទុដែលមានឈ្មោះដូចគ្នានេះ ហើយដែលរស់នៅក្នុងភូមិបី ចន្លោះកំពង់ធំនិងត្បែងមានជ័យ។ ចំនួនប្រជាជននៃជាតិពន្ធុនេះប្រែប្រួលខ្លាំងណាស់ ដោយអាស្រ័យតាមប្រភព។ ចំពោះ យើង យើងប៉ាន់ប្រមាណថា មានតិចជាង៣០០នាក់។

ភាសាស្អួច ចំពោះលក្ខណៈដែលថាវាលែងជា ភាសាប្រាស្រ័យទាក់ទងគ្នាទៀតហើយ ប៉ុន្តែអាចនៅមានមនុស្សជំនាន់មុនចេះនិយាយនៅឡើយ ហើយក្នុងន័យនេះវាអាចជាកម្មវត្ថុនៃការពិពណ៌នាមួយ ។

**២.៣.២.សំណេរនៃភាសាជនជាតិភាគតិច**

យើងអាចបែងចែកស្ថានភាពពីរប្រភេទ :

- ករណីដែលជនជាតិភាគតិចមានតាំងពីពេលយូរមកហើយ នូវប្រព័ន្ធសំណេរដោយឡែកមួយ ។
- ការបង្កើតតាំងពីសម័យអាណាព្យាបាលបារាំង នូវប្រព័ន្ធសំណេរនៅលើមូលដ្ឋាននៃអក្សរឡាតាំងហើយនៅពេលឥឡូវនេះ នៅលើមូលដ្ឋាននៃអក្សរខ្មែរ ។

ភាពខុសគ្នារវាងចំណាត់ថ្នាក់ទាំងពីរនេះ មិនសូវដាច់ណាត់ទេ ព្រោះប្រសិនបើគេលើកលែងអក្សរចិនចេញ សំណេរ នៃឧបទ្វីបអាស៊ីអាគ្នេយ៍មានប្រភពចេញពីការកែសម្រួលសំណេរឥណ្ឌាតាំងពីសតវត្សដំបូងនៃគ្រឹះសករាជឬក្រោយនេះ ដូចជាក្នុងករណីនៃប្រភេទសំណេរម៉ាឡេគឺមានប្រភពមកពីអារ៉ាប់ ។

ដោយមានបំណងសម្រួលបញ្ហា យើងកំណត់យកពេលដំបូងនៃសម័យអាណាព្យាបាលបារាំងដើម្បីពិនិត្យមើលពីភាព ខុសគ្នារវាងសំណេរទាំងពីរប្រភេទនេះ ។

**២.៣.២.១.សំណេរបុរាណ**

**២.៣.២.១.១.សំណេរចិន**

ករណីនៃសំណេរចិនមានភាពស្មុគស្មាញជាងគេ ។ តាំងពីដើមហើយជាផ្លូវការណ៍

រហូតដល់សព្វថ្ងៃ តួអក្សរចិន[១០៨] ត្រូវបានប្រើដើម្បីសរសេរភាសាពីរ : ចិនកុកងឺ[១០៩] និងចិនកន្តាំង[១១០] ។

បញ្ហាសំណេរនៃក្រុមភាសាចិនដទៃទៀត ដោយប្រើតួអក្សរចិនមិនត្រូវបានគេយកចិត្តទុកដាក់នោះទេ ។ ដូចនេះ នៅពេលគេសរសេរសញ្ញាបញ្ចេញសំលេងដើម្បីបង្រៀន[១១១] ភាសាហុកកៀននិងចិនខិ គេចូលចិត្តប្រើប្រព័ន្ធកត់ត្រាបែប ឡាតាំងដែលផ្អែកលើរចនាសម្ព័ន្ធសទ្ទវិទ្យានៃភាសា[១១២] ទាំងនេះ ហើយដែលខុសពីរចនា សម្ព័ន្ធនៃភាសាកុកងឺយ៉ាងខ្លាំង ។

នៅក្នុងករណីនៃកម្ពុជា គេឃើញមាន ដូចជានៅមុខហាង នូវស្លាកយីហោដែលសរសេរជាតួអក្សរដែលអានដូចភាសា ចិនកន្តាំងនិងទាជីវ ដូចដែលមានការកត់ត្រាសូរឡាតាំងជាសក្ខីភាពស្រាប់ ។មានការសាកល្បងខ្លះៗក្នុងការសរសេរភាសាចិនទាជីវដោយប្រើតួអក្សរចិនកុកងឺ[១១៣] ប៉ុន្តែមិនបានជោគជ័យ[១១៤] ។

---

[១០៨] យើងប្រើពាក្យមួយដែលមានអព្យាក្រិត្យភាព « តួអក្សរ » ដើម្បីចៀសវាងភាពចម្រូងចម្រាស់ទាក់ទងទៅនឹងប្រភេទនៃសំណេរនេះ ។ ភាពចម្រូងចម្រាស់នោះសំដៅទៅលើការប្រើ ពាក្យ « គំនូសគំនិត » ឬ «រូពសញ្ញា » ឬ « សំណេររូបសញ្ញាព្យាង្គ » ។ល។ (Creel, 1936; Boodberg, 1937; DeFrancis, 1990; Vandermersch, 1994)

[១០៩] និយាយអោយច្បាស់គឺ ភាសានិយាយនៃប្រទេសចិនខាងជើងបានបង្កើតរចនាសម្ព័ន្ធនៃភាសារួមមួយ (Putonghua) ឬភាសាជាតិមួយ (Guoyu) ។

[១១០] សញ្ញាបន្ថែមខ្លះទៀតត្រូវបានបង្កើតឡើងក្នុងភាសាចិនកន្តាំងដើម្បីសំដែងទស្សនាទានដែលប្រព័ន្ធតួអក្សរចិនបុរាណមិនអាចសំដែងបាន ។

[១១១] ដូចករណីនៅតៃវ៉ាន់និងសង្ហបុរី ។

[១១២] គួរកត់សម្គាល់ថា ប្រព័ន្ធព្យាង្គនិងអក្សរដែលបានបង្កើតឡើងសម្រាប់កត់ត្រា ការបញ្ចេញសម្លេងភាសាចិនកុកងឺមិនត្រូវបានយកទៅអនុវត្តចំពោះភាសាចិនដទៃទៀតទេ ។

[១១៣] យើងជាសាក្សីនៃការសាកល្បងមួយចំនួនក្នុងការសរសេរចិនទាជីវដោយប្រើអក្សរចិនកុកងឺនៅភ្នំពេញនិងនៅស្រុកស្អាង (ខេត្តកណ្តាល)

មួយផ្នែកធំ អ្នកផ្តល់ព័ត៌មានរបស់យើងគិតថា ការចេះអក្សរចិននៅលើមូលដ្ឋានចិនកុកងឺមានសារៈសំខាន់និងគ្រប់ គ្រាន់ហើយ[១១៥] ។

មួយផ្នែកតូចនៃអ្នកផ្តល់ព័ត៌មានចិនទាជីវរបស់យើងបានប្រកាសប្រាប់យើងថាចង់ចេះអាននិងសរសេរភាសារបស់គេ ។ ហេតុនេះកិច្ចពិភាក្សានៅបើកចំហ ហើយអាស្រ័យទៅលើជម្រើសដែលសហគមន៍ចិន-ខ្មែរប្រកាន់យកក្នុងពេលអនាគត ។ លទ្ធភាពជាយថាភាពអាចមានដូចខាងក្រោម :

- បង្រួមការប្រើប្រាស់សំណេរត្រឹមសំណេរចិនកុកងឺតែមួយគត់ ។
- បង្កើតប្រព័ន្ធសំណេរភាសាចិនទាំងអស់នៅកម្ពុជា ដោយផ្តើមចេញពីសំណេរអក្សរចិន ។
- បង្កើតប្រព័ន្ធសំណេរចេញពីតួអក្សរឡាតាំង ខ្មែរ[១១៦] ឬពីតួអក្សរដទៃទៀត ។

### ២.៣.២.១.២.សំណេរប្រើសម្រាប់ភាសាចាម

ភាសាចាម ទោះជាមានការសរសេរតិចតួចនាពេលបច្ចុប្បន្នក៏ដោយ ក៏មានសំណេរពីរបែបដែរ : សំណេរមួយដែល ហៅថា *ចាវី* មានប្រភពពីតួអក្សរអារ៉ាប់ដូចដែលបានប្រើសម្រាប់កត់ត្រាភាសាម៉ាឡេ ។ សំណេរនេះត្រូវបានប្រើប្រាស់ដោយ

---

[១១៤] ហេតុផលគឺសាមញ្ញបំផុត ហើយបណ្តាលមកពីការណ៍ដែលតួអក្សរចិនដែលផ្ទុយពីការយល់ឃើញទូទៅ មិនឆ្លុះបញ្ចាំងពីការពិតនៃទស្សនាទានឯករាជ្យនៃភាសាទេ ប៉ុន្តែបកប្រែពីរូប បង្កប់នូវអត្ថន័យនិងជាពិសេសបង្កប់សូររបស់ចិនកុកងឺផ្ទាល់ (Boodberg, 1937 ; DeFrancis,1990).

[១១៥] គឺអ្វីដែលកំពុងកើតមាននៅសាលាភាសាចិននៅកម្ពុជាសព្វថ្ងៃ ។

[១១៦] មានសៀវភៅសន្ទនាភាសាចិនទាជីវដោយសូរសម្លេងសរសេរជាខ្មែរលក់នៅភ្នំពេញ ប៉ុន្តែសម្លេងសរសេរជាភាសាខ្មែរមានលក្ខណៈប្រហាក់ប្រហែលមិនត្រូវនឹងប្រព័ន្ធដែលមានស្រាប់ ទៅតាមរចនាសម្ព័ន្ធអំណាននិងសម្លេងឡើងចុះនៃភាសាចិនទាជីវ ។

ជនជាតិចាម ហៅថា *ម៉ាឡាយូ* ដែលជាក្រុមភាគច្រើន (ជាង ៨០ %)នៅក្នុងសហគមន៍ចាម ។

គេពិបាកនឹងដឹងថាតើនរណាប្រើសំណេរនេះ ហើយប្រើក្នុងឱកាសណានោះ ព្រោះយើងបាន ឃើញមានវត្តមានដ៏តិច តួចនៃអត្ថបទចាមដែលសរសេរតាមសំណេរនេះ ។ យើងក៏គ្មានស្ថិតិជាក់លាក់ស្តីពីកម្រិតអក្ខរនីយកម្មជាភាសាចាម ហើយយើងក៏គ្រាន់តែបានឃើញនូវគំនិតផ្តួចផ្តើមតិចតួចតែប៉ុណ្ណោះ ។

ទោះយ៉ាងណាភាសាចាមនៅតែអាចសរសេរបាន យ៉ាងសុក្រិតដោយមធ្យោបាយនេះ ហើយអ្នកផ្តល់ព័ត៌មានមួយចំនួន បានប្រាប់យើងថា ចង់បានអក្ខរនីយកម្មមួយនៅលើមូលដ្ឋាននៃភាសាចាម ។ គួរបញ្ជាក់ថា សំណេរនេះត្រូវបានគេប្រើសម្រាប់សរសេរ ភាសាម៉ាឡេដែលប្រើដោយសហគមន៍ចាមដូចជាយាន នៃកម្មវិធីអប់រំដែលជាទូទៅមានអត្ថន័យសាសនាច្រើន ។

ការសិក្សាយ៉ាងពេញលេញមួយអាចជាការចាំបាច់ព្រោះយើងបានឃើញនៅក្នុងពេលអង្កេតរបស់យើងនូវប្រតិកម្មខ្លះៗស្តីពី បញ្ហាភាសាឬភាពអាក់អន់ស្រពន់ចិត្ត ។ ប្រការនេះហាក់ដូចជាបណ្តាលមកពី ជំនឿដែលចាក់ឫសយ៉ាងជ្រៅទៅក្នុងសហគមន៍ចាមដែលតាមរយៈជំនឿនោះគឺថា *ភាសាអភិជន* ដូចជាម៉ាឡេនិង អារ៉ាប់មានលក្ខណៈជាភាសាសរសេរ រីឯភាសាចាមគ្រាន់ តែភាសានិយាយប៉ុណ្ណោះ ។

វាមិនមែនដូចគ្នាទេ ចំពោះសំណេរទីពីរដែលមានប្រភពមកពីឥណ្ឌា[១១៧] ។ ជា

---

[១១៧] ភាសាចាមនិងភាសាខ្មែរជាភាសាទីមួយនៃឧបទ្វីបដែលត្រូវបានសរសេរ ។ ដូចភាសាខ្មែរដែរ គឺត្រូវជាក់ប្រភពនៃសំណេរចាមនេះនៅក្នុងបរិបទឥណ្ឌូនីយកម្មនៃឧបទ្វីប ។ សំណេរនេះ ត្រូវបានថែរក្សាដោយពួកចាមកាន់សាសនាហិណ្ឌូ ប៉ុន្តែក៏ត្រូវបានថែរក្សាដោយចាមកាន់សាសនាអ៊ីស្លាមខ្លះៗដែរ (តិចជាង២០% នៃចំនួនប្រជាជនចាមនៅកម្ពុជា) ដោយចាមសុទ្ធ ឬចាមកាត់ដែលប្រតិបត្តិអ៊ីស្លាមចំរុះ ។ ចំពោះប្រធានបទនេះសូមអាន Defeo(Defeo, 2005) ។

ពិសេស សំណេរនេះមានតែបញ្ញាវ័ន្តមួយ ចំនួនប៉ុណ្ណោះដែលចេះហើយច្រើនប្រើសម្រាប់ការអាន ឬការចម្លងអត្ថបទបុរាណ ជាជាងសម្រាប់សរសេរអត្ថបទដែលទាក់ទង ទៅនឹងជីវិតប្រចាំថ្ងៃ[១១៨]។ ក្មេងជំនាន់ក្រោយមានការចេះដឹងពីសំណេរនេះដោយមានកម្រិតតិចបំផុតហើយដែលមានមិន លើសពីបួនដប់អក្សរឡើយឬក៏យ៉ាងច្រើនបំផុតគ្រាន់តែចេះអានឃ្លាខ្លះៗប៉ុណ្ណោះ។

ប៉ុន្តែយើងអាចឃើញមាននៅក្នុងសហគមន៍ចាម សាមញ្ញហើយជាពិសេសក្នុងចំណោមក្មេងជំនាន់ក្រោយនូវចរន្តទាម ទារអត្តសញ្ញាណដ៏ខ្លាំងក្លាមួយដែលមិនឆ្លងតាមអ៊ីស្លាមអូតូដុកទេ ប៉ុន្តែ តាមការលើកស្ទួយនៃតម្លៃចាមពិតប្រាកដមួយ :

- ភាសាចាមដែលស្រដៀងនឹងភាសានៃអ្នកនាំពាក្យរបស់ព្រះត្រូវបានអ្នកខ្លះចាត់ទុកថាដូចគ្នាតែម្តង។
- ការប្រតិបត្តសាសនារបស់ចាមសាមញ្ញ។
- សំណេរ។

ដោយមានប្រតិកម្មទៅនឹងទម្រង់ខ្មែរូបនីយកម្មមួយចំនួន និងការផ្សព្វផ្សាយសាសនារបស់ចាមភាគច្រើននោះ គេឃើញមានយ៉ាងពិតប្រាកដនូវឆន្ទៈអះអាងពីតម្លៃវប្បធម៌ដែលគេយល់ថាមានលក្ខណៈជាចាម ដែលដំបូងបំផុតនោះគឺភាសា និងសំណេរនេះឯង។ គូសន្ទនា របស់យើងបានសំណូមពរជាឯកច្ឆន្ទនូវអក្ខរនីយកម្មមួយនៅលើមូលដ្ឋាននៃភាសាចាម។

---

[១១៨] យើងបានប្រមែប្រមូលអត្ថបទទាំងនេះជាច្រើនដែលស្តីពីបញ្ហាសាសនា ហើយនៅឆ្នាំ២០០៥ យើងបានចូលរួមក្នុងសិក្ខាសាលាមួយនៅក្នុងភូមិអូរឫស្សីដែលចាស់ៗនៅក្នុងសហគមន៍ បានចំណាយពេលជាងមួយសប្តាហ៍ដើម្បីចម្លងអក្សរ និងបង្កើតក្បួនសំណេរ។ យើងបានវិលទៅភូមិដដែលនោះនៅឆ្នាំ២០០៧។

### ២.៣.២.២.ទស្សនាទានសំណេរសម្រាប់ភាសាជនជាតិភាគតិច

#### ២.៣.២.២.១.សំណេរឡាតាំង

ពិតមែនហើយ យើងមិនមែនមានន័យថាចង់ធ្វើរ៉ូម៉ាំងនីយកម្មទេ ព្រោះការប្រើពាក្យនេះគឺសំដៅតែទៅលើការប្រើ ប្រាស់តួអក្សរឡាតាំងសម្រាប់ភាសាដែលមានសំណេរ[១១៩] រួចទៅហើយនោះទេ។ ក្នុងផ្នែកនេះយើងគិតអំពីសំណេរបង្កើត សម្រាប់ភាសាដែលមិនធ្លាប់មានអក្សរសរសេរពីមុនមក។

ប្រព័ន្ធសំណេរទាំងអស់បង្កើតឡើងនៅសម័យអាណាព្យាបាលបារាំង ត្រូវបានបង្កើតនៅលើមូលដ្ឋាននៃតួអក្សរវៀតណាម[១២០] ជាមួយការបន្ថែមសញ្ញាផ្សេងៗដើម្បីតំណាងអោយសូរផ្សេងៗដែលមាននៅក្នុងភាសាទាំងនោះ។

ប្រព័ន្ធសំណេរទាំងនេះ មានការវិវត្តជារឿយៗនៅក្នុងអំឡុងពេលជាច្រើនឆ្នាំ ដោយសម្របទៅនឹងសទ្ទវិទ្យានៃភាសា ដែលត្រូវយកប្រព័ន្ធនេះទៅអនុវត្ត ហើយស្ថានភាពនេះ ហាក់ដូចជាមិនចោទជាសេចក្តីកង្វល់បឋមដល់អ្នកបង្កើត[១២១] វាឡើយ។

---

[១១៩] ឧទាហរណ៍ករណីភាសាវៀតណាម។ សម្រាប់រ៉ូម៉ាំងនីយកម្ម សូមអាន Palmer (Palmer, 1931)

[១២០] គឺជាតួអក្សរវៀតណាមទំនើបដូចដែលបានច្នៃបង្កើតដោយ Alexandre de Rhodes ហើយដែលត្រូវបានប្រើជាផ្លូវការសម្រាប់សរសេរភាសាវៀតណាម ចាប់តាំងពីមានសេចក្តី សម្រេចរបស់អគ្គទេសាអភិបាលចុះថ្ងៃទី២ខែធ្នូ ឆ្នាំ១៩៣៥។

[១២១] Hoeffel សង្ខេបបានយ៉ាងល្អនូវស្ថានភាពនេះ នៅពេលដែលគាត់សរសេរជុំវិញរឿងអក្ខរាវិរុទ្ធរបស់ Biat : «សរុបសេចក្តីមករបៀបកត់ត្រាសញ្ញាសម្លេងផ្លូវការភាសា Biat មាន លក្ខណៈមួយដែលសម្បូរព្យញ្ជនៈនិងខ្វះស្រៈ។ ផលអវិជ្ជមាននេះប្រហែលជាអាចចៀសវាងបានប្រសិនបើកម្ពុជាត្រូវបានគេហៅឱ្យចូលរួមក្នុងការបង្កើតប្រព័ន្ធនេះ។ ប្រព័ន្ធផ្លូវការដំបូងឡើយជាស្នាដៃអាណាម ចំនែកយើងវិញជឿថាអាចផ្តល់ យោបល់ដែលផ្អែកលើចំណេះដឹងជ្រៅជ្រះរបស់យើងទាំងភាសាអាណាមទាំងភាសាខ្មែរ ហើយយើងជឿថា ការសិក្សាមុន១ពីភាសា ខ្មែរជាការត្រៀមរៀបចំដ៏ប្រសើរមួយសម្រាប់សិក្សាភាសា Biat... » (Hoeffel, 1936)។

ទោះបីជាគេមានឯកសារសរសេរតែបន្តិចបន្តួចក៏ដោយ ក៏វាហាក់ដូចជាភាសាព្នង (Biat)ចារាយ ទំពួន និងប្រាវនៅ កម្ពុជាបានទទួលផលប្រយោជន៍ពីឯកសារនេះដែរ ។ សំណេរទាំងនេះត្រូវបានប្រើក្នុងករណីមួយចំនួនជាឧបករណ៍នៃអក្ខរនីយកម្មម្តងម្កាលដែលបានធ្វើឡើងដោយអាចារ្យសាសនា[១២២] ហើយប្រវត្តិសាស្ត្ររបស់គេសក្តិសមនឹងត្រូវបានសិក្សា ។ នៅពេលបច្ចុប្បន្ន មានមនុស្សមួយចំនួនតូចក្នុងខេត្តមណ្ឌលគីរីនិងខេត្តរតនគីរីតែប៉ុណ្ណោះដែលចេះប្រើសំណេរទាំងនេះ ។

### ២.៣.២.២.២.ការបង្កើតតួអក្សរលើមូលដ្ឋាននៃអក្សរខ្មែរ

#### ២.៣.២.២.២.១.កាលប្រវត្តិ

ការបង្កើតប្រព័ន្ធសំណេរលើមូលដ្ឋានអក្សរខ្មែរមានតាំងពីបំណាច់ឆ្នាំ៩០ ។ មុននឹងគិតដល់ការដាក់ឱ្យមានកម្មវិធី អក្ខរនីយកម្មអ្នកស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានគ្រោងទុកជាស្រេចនូវការសិក្សាភាសាមួយចំនួនរបស់ជាតិ ពន្ធុភាគតិចពេលនោះត្រូវលើកសំណើស្តីពីការពិពណ៌នាផ្នែកសូរវិទ្យា សទ្ទវិទ្យា និងផ្នែកសម្ព័ន្ធមុននឹងការបង្កើតប្រព័ន្ធសំណេរ[១២៣] ។ ប្រព័ន្ធសំណេរដំបូងត្រូវបានបង្កើតឡើងសម្រាប់ភាសាមួយចំនួនដូចតទៅ : ចារាយ ប្រាវ ទំពួន និងព្នង ។

ដំណាក់កាលក្រោយមកទៀតគឺ សំដៅទៅបង្កើតកម្មវិធីបង្រៀននៅលើគំរូដូចតទៅ : ការបង្កើតកម្មវិធីសិក្សាជា ភាសាអ្នកស្រុកមួយសម្រាប់រយៈពេលបីឆ្នាំជាមួយការឈានទៅរកភាសាខ្មែរបន្តិចម្តងៗ មានន័យថាអក្ខរនីយកម្មជាភាសា

---

[១២២] ចំពោះប្រធានបទនេះយើងបានសួរនាំអ្នកស្រុកក្នុងខេត្តមណ្ឌលគីរី ។

[១២៣] ប្រការនេះបាននាំទៅដល់ការបោះពុម្ពផ្សាយដំបូងមួយចំនួនស្តីពីភាសាព្នង (Filippi et Vogel, 1997; Filippi, 2000) ស្តីពីទំពួនសូមអាន Crowley (Crowley, 2000)

ជនជាតិភាគតិចស្របនឹងការរៀនភាសាខ្មែរ ។ កម្មវិធីទីមួយត្រូវបានដកចេញដោយអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះ Care[១២៤] នៅឆ្នាំ២០០៣ ដោយមានកិច្ចសហការជាមួយក្រសួងអប់រំនៃប្រទេសកម្ពុជា និងបន្តចាប់ពីឆ្នាំ២០០៥ មានកម្មវិធីផ្សេងៗទៀតដែលរៀបចំឡើងដោយមានការចូលរួម ពីសំណាក់ក្រសួងអប់រំនៃប្រទេសកម្ពុជាអង្គការយូនីសេហ្វ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត ។ កម្មវិធីទាំងនេះត្រូវបានអនុវត្តជាបឋមនៅផ្នែកពាយ័ព្យ ព្រោះជាតិពន្ធុភាគតិចនៅទីនោះមានចំនួនច្រើន ។ ប៉ុន្តែនៅឆ្នាំ២០០៦ ការងារទីមួយត្រូវបានធ្វើឡើងចំពោះភាសាកួយតាមរយៈការបកប្រែជា ភាសាកួយនូវ សៀវភៅ *ភាសាខ្មែរ* ឆ្នាំទីមួយនៃសាលាបឋមសិក្សា ។

### ២.៣.២.២.៣.ទស្សនាទាននៃប្រព័ន្ធសំណេរផ្សេងៗលើមូលដ្ឋានអក្សរខ្មែរ

#### ២.៣.២.២.៣.១.ការលំបាកទាក់ទងនឹងការប្រើអក្សរខ្មែរ

ការរៀនសរសេរខ្មែរមានភាពស្មុគស្មាញ ហើយដូចករណីសំណេរជាច្រើនទៀតដែរ ការលំបាកគឺបណ្ដាលមកពីការ ប្រឈមរវាងលំនឹងតួអក្សរនិងការវិវត្តផ្នែកសូរ ។

ដោយមិនចូលជ្រៅទៅក្នុងសេចក្ដីលម្អិត យើងអាចលើកយកឧទាហរណ៍មួយចំនួនដែលឆ្លុះបញ្ចាំងពីការលំបាកទាំង នេះ ។

- ស៊េរីព្យញ្ជនៈ

កាលពីដើម ចាប់ពីសិលាចារិកបុរេអង្គរនិងអង្គរខ្មែរមានភាពប្រឈមរវាងស៊េរីឃោសៈនិងស៊េរីអឃោសៈ[១២៥] ។

[១២៤] គេអាចឃើញការពិពណ៌នាពិស្ដារពីចំណុចនេះនៅក្នុងស្នាដៃរបស់ Norlander (Norlander, 2003) ។

[១២៥] ឃោសៈគឺគ្រប់ព្យញ្ជនៈបង្កើតឡើងដោយមាន រំញ័រ ប្រដាប់បន្លឺសំឡេងដូចក្នុងភាសាបារាំង : b d ។ល។ ហើយអឃោសៈគ្រប់ព្យញ្ជនៈបង្កើតដោយគ្មានរំញ័រប្រដាប់បន្លឺសំឡេងដូច ក្នុងភាសាបារាំង : p t ។ល។

| សំណេរខ្មែរ[១២៦] | សំណេរ |
| --- | --- |
| ត ទ | t d |
| គ | k g |
| ច ជ | c ɟ |

ចាប់តាំងពីសតវត្សទី១៥មក ការផ្លាស់ប្តូរដ៏ច្រើនបានកើតមាន :

ត ទ > t

ក គ > k

ច ជ > c

ការផ្លាស់ប្តូរពីព្យញ្ជនៈឃោសៈទៅជាព្យញ្ជនៈអឃោសៈធ្វើអោយលេចឡើងនូវទំរង់នៃ *សូរ មានខ្យល់*[១២៧] ហើយ បង្កើតឡើងនូវប្រព័ន្ធស្រៈដ៏ស្មុគ្រស្មាញបំផុត[១២៨] ។

យើងធ្វើតំនូសតាងខាងក្រោមនេះ ដើម្បីបញ្ជាក់ពីឧទាហរណ៍នៃការផ្លាស់ប្តូរដោយវិភាគសូររបស់ពាក្យ *ទា* ហើយ ដោយសម្រួលវាខ្លះៗ[១២៩] :

---

[១២៦] យើងប្រើអក្សរសម័យបច្ចុប្បន្ន ប៉ុន្តែរឿងនេះគ្មានសារៈសំខាន់សម្រាប់សំណើយើងនាពេលនេះទេ ។

[១២៧] គឺជាប្រភេទនៃសូរដែលបានកំណត់តាមរបៀបទំនាក់អារម្មណ៍ដូចជាសម្លេងចេញពីផ្ទះ (Henderson, 1952) ។ បើប្រៀបធៀបគឺជាទម្រង់មួយនៃសូរប្រើញឹកញាប់ក្នុងភាសាបារាំង ដើម្បីបង្ហាញពីការភ្ញាក់ផ្អើលខ្លាំង ហើយការ ប្រើនោះច្រើនមានលក្ខណៈជារចនាបទ ។ នៅក្នុងភាសាដែលយើងបានលើកឡើងខាងលើនេះ ការបង្កើតឱ្យមានសូរ បែបនេះចូលទៅក្នុងការផ្ទុយគ្នារវាងសូរធម្មតា /សូរមានខ្យល់ នេះមានន័យថាវាមានតួនាទីតែក្នុងផ្នែកភាសាប៉ុណ្ណោះ ។ សម្រាប់ សេចក្តីពិស្តាសូមអាន Diffloth (Diffloth, 1982); ចំពោះការសិក្សាអំពីសូរ វិទ្យាពិស្តារសូមអាន Filippi et Hiep, (Filippi, 2007; Filippi et Hiep, 2007). ។

[១២៨] គឺអ្វីដែលយើងហៅថា «បណ្តុំរមនខ្មែរ» ។ សម្រាប់សេចក្តីពិស្តារសូមអាន Diffloth, (Diffloth, 1982) ។

[១២៩] សម្រាប់សេចក្តីពិស្តាសូមអាន Filippi, (Filippi, 2007)

| សម័យកាល I | សម័យកាល II | សម័យកាល III |
| --- | --- | --- |
| da: | d̤ɛa | tiɜ |

ចំណុចពីរនៅក្រោមពាក្យ [d̤ɛa]បញ្ជាក់ថា ជាសូរមានខ្យល់ ។

ភាគច្រើននៃភាសាជនជាតិភាគតិចពាយ័ព្យមានសូរមានខ្យល់ដែលបានបាត់បង់នៅក្នុងភាសាខ្មែរស្តង់ដា[១៣០] ប៉ុន្តែមាននៅក្នុងភាសាពួង[១៣១]និងទំពួន[១៣២] ។ ឃោសភាពនៃព្យញ្ជនៈបានបាត់បង់ក្នុងភាសាខ្មែរទំនើប ប៉ុន្តែវាត្រូវបានរក្សាទុកនៅក្នុង ភាសាស្ទៀង[១៣៣] និងរក្សាទុកខ្លះក្នុងភាសាប្រាវ[១៣៤] ។ ដើម្បីយល់ច្បាស់ពីភាពខុសគ្នាផ្នែករចនាសម្ព័ន្ធ គេបានប្រើបញ្ជី សារពើភណ្ឌសម្បូរបែបនៃអក្សរពុម្ពខ្មែរឬគេបានបង្កើតសញ្ញាថ្មីៗទៀត[១៣៥] ។

- ក្រុមព្យញ្ជនៈ

ភាសាខ្មែរមានក្រុមព្យញ្ជនៈច្រើននៅដើមព្យាង្គ ក្រុមព្យញ្ជនៈសរសេរដោយដាក់ត្រួតជើងព្យញ្ជនៈនៅក្រោមព្យញ្ជនៈ ទីមួយ ហើយជើងព្យញ្ជនៈនេះតំណាងឱ្យព្យញ្ជនៈទីពីរនៃក្រុមនេះ ។

---

[១៣០] ផ្ទុយទៅវិញគេឃើញមានសូរបែបនេះនៅក្នុងក្រុមភាសាក្បែរខាងផ្សេងៗ (Thongkum, 1988)

[១៣១] សម្រាប់សេចក្តីផ្តើមនៃភាសាពួងសូមអាន Vogel និង Filippi, (Vogel et Filippi, 2007)

[១៣២] សម្រាប់ការពិពណ៌នាពីសទ្ទវិទ្យាទំពួន សូមអាន Crowley, (Crowley, 2000)

[១៣៣] សម្រាប់ការពិពណ៌នាផ្នែកវេយ្យាករណ៍ស្ទៀងសូមអាន Miller, (Miller, 1976) ។

[១៣៤] សម្រាប់ការពិពណ៌នាផ្នែកវេយ្យាករណ៍ប្រាវ សូមអាន Keller, (Keller, 1976)

[១៣៥] គឺជាដំណោះស្រាយដែលត្រូវបានជ្រើសរើសសម្រាប់កត់ត្រាសំឡេង [g] នៃភាសាប្រាវ (Kreung), (Keller, 2003) ។

ភាសាជនជាតិភាគតិច ក៏មានក្រុមព្យញ្ជនៈដែរដែលភាគច្រើនខុសពីក្រុមព្យញ្ជនៈនៃភាសាខ្មែរ។ ភាសាពួងមាននៅ ដើមព្យាង្គនូវក្រុមព្យញ្ជនៈដូចតទៅ n + k ; n + t ; m +b ។ល។ ដែលមិនមាននៅក្នុងភាសាខ្មែរទេ។ សំណួរចោទសួរថា តើត្រូវសរសេរក្រុមព្យញ្ជនៈទាំងនេះយ៉ាងដូចម្ដេច? ករណីខ្លះត្រូវបានដោះស្រាយដោយត្រូវត្រួត ព្យញ្ជនៈ ហើយក្នុងករណីខ្លះទៀតត្រូវដាក់ព្យញ្ជនៈក្នុងទីតាំងជាប់គ្នា។

សេចក្ដីផ្ដើមដ៏សាមញ្ញចំពោះការលំបាក ដែលកើតឡើងដោយការប្រើសំណេរខ្មែរនេះ មិនមែនគ្មានន័យនោះទេ ទោះបី វាជារឿងលឿនបន្តិចក្នុងការធ្វើកិច្ចការនេះក៏ដោយ ក៏បញ្ហានៃការវិវត្តប្រព័ន្ធសំណេរនេះនឹងកើតមាននៅថ្ងៃណាមួយ :

- ប្រព័ន្ធទាំងនេះត្រូវបានបង្កើតឡើងក្នុងពេលភ្លាមៗនេះ ដើម្បីអោយមានអក្ខរនីយកម្មដំបូងហើយអាចនឹងប្រើក្នុងការ សរសេរនាពេលអនាគតនូវអត្ថបទពេញលក្ខណៈ មានន័យថា សហគមន៍ត្រូវចេះប្រព័ន្ធនេះក្នុងក្របខ័ណ្ឌក្រៅសាលា?

- នៅក្នុងពេលសិក្សាបីឆ្នាំដំបូង គេគ្រោងអោយរៀនភាសាខ្មែរបន្តិចម្ដងៗ ក្រៅពីអក្សរដែលស្ទើរតែដូចគ្នាទាំងស្រុងនោះ គោលការណ៍សំណេរភាសាខ្មែរ និងគោលការណ៍សំណេរបង្កើតថ្មីខុសគ្នា តើប្រការនេះមិននាំអោយមានភាពច្រឡំទេឬយ៉ាងណា?

- បញ្ហាសាមិតភាពនៃប្រព័ន្ធនេះជាមួយយូនីកូដខ្មែរនឹងអាចចោទឡើងផងដែរ។

### ២.៣.២.២.៣.២.សំណេរនិងបញ្ហាបម្រែបម្រួលភាពនៃគ្រាមភាសា

គេមានទម្លាប់នៅអឺរ៉ុបខាងលិចក៏ដូចជានៅកម្ពុជាទៅនឹងភាពច្រឡំគ្នារវាងសណ្ឋានភាសាដែលកន្លងមករាប់សតវត្ស គេហៅថា *ភាសាជាតិ* និងសញ្ញាណទូលំ

ទូលាយនៃ *ភាសា* ដែលគ្របដណ្ដប់រួមភាសានិយាយ រួមទាំងគ្រាមភាសាទាំងអស់ដែលយល់គ្នាទៅវិញទៅមកក្នុងកម្រិតផ្សេងៗគ្នា ។

នៅក្នុងករណីនៃភាសាជនជាតិភាគតិចដែលរហូតមកដល់ពេលនេះ គ្មានឬមានការសរសេរតិចតួច វាគ្មានទម្រង់ឯកភាពដែលអាចបង្កើតជាមូលដ្ឋាននៃសំណេរមួយ[១៣៦] ទេ ។

គេអាចអះអាង ដោយហេតុថា ជានិច្ចកាល សំណេរកើតពីសិប្បនិម្មិតកម្មមួយដែលគិតតែពីបំណែកនៃទិដ្ឋភាសាណាមួយប៉ុណ្ណោះ ហើយការធ្វើវិទ្យាស្ថាននីយកម្មនូវប្រព័ន្ធសំណេរណាមួយនោះគឺចាំបាច់ត្រូវត្រឡប់ទៅប្រើហិង្សាមួយចំនួន ។ ទង្វើនេះគឺគេនឹងបំភ្លេចនូវហេតុការណ៍ចាំបាច់មួយ : ប្រសិនបើអភិក្រមនៅក្នុងការទទួលយកជាទ្រឹស្ដីនិងដោយមិនគិតពី ប្រវត្តិសាស្ត្ររបស់គេមានភាពជាសិប្បនិម្មិត នោះលក្ខខណ្ឌនៃការដាក់ឱ្យមានអភិក្រមនេះអាចបង្ហាញអព្យាក្រឹតភាពតិចឬ ច្រើន ហើយគេត្រូវបែងចែករវាង :

- ការបង្កើតបន្តិចម្ដងៗរាប់សតវត្សនូវប្រព័ន្ធសំណេរ ដែលតាមរយៈតម្រូវការ (រដ្ឋបាលអប់រំ ។ល ។) នឹងមានលំនឹងបន្តិចម្ដងៗ ហើយទីបំផុតនឹងបង្កើតជាបទដ្ឋានសំណេរមួយ[១៣៧] ។
- ការបង្ខំអោយភាសាមួយប្រើប្រព័ន្ធសំណេរភ្លាមៗ ។

---

[១៣៦] តាមពិតអ្វីដែលជំរុញឱ្យលេចចេញនូវបទដ្ឋានភាសាមួយគឺការភ្ជាប់គ្នានៃមជ្ឈការនយោបាយនិងប្រព័ន្ធ សំណេរ (Février, 1959, Gelb, 1963)

[១៣៧] នៅក្នុងវិស័យនេះទៀត គ្មានអ្វីដែលធ្វើទៅដោយគ្មានជម្លោះនោះទេ យើងគ្រាន់តែគិតទៅដល់ការជជែកគ្នាជាបន្តបន្ទាប់ក្នុងប្រវត្តិសាស្ត្រនៃអក្ខរាវិរុទ្ធបារាំងតាំងពីដើមសតវត្សទី១៩ មកនោះ យើងអាចយល់បានហើយ ។

ក្នុងករណីកម្ពុជានិងដើម្បីទប់ទិដ្ឋភាពសិប្បនិម្មិតនេះ មុននឹងបង្កើតសំណេរ មួយ ការអង្កេតលើគ្រាមភាសាវិទ្យាត្រូវ តែមានដើម្បីកំណត់ភាពត្រូវគ្នាខាងសូរសព្ទ និងសទ្ទតានៃគ្រាមភាសានានាដទៃទៀត។

ស្ថានភាពកាន់តែស្មុគស្មាញជាងការរំពឹងទុក ព្រោះការប្រកាសថាទម្រង់ភាសាពីរគឺជាគ្រាមភាសាពីរនៃភាសាតែមួយ មិនចោទបញ្ហាអ្វីលើលទ្ធភាពក្នុងការបង្កើតទម្រង់សំណេរតែមួយគត់ដែលអាចឱ្យយល់ពីគ្រាមភាសាទាំងពីរទេ។

យើងបានវិភាគការអង្កេតពីរក្នុងចំណោមការអង្កេតទាំងនោះ ដែលមួយផ្តោតទៅលើភាសាកួយ ហើយមួយទៀត ផ្តោតទៅលើភាសាប្រាវ។

ការសិក្សាដែលបានធ្វើទៅលើភាសាកួយ[១៣៨] ផ្តើមចេញពីការទទួលស្គាល់គ្រាមភាសាបី[១៣៩] ជាចម្បងរបស់ភាសាកួយ : គ្រាមភាសា នត្រា នត័រ និងម្ល៉ា ហើយស្នើឱ្យពិនិត្យទៅលើគម្លាតនៃភាសាទាំងនេះតាមរយៈកម្រងសំណួរទូទៅមួយ ការប្រៀបធៀបស្ថិតិវចនសព្ទ ការបង្កើតឡើងវិញផ្នែកសទ្ទតា និងការធ្វើតេស្តលើការយល់។ នៅទីបញ្ចប់នៃការសិក្សាអ្នកនិពន្ធ បានសន្និដ្ឋានថាគ្រាមភាសាកួយទាំងអស់យល់គ្នាច្រើន ហើយថាលទ្ធភាពនៃការបង្កើតប្រព័ន្ធសំណេរតែមួយ ដែលអាចប្រើបានដោយអ្នកនិយាយគ្រាមភាសាកួយ[១៤០] ទាំងអស់អាចទៅរួច។

[១៣៨] គឺជាសារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដែលត្រូវបានឡើងការពារដោយ Markowski ក្នុងឆ្នាំ ២០០៥។

[១៣៩] សម្រាប់សេចក្តីពិស្តារបន្ថែមទៀតសូមអាន Duffossé, (Duffossé, 1934) និង Lévy, (Lévy, 1943)។

[១៤០] «Using the findings of the current research and taking into account the sound rule change, it may be possible to create a single orthography for the Kuy speakers in Cambodia», P.133, (Markowski, 2005).

ការសិក្សាអំពីភាសាប្រាវ[១៤១] ប្រើវិធីអង្កេតដែលមានលក្ខណៈជាគ្រាមភាសាវិទ្យាសុទ្ធសាធ ពោលគឺបានប្រៀបធៀប ពាក្យចំនួន៣៨៣ ក្នុងអំបូរភាពខុសៗគ្នាចំនួន៨ ដែលចង្អុលបង្ហាញដោយពន្ទុនាមផ្សេងៗ តែសង្ស័យថាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងគ្នា។ លទ្ធផលនៃការសិក្សានេះបានពង្រឹងនិក្ខេបបទស្ដីពីចំណងទាក់ទងគ្រាមភាសារវាង អំបូរភាពខុសៗគ្នាទាំង នេះ។

ផ្ទុយពីការសាកល្បងបឋមនេះ អ្នកបកប្រែជាភាសាកួយនូវសៀវភៅ *ភាសាខ្មែរ* សម្រាប់ឆ្នាំទីមួយនៃ សាលាបឋមសិក្សា ហាក់គ្មានបារម្ភពីកំហិតនេះទេ ហើយអំណានផ្នែកមួយចំនួននៃអត្ថបទដែលយើងបានរៀបចំជាមួយជនជាតិកួយដែល និយាយគ្រាមភាសាទាំងពីរបានផ្ដល់លទ្ធផលដ៏គួរឱ្យអស់សង្ឃឹម។ អ្នកទាំងនោះជាអ្នកនិយាយភាសាកួយពីកំណើត ហើយបានរៀននៅលើមូលដ្ឋាននៃអក្សរខ្មែរ។ ពួកគេអានកំណត់ត្រាភាសារបស់ពួកគេជាភាសាខ្មែរមិនដាច់ក្រៅតែពីពាក្យពីរ បីរាយប៉ាយនៅក្នុងអត្ថបទ។

ក្រៅពីអវត្តមាននៃការគិតគូរដល់បម្រែបម្រួលភាពគ្រាមភាសា យើងគិតថាគ្មានការបង្កើតប្រព័ន្ធសំណេរមុនពេល ការសរសេរអត្ថបទទាំងនោះទេ។ តាមមើលទៅអត្ថបទទាំងនោះត្រូវបានសរសេរចេញពីឃ្លាកួយដែលចម្លងតាមពាក្យម្ដង មួយៗដោយប្រើអក្សរខ្មែរនិងដោយគ្មានការរៀបចំទុកជាមុន ដែលអាចអនុញ្ញាតឱ្យគេចម្លងបានត្រឹមត្រូវទៅតាមមូលដ្ឋាន នៃប្រព័ន្ធសូរភាសាកួយ។

[១៤១] គឺជាឯកសារ បើតាមយើងដឹងមិនដែលបានបោះផ្សាយទេ។

## ២.៤.បរិស្ថានភាសា

ពាក្យបង្កើតថ្មីនេះ[១៤២] និងទស្សនាទានដែលវាបានគ្របដណ្តប់ទាមទារនូវការពន្យល់មួយ។ គោលការណ៍មូលដ្ឋាននៃ ពាក្យនេះគឺជាគំនិតបច្ចេកទេស និងទ្រឹស្តីស្តីពីប្រភាសនិងភាសា[១៤៣] ដូច្នេះការកំណត់និងការញែកបាតុភូតភាសាឱ្យទៅជាទ្រឹស្តី នោះបានមកពីភាពចាំបាច់ផ្នែកនយោបាយ ក្នុងការផ្តល់នូវចក្ខុវិស័យនៃប្រភាសដល់អភិក្រមនៃការស្ថាបនាលំហសង្គមក្នុងក្រប ខណ្ឌប្រវត្តិសាស្ត្រណាមួយ។

ប្រការនេះអាចពន្យល់ថា សេចក្តីកង្វល់ពីការសិក្សាអំពីប្រភាស និងភាសាព្រមទាំងអំពីនិក្ខេបបទនិងកម្មវិធីស្រាវជ្រាវ ដែលជាផ្លែផ្កានោះគឺពិតជាខុសគ្នាដាច់ស្រឡះទៅតាមសម័យកាល :

- ភាពចាំបាច់នៃការបង្កើតទម្រង់បរិក្ខារ នៃការបញ្ចុះបញ្ចូលធ្វើឱ្យជឿជាក់ដែលដើមឡើយជាប្រយោជន៍ផ្នែកច្បាប់ = ការ លេចឡើងបន្តិចម្តង១នូវវោហារសាស្ត្រ។
- ការរីករាលដាលនយោបាយនិងសាសនាអឺរ៉ុប = វេយ្យាករណនីយកម្ម។
- ប្រវត្តិនីយកម្មនៃដំណើរវិទ្យាសាស្ត្រនិងវប្បធម៌ = ប្រដូចនិយម ។ល។

ដូច្នេះ បរិស្ថានភាសាអាចនឹងមានភារកិច្ចឆ្លុះបញ្ចាំងពីរយ៉ាង :

- លើកតម្លៃនិងវិភាគស្ថានភាពដែលទាមទារ នូវការសិក្សាពិសេសអំពីព្រឹត្តិការណ៍ភាសា។

---

[១៤២] សម្រាប់សេចក្តីពិស្តារស្តីពីទស្សនាទាននេះ អត្ថបទដៃទីមួយមាននៅក្នុងដៃអ្នកនិពន្ធរួចស្រេចហើយ នឹងត្រូវបោះផ្សាយក្នុងឆ្នាំ២០០៨ (Filippi, 2008)

[១៤៣] ភាសាវិទ្យាគ្រាន់តែជាផ្នែកមួយប៉ុណ្ណោះ។ កើតមានតាំងពីកំណែទម្រង់សាកលវិទ្យាល័យព្រុស នាដំណាច់សតវត្សទី១៩ (Auroux,1989) វាក្លាយជាវិស័យឆ្នើមនាសម័យបច្ចុប្បន្ន មានឈ្មោះថា *វិទ្យាសាស្ត្រភាសា* ដែលគ្មានទស្សនៈវិទ្យាសាស្ត្រសក្តិសមនឹងឈ្មោះនេះណាមួយអាចប្រៀបផ្ទឹមបាន។

- វិភាគភាពស្របគ្នានៃបច្ចេកវិទ្យាភាសា ទៅនឹងស្ថានភាពដែលនាំទៅដល់ការអនុវត្តបច្ចេកវិទ្យានេះ។

នៅសម័យបច្ចុប្បន្ន គេហាក់ដូចជាឃើញប្រធានបទមួយចំនួនមាននិន្នាការគ្របដណ្តប់ ហើយដូច្នេះនឹងក្លាយទៅជា បេក្ខជនសក្តានុភាពក្នុងការកែលម្អឡើងវិញនូវវិធីសាស្ត្រខាងភាសា ៖ វិវិធភាពនៃវប្បធម៌(ភាសា) ចំណោទបញ្ហានៃភាសាកំពុងរងគ្រោះ និងការធ្វើមានជីវិតរស់រានឡើងវិញ។

## ២.៤.១.ភាសាក្នុងសភាពរងគ្រោះនៅកម្ពុជា

### ២.៤.១.១.លក្ខខណ្ឌកំណត់

សញ្ញាណនៃ *ភាសាកំពុងរងគ្រោះ* ទើបតែមានថ្មីពេកមិនអាចធ្វើអោយទៅជាទ្រឹស្តីសមស្របណាមួយបានទេ យើង នឹងកាត់បន្ថយវិធីសាស្ត្ររបស់យើងមកនៅត្រឹមវាទរូបគោលដែលបន្តដោយការវិភាគពីស្ថានភាពកម្ពុជា។

ភាសាកំពុងរងគ្រោះជាសញ្ញាណមួយដែលឈរលើការកត់សម្គាល់ដូចតទៅ ៖ ក្នុងចំណោមភាសាចំនួន ៦ ៧០០[១៤៤] ដែលគេនិយាយនាពេលបច្ចុប្បន្ននៅលើផែនដី ៥០%ស្ថិតនៅក្នុងគំរាមកំហែង ទៅរកការបាត់បង់ពេលដ៏ខ្លី ៩៦%ត្រូវបាន និយាយដោយ៤%នៃប្រជាជនក្នុងពិភពលោកប៉ុណ្ណោះ ហើយរៀងរាល់ពីរសប្តាហ៍មានភាសាមួយបាត់បង់[១៤៥] ។

---

[១៤៤] ៦៧០០ជាតួលេខជ្រើសយកតាមបែបមជ្ឈតកម្មបន្តិច តាមពិតការវាយតម្លៃពេញនិយមជាងគេគឺពីអប្បបរមា៣ ០០០ ទៅអតិបរិមា៦ ៧០០។ សម្រាប់សេចក្តីពិស្តារសូមពិគ្រោះ គេហទំព័ររបស់អង្គការយូណេស្កូត្រង់ចំណុច Langues en danger ទិន្នន័យ «Ethnologue» ។

[១៤៥] គឺជាទិន្នន័យដែលមាននៅក្នុងគេហទំព័ររបស់អង្គការយូណេស្កូ ដែលនិយាយអំពីបេតិកភណ្ឌវប្បធម៌អរូបី។

ផ្តើមចេញពីលទ្ធផលនេះ មានការយកចិត្តទុកដាក់លើការគំរាមកំហែងចំពោះវិវិធភាពនៃវប្បធម៌និងចំណាប់ អារម្មណ៍ដែលថាភាសាគឺជាផ្នែកមួយនៃបេតិកភណ្ឌមនុស្សជាតិ[១៨៦] ។ ជាក់ស្តែង វាចាំបាច់ត្រូវកំណត់ យុទ្ធសាស្ត្រងាយតម្លៃ អំពីស្ថានភាពនៃភាសាផ្សេងៗ កម្មវិធីសកម្មភាពឈានឆ្ពោះទៅរកការសង្គ្រោះ និងការធ្វើឱ្យជីវិតរស់រានឡើងវិញ ព្រមទាំង ក្នុងករណីខ្លះគឺការដាក់ឱ្យមាននូវពិធីការនៃការពិពណ៌នាមួយដើម្បីចៀសវាងកុំឱ្យផ្នែកមួយនៃបេតិកភណ្ឌមនុស្សជាតិវិនាស សាបសូន្យទៅ ។

### ២.៤.១.២.ស្ថានភាពភាសានៅកម្ពុជា

ការពន្យល់អោយបានជាក់លាក់អំពីស្ថានភាពប្រភេទភាសានៅមានភាពលំបាកលំបិន ដោយហេតុថា យើងមាន សម្ភារៈឯកសារតិចតួច ។ នៅក្នុងអត្ថបទបន្តទៅនេះ យើងនឹងសាកល្បងកំណត់ស្ថានភាពគំរូខ្លះៗសម្រាប់បញ្ជាក់ពីទិដ្ឋភាព ភាសានៅកម្ពុជា ។

#### ២.៤.១.២.១. សញ្ញាណភាសាងាប់[១៨៧]

យើងចាត់ទុកភាសាមួយជាភាសាងាប់បន្ទាប់ពីអ្នកនិយាយចុងក្រោយស្លាប់បាត់

---

[១៨៦] ឯកសារស្តីអំពីភាសាក្នុងសភាពរងគ្រោះដែលនៅមានតិចតួចកាលពីជាងដប់ឆ្នាំមុន មានភាពសម្បូរក្នុងពេលអំណើះតទៅ បើចង់ដឹងសូមមើលគេហទំព័រជាច្រើនដែលនិយាយអំពីបញ្ហានេះ ដូចជា «L'atlas interactif des langnes en danger» នៅក្នុងគេហទំព័ររបស់អង្គការយូណេស្កូ ព្រមទាំងស្នាដៃដែល មានចំនួនច្រើនឡើងស្តីពីបញ្ហានេះ ដូចជា Hagège (Hagège, 1992, 2000) ។

[១៨៧] និរុត្តសព្ទមានភាពស្រពិចស្រពិលព្រោះគុណវឌ្ឍិនៃ *ភាសាងាប់* អនុវត្តទៅលើភាសាឡាតាំងដែលក្រោយពីលែងជាភាសាកំណើតនៃក្រុមមនុស្សណាមួយនោះនៅតែត្រូវបានបន្តប្រើ ប្រាស់រាប់សតវត្សសម្រាប់សរសេរអត្ថបទទស្សនៈវិជ្ជា រដ្ឋបាល ។ល។ និងដោយព្រះវិហារកាតូលិកផងដែរ ។ អ្នកនិពន្ធ (Saussure, 2002 ) មិនញញើតក្នុងការប្រកាសថា ភាសាឡាតាំងមិនស្លាប់ទេ ប៉ុន្តែបានប្តូរទៅជាភាសាបារាំង អ៊ីតាលី ។ល។ លើសពីនេះទៅទៀត មិនត្រូវបណ្តោយខ្លួនឱ្យយល់ច្រឡំលើអង្គទំហៀបន័យនៃពាក្យ *ភាសាងាប់* នោះឡើយ ព្រោះអ្នកនិយាយ ទេដែលស្លាប់មិនមែនភាសានោះទេ ។

ទៅ[១៨៨] ។ នៅកម្ពុជា យើងអាចលើកករណីនៃភាសាសំរ៉ែ[១៨៩] ដែលជាភាសាមួយក្នុងអំបូរអូស្ត្រូអាស៊ីនៃក្រុមពៀរិកដែលលោកមូរ៉ា (Moura, 1883) ថា មាននៅក្នុងខេត្តសៀមរាប ហើយដែលគាត់កត់ត្រាទុកបានជាង១៥ពាក្យ ។ ភាសានេះមិនត្រូវបានកំណត់ទីតាំងប្រកបដោយភាព ច្បាស់លាស់ទេ ព្រោះខេត្តសៀមរាបនាដំណាច់សតវត្សចុងក្រោយនេះ មានទឹកដីដែលពេលបច្ចុប្បន្ននេះស្ថិតនៅក្នុងខេត្ត កំពង់ធំ និងព្រះវិហារ ។ គ្រប់ការស្រាវជ្រាវដែលបានធ្វើនៅពេលនេះមិនអាចឱ្យរកឃើញទីតាំងភូមិឬអ្នកនិយាយភាសាសំរ៉ែ[១៩០] ទេ ហេតុនេះភាសានេះអាចកំណត់បានថាជាភាសាងាប់រហូតដល់ពេលណាមួយដែលមានភស្តុតាងផ្ទុយពីនេះ ។

**២.៥.១.២.២.ភាសាក្នុងសភាពរងគ្រោះជិតឈានទៅរកការបាត់បង់ទាំងស្រុង**

យើងដាក់បញ្ចូលទៅក្នុងកថាភាគនេះនូវភាសាដែលមានលក្ខណៈដូចតទៅ :

- អ្នកនិយាយក្មេងជាងគេមានអាយុលើសពី៤០ឆ្នាំ ។
- គ្មានការផ្ទេរទៅក្មេងជំនាន់ក្រោយ ។
- ចេះនិយាយតែដោយជនវ័យចំណាស់ ភាសាលែងជាមធ្យោបាយនៃការប្រាស្រ័យទាក់ទងគ្នានៅក្នុងសហគមន៍ដែលបានជំនួស ភាសានោះដោយភាសាផ្សេងទៀត ។

---

[១៨៨] ភាសាមួយចំនួនត្រូវបានពិពណ៌នានៅលើមូលដ្ឋានព័ត៌មានដែលផ្តល់ដោយអ្នកនិយាយភាសានោះចុងក្រោយគេ ដូចជាភាសា : ដាល់ម៉ាត់ កាម៉ាស់ អ៊ូបិក ។ល។

[១៨៩] សូមកុំច្រឡំជាមួយនឹងភាសាសំរ៉ែនៅភ្នំក្រវាញដែលជាភាសាពៀរិក (Baradat, 1941) ។

[១៩០] នៅតែមានអ្នកនិពន្ធខ្លះមិនរុញរាក្នុងការបង្ហាញភាសាសំរ៉ែនៅលើផែនទីដែលពន្យល់ពីស្ថានភាពភាសានៅកម្ពុជាសម័យទំនើប (Headley, 1977) នេះគឺជារឿងស្រមើលស្រមៃសុទ្ធ សាធ ។

- គ្មានទម្រសង្គមវប្បធម៌ (សាសនា ។ល។) ដែលអាចធ្វើឱ្យមានជីវិតរស់រានឡើងវិញបាន[១៥១] ។

នៅប្រទេសកម្ពុជា ភាសាពីរស្ថិតនៅក្នុងស្ថានភាពនេះ : ស្អូច និង ព័រ។ ភាសាទាំងពីរស្ថិតក្នុងក្រុមពៀរិកនៃអំបូរ អូស្ត្រូអាស៊ីដែលគេស្គាល់ក្រោមឈ្មោះ ជុង (ស្អូច) និងព័រនៃកំពង់ធំ ។

វាដូចជាមិនសមឡើយក្នុងការប្រើពាក្យ *អ្នកនិយាយ* ដើម្បីសំដៅទៅមនុស្សសាមសិបនាក់ប្លាយដែលចេះភាសាស្អូច និងសែសិបនាក់ប្លាយដែលចេះភាសាព័រ ព្រោះពួកគេបានប្រាប់យើងថាគ្មានឱកាសនិយាយភាសានេះតាំងពីដំណាច់ឆ្នាំ៧០ ហើយជាលទ្ធផលពួកគេមិនអាចធានាការបង្រៀនភាសាពួកគេទៅក្មេងជំនាន់ក្រោយបានទេ ។

នៅក្នុងជីវិតប្រចាំថ្ងៃ ពួកស្អូចប្រើភាសាខ្មែរ ហើយពួកព័រប្រើភាសាខ្មែរ និងភាសាកួយ ។

ដូចអ្វីដែលយើងបានបញ្ជាក់ជូនស្រាប់ ភាសាទាំងពីរនេះហាក់ដូចជាគ្មានការប៉ះពាល់គួរអោយឆ្ងល់ ហើយមានគេ ពិព័ណ៌នាអំពីភាសានេះ ។ ហាក់ដូចជាចំណេះភាសាទាំងនេះត្រូវបានគេឈប់ប្រើយ៉ាងតក់ក្រហល់ ដើម្បីបង្រួមមកត្រឹមសភាពភាសាដ៏មានអំណាចដែលនឹងលែងមានបច្ចុប្បន្នភាពតទៅទៀត ។

---

[១៥១] សូមកុំមើលស្រាលអោយសោះការធ្វើជីវិតនីយកម្មឡើងវិញ និយាយរួមគឺអាចធ្វើទៅរួចដូចជាករណីភាសា *ហេប្រឺ* ជាករណីលេចធ្លោបំផុត (Rosén, 1977) ប៉ុន្តែ យើងគិតថា នយោបាយនៃការធ្វើជីវិតនីយកម្មឡើងវិញអាចដំណើរការទៅបានតែក្នុងលក្ខខណ្ឌដែលសង្គមវប្បធម៌ (សាសនា ឆន្ទៈអភិរក្សបំណែបជីវិតពិសេសណាមួយ ។ល។ ) តម្រូវឱ្យមានការរក្សាទុកនូវភាសាមួយ ។

មូលហេតុនៃស្ថានការណ៍នេះ មានតាំងពីសម័យកម្ពុជាប្រជាធិបតេយ្យ ព្រោះអ្នកផ្តល់ព័ត៌មានបានប្រាប់យើងថា កម្មាភិបាលតំបន់នៃរបបនេះបានហាមឃាត់មិនឱ្យប្រើមធ្យោបាយប្រាស្រ័យទាក់ទងគ្នាណាផ្សេងពីភាសាខ្មែរឡើយ ប្រហែលជាក្នុងបំណងធានានូវការត្រួតត្រាទាំងស្រុងទៅលើជនជាតិទាំងនេះ។ ជាមួយការប្រយ័ត្នប្រយែងដែលត្រូវតែមាននោះ គេអាចកំណត់កាលបរិច្ឆេទនៃសម័យកាលនេះ ជាពេលដំបូងនៃអភិក្រមនៃការលែងឱ្យតម្លៃលើភាសាទាំងពីរ។

យ៉ាងហោចណាស់ចំពោះអ្វីដែលទាក់ទងនឹងស្អូច វាសក្តិសមនឹងកត់សម្គាល់ថា សំណេរបរទេសដែលទាក់ទងនឹងជាតិ ពន្ធនេះ (Bastian, 1868, Baradat, 1941) បានចង្អុលបង្ហាញថាមានចំនួនអ្នកនិយាយតិចតួចស្ទួចស្តើងបំផុត ដូច្នេះក៏ បានព្យាករបាត់បង់ដ៏ឆាប់រហ័សនៃភាសានេះ។ ប៉ុន្តែវាមិនបានកើតឡើងដូច្នោះទេ។ មានតែពេលសព្វថ្ងៃនេះទេ ដែលគេអាចនិយាយពីការវិនាសបាត់បង់ដែលបានគ្រោងទុក ដោយសំអាងលើហេតុផលដែលបានលើកឡើងខាងលើ។

ក្នុងលក្ខខណ្ឌនេះ គេគួរចោទសួរពីសកម្មភាពដែលអាចគ្រោងនឹងធ្វើទៅបាន។

ប្រសិនបើគោលនយោបាយនៃជីវិតនីយកម្មត្រូវបានទាត់ចោលនោះ ការសិក្សាពិព័ណ៌នាអំពីភាសានេះគួរតែធ្វើ អោយបាន ទោះបីជាផ្លែផ្កានៃការពិពណ៌នាផ្នែកភាសាមិនអាចនឹងមានសមូលភាពទៅនឹងភាសាដែលគេពិព័ណ៌នានោះក៏ដោយ ។ ពិតណាស់ថា អ្វីដែលឯកសារពិព័ណ៌នាភាសាអាចឆ្លុះបញ្ចាំងបាន គឺសភាពភាសាដែលមិនប្រែប្រួលផ្នែកសម្ព័ន្ធ ហើយដែល ផ្ទុយនឹងការបង្កើតថ្មីគ្មានព្រំដែននៃផលិតកម្មភាសា។ ដោយគ្មានជម្រើសប្រសើរជាងនេះ ការវិលទៅរកការពិព័ណ៌នាចោទជា

សំណួរពីរភ្ជាប់គឺ : យ៉ាងដូចម្តេច? និងហេតុអ្វី?

រាល់បច្ចេកទេសដែលមាននៅក្នុងការពិព័ណ៌នាសាកល្បង បង្កើតភាពដើមជាអតិបរមានៃទិន្នន័យក្នុងវិស័យដូចត ទៅ :

- សូរវិទ្យានិងសទ្ទវិទ្យា
- ទម្រង់វិទ្យា
- សម្ព័ន្ធវិទ្យា
- វចនវិទ្យា
- ន័យវិទ្យា

យោងទៅតាមទិន្នន័យពិសេសក្នុងស្ថានភាពភាសានីមួយៗដែលគេសិក្សាភាសាមិនអាចត្រូវបានពិព័ណ៌នាក្នុង កម្រិតដូចគ្នានោះទេ។

ក្នុងករណីភាសាស្មុចនិងភាសាព័រគេអាចពិព័ណ៌នាផ្នែកសូរវិទ្យា សទ្ទវិទ្យា និងវចនវិទ្យា ការពិព័ណ៌នាផ្នែកសម្ព័ន្ធ វិទ្យាមានភាពលំបាកដោយមិនចាំបាច់និយាយពីការពិព័ណ៌នាផ្នែកន័យវិទ្យា ដែលជុំវិញប្រធានបទនេះ យើងសូមមិនអត្ថាធិប្បាយអ្វីទាំងអស់។ លើសពីការពិព័ណ៌នានេះ ដែលអាចធ្វើតាមបែបបុរាណ គេចាំបាច់ត្រូវថតសម្លេងភាសាទាំងនេះអោយ បានច្រើនបំផុត ដើម្បីមានមូលដ្ឋានទិន្នន័យជាសូរសម្លេងនៃភាសាទាំងនោះ។

សំណួរដែលថាហេតុអ្វីត្រូវមានការពិពណ៌នានោះ ទាក់ទងទៅនឹងការបដិសេធមិនព្រមទុកឱ្យវិនាសផ្នែកតែមួយគត់ នៃបេតិកភណ្ឌមនុស្សជាតិដោយគ្មានរក្សាទុកនូវភស្តុតាងណាមួយសោះ។ ភាសាមួយនាំមកនូវចក្ខុវិស័យពិភពលោកតែមួយគត់ និង

មិនអាចបង្រួមបានឡើយ។

ក្នុងករណីភាសាស្ទួចនិងភាសាព័រ ចាំបាច់ត្រូវកត់សម្គាល់ថាភាសាទាំងពីរមាន លក្ខណៈសំខាន់ ឬអាចថាមាន លក្ខណៈពិសេសដោយឡែកទៀតផង :

- មានកម្ចីពាក្យជាច្រើនពីភាសាខ្មែរ និង ពីភាសាដទៃទៀតដែលការវិភាគនឹងអនុញ្ញាតឱ្យបង្កើតឡើងវិញនូវផ្នែកមួយនៃ ប្រវត្តិសាស្ត្រតំបន់។

- គ្រឹះសំខាន់សម្រាប់បង្កើតឡើងវិញនូវបុរេប្រវត្តិភាសានៃតំបន់។

- វត្តមាននៃសំឡេងភាសាស្ទួចចំនួន៤ (សំឡេងបំណែប ត្រដុស ដើមក បង្ហូរត្រដុស) ដែលរួមចំណែកក្នុងបេតិកភណ្ឌ សំឡេងដ៏កម្រនេះជាមួយភាសាព្សើរកមួយទៀតនៃប្រទេសថៃនិងជាមួយភាសាឆាដមួយ។

### ២.៤.១.២.៣.ភាសាក្នុងសភាពវងគ្រោះ

គឺជាភាសាដែលការវិនាសបាត់បង់មិនអាចគ្រោងទុកបានភ្លាមៗ ប៉ុន្តែនឹងកើតមានដោយចៀសមិនផុតក្នុងពេលយូរ ឬឆាប់ ប្រសិនបើសកម្មភាពនៃជីវិតនីយកម្មមិនត្រូវបានធ្វើឡើងទេនោះ។ គេអាចកំណត់ស្ថានភាពនៃភាសាទាំងនោះ តាមលក្ខណៈដូចតទៅ :

- ចំនួនអ្នកនិយាយតិច។

- ការប្រើភាសាក្នុងជីវិតប្រចាំថ្ងៃក្នុងក្របខណ្ឌទ្វេភាសានិយម ដែលចូលចិត្តប្រើភាសា ខ្មែររបស់ជនជាតិភាគច្រើនជាង។

- ការផ្ទេរទៅអោយក្មេងជំនាន់ក្រោយ តែប្រកបដោយការបាត់បង់ទៅៗ។

- ការអភិរក្សក្របខណ្ឌសង្គមវប្បធម៌ ពិសេសសាសនាដែលនាំឱ្យមានការប្រើភាសា។

លក្ខណៈទាំងនេះ ហាក់ដូចជាកំណត់បានចំៗល្អនូវស្ថានភាពភាសាទាំងពីរនៃ មែកធាងពៀរិកក្នុងអំបូរអូស្ត្រូអាស៊ី ដែលមាននិយាយតាមជួរភ្នំក្រវាញ : ភាសាសំរែ (ពៀរខាងលិច) និងសំរ៉ែ (ពៀរខាងកើត) ។

យើងងគ្រាន់តែមានព័ត៌មានមិនពេញលេញស្ដីពីភាសាទាំងពីរដែលប្រហែលជាមានអ្នកនិយាយមិនលើសពី៤០០ នាក់ផង ។

ការពិព័ណ៌នាលម្អិតនៃសម័យកាលមុនឆ្នាំ៧៥ (Baradat, 1941 ; Martin, 1974, 1975) ម្យ៉ាងជាសក្ខីនៃ ភាពសម្បូរបែបខាងវប្បធម៌ដែលគេឃើញមាននៅក្នុងពិធីផ្សេងៗ របាំ វត្ថុវប្បធម៌ គ្រឿងអលង្ការនៃជីវិតប្រចាំថ្ងៃ ព្រមទាំង អក្សរសិល្ប៍ផ្ទាល់មាត់ដ៏សម្បូរបែប ហើយម្យ៉ាងទៀត ការពិព័ណ៌នានេះក៏ជាសក្ខីនៃសកម្មភាពសេដ្ឋកិច្ចទាក់ទងនឹងការបេះ ក្រវាញ (Dy Phon, 2000) ។

ទស្សនីយសង្គមភាសាវិទ្យានៃភាសាទាំងពីរ[១៥២] ហាក់ដូចជាមានលក្ខណៈប្រកបដោយការទទួលឥទ្ធិពលដ៏សម្បើមពី ភាសាខ្មែរ[១៥៣] និងពីទ្វេភាសានិយមដែលមិនអំណោយផលដល់ភាសាជនជាតិភាគតិចទាំងពីររហូតដល់ដែនប្រើប្រាស់នៃ ភាសាទាំងពីរនេះ រួមតូចបន្តិចម្ដងៗក្នុងជីវិតសង្គម ។

មានចំណុចសំខាន់ពីរដែលត្រូវកត់សម្គាល់ : គ្មានការឃ្លាតចេញពីគ្នាផ្នែកភាសារវាងជំនាន់ចាស់និងជំនាន់ថ្មី ទោះបីជាការផ្ទេរភាសាទាំងពីរ បើតាមការប្រាប់ឱ្យដឹងពី

---

[១៥២] យើងសូមបញ្ចេញយោបល់ប្រកបដោយការប្រុងប្រយ័ត្នដែលចាំបាច់ ព្រោះយើងបានជួបសមាជិកជាតិពន្ធុនេះតែពីរនាក់ប៉ុណ្ណោះ ម្យ៉ាងទៀតពិបាកនឹងទាក់ទងណាស់ ។

[១៥៣] អ្នកផ្ដល់ព័ត៌មានយើងម្នាក់បានរៀបរាប់ពីពាក្យខ្មែរមួយចំនួនដែលក្នុងអំណើះតទៅគេប្រើជំនួសពាក្យមានប្រភពពីភាសាសំរែ ដែលចាប់ពីពេលនេះតទៅត្រូវបានគេកំពុងបំភ្លេចចោល ។

សំណាក់អ្នកផ្តល់ព័ត៌មានរបស់យើង ជួបប្រទះនឹងការបាត់បង់យ៉ាងសម្បើម ហើយម្យ៉ាងទៀតភាពចាំបាច់ក្នុងការអភិរក្សភាសា ទាំងពីរដើម្បីបន្តអនុវត្តពិធីអារក្សអ្នកតាក្នុងភូមិដែលមិនអាច កាត់ផ្តាច់ចេញពីធម៌អាគមអួមអាមដែលចាំបាច់ត្រូវសូត្រអោយច្បាស់ៗ ។

កម្មវិធីនៃការធ្វើឱ្យរស់រានមានជីវិតឡើងវិញ សម្រាប់ភាសាទាំងពីរនេះដែលមិនអាចថាធ្វើមិនកើតនោះ ប្រហែល អាចនឹងមានទម្រង់ដូចតទៅ :

- ការពិពណ៌នាភាសា
- ការបង្កើតអក្សរ
- ការប្រមូលអក្សរសិល្ប៍ផ្ទាល់មាត់បែបសាសនានិងមិនមែនបែបសាសនា ។
- ការបង្កើតកម្មវិធីអប្បបរមានៃអក្ខរនីយកម្មភាសាទាំងពីរ ។

ទោះជាយ៉ាងណាក្តី ស្ថានភាពបរិស្ថានភាសា នៅតាមជួរភ្នំក្រវាញត្រូវតែពិព័ណ៌នា[១៥៤] ឱ្យបានល្អ ។

## ២.៤.១.២.៤.ភាសាក្នុងអន្តរកាល

គឺជាចំណាត់ប្រភេទដែលប្រមូលផ្តុំភាសាជនជាតិភាគតិចនៅតំបន់ខ្ពង់រាប (មណ្ឌលគីរីនិងរតនគីរី) ព្រមទាំងភាសា ប្រជាជនកួយមួយផ្នែក (ខេត្តព្រះវិហារ) ។ ភាសាទាំងនេះស្ថិតក្នុងអំបូរអូស្ត្រូអាស៊ី លើកលែងតែភាសាចារាយដែលជាភាសាមួយនៃមែកធាងភាសាចាមក្នុងអំបូរអូស្ត្រូណេស៊ី ។

---

[១៥៤] វាហាក់ដូចជាមានអ្នកនិយាយភាសាខ្មែរបុរាណនៅក្នុងតំបន់អូរសោម (Martin, 1974, 1975) ដែលយើងមិនអាចផ្ទៀងផ្ទាត់ដោយផ្ទាល់បាន ។

ភាសានិយាយក្នុងតំបន់ទាំងនេះ មិនស្ថិតនៅក្នុងសភាពរងគ្រោះទេនាពេលសព្វថ្ងៃនេះ។ ប៉ុន្តែ ភាសាទាំងនោះជាប់ ទាក់ទងដោយផ្ទាល់ទៅនឹងបំណែបជីវិតប្រពៃណីដែលកំពុងឈានទៅរកការបាត់បង់តម្លៃដោយសារវត្តមានទំនើបភាពមួយដែលជារឿយៗគ្មានការគ្រប់គ្រង។

ក្នុងពេលខ្លីមធ្យមខាងមុខ ការមិនសូវយកចិត្តទុកដាក់លើវប្បធម៌បុរាណមិនមែនគ្មានឥទ្ធិពលទៅលើអនាគតនៃ ភាសាទាំងឡាយដែលគេប្រើជាយានដ៏ពិសិដ្ឋនោះទេ។ យើងលើកឡើងនូវវិស័យពីរខាងក្រោម :

- កសិកម្ម
- អប់រំ

### ២.៤.១.២.៤.១.កសិកម្ម

ប្រជាជននៃតំបន់ខ្ពង់រាបអនុវត្តតាំងពីយូរយារមកហើយ នូវបច្ចេកទេសដាំដុះទាក់ទងទៅនឹងការរានដីដែលគេហៅ ផងដែរថាជាការដាំដុះនៅលើដីព្រៃដុត។ គេមិនត្រូវយល់ថាជាបច្ចេកទេសកសិកម្មសាមញ្ញនោះទេ ប៉ុន្តែ ត្រូវយល់ថាជាចក្ខុវិស័យនៃពិភពដោយឡែកមួយ (Dufumier, 1993) ដែលបណ្តាលឱ្យមានការប្រារព្ធពិធីសាសនាដ៏ស្មុគស្មាញមួយ (Matras Troubetskoy, 1983)។ កសិកម្មប្រភេទនេះមានន័យថាប្រជាជនមានចំនួនតិចតួចហើយមានផ្ទៃដីធំ។

ការដាក់បញ្ចូលទៅក្នុងតំបន់ខ្ពង់រាប នូវបច្ចេកទេសធ្វើស្រែដោយប្រព័ន្ធស្រោចស្រពនាសតវត្សទី២០ តាំងពីសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០)(Bourdier, 2006) ជំរុញឱ្យលេចឡើងនូវការប្រជែងគ្នាក្នុងកសិកម្ម ហើយការនេះ នាំអោយគេ

មិនសូវអនុវត្តកសិកម្មបុរាណ ជាពិសេស ប្រសិនបើគេគិតអំពីសម្ពាធប្រជាជនកាន់តែធំបណ្ដាលមកពីការមក តាំងទីលំនៅនៃប្រជាជនវាលទំនាបក្នុងតំបន់ខ្ពង់រាប។ ទីបំផុតគឺបំណែបជីវិតបុរាណទាំងមូលដែលប្រទះនឹងការគំរាម កំហែង។

ការផ្គុំបញ្ចូលគ្នានៃបែបបទផលិតកម្មកសិកម្មទាំងពីរប្រភេទ ពោលគឺ ស្រែស្រោចស្រពជាមួយបច្ចេកទេសរានដីគឺ មិនមែនថា ធ្វើទៅមិនកើតនោះទេ (Bourdier, 2006) ប្រសិនបើគេបង្រៀនប្រជាជនអោយចេះនិងមានការសន្ដោស សហវត្ថមាននៃប្រភេទផលិតកម្មទាំងពីរនេះ។

## ២.៤.១.២.៤.២.ការអប់រំ

ទន្ទឹមនឹងការអប់រំទំនើបដែលគេធ្វើឡើងជាបន្តបន្ទាប់នោះ បំណែបវប្បធម៌បុរាណនឹងរងនូវការវិនាសបាត់បង់យ៉ាង ឆាប់រហ័ស។

ជាក់ស្ដែងនៅក្នុងខេត្តមណ្ឌលគិរី យើងបានឃើញការបញ្ឈប់ភ្លាមៗនូវការផ្ទេរចំណេះខាងសិល្បៈនិទានរឿង។ អ្នក ចេះនិទានរឿងចុងក្រោយគេមានអាយុលើសពី៥០ឆ្នាំ ហើយការផ្ទេរចំណេះដឹងរបស់គេត្រូវបានឈប់នៅដើមឆ្នាំ៩០។ ដូចនេះ គឺគ្រប់ការចងចាំដ៏រស់រវើកនៃវប្បធម៌មួយ ដែលមានមូលដ្ឋានលើប្រពៃណីផ្ទាល់មាត់នឹងចៀសមិនផុតពីការវិនាសបាត់បង់។

ទស្សនាទាននិទានកម្ម[១៥៥] បង្ហាញយ៉ាងច្បាស់ថា អវត្តមានសំណេរគ្មានអត្ថន័យអវិជ្ជមាននោះទេ ហើយគេត្រូវបែង ចែករវាងអនក្ខរជននិងអ្នកមិនចេះអក្សរ។ ក្នុងករណីទីមួយគឺជាកង្វះខាត ដែលនាំទៅរកការឃ្លាតចេញពីសង្គមមួយដែលមិន

---

[១៥៥] ទស្សនាទាននេះបង្កើតឡើងដោយនវិទ្យាឈ្មោះ Rémi Dor ដែលចាត់ទុកវិទ្យាស្ថាននីយកម្មនៃនិទានភាពដូចជាយានដែលមិនអាចគ្មានបាន (Rémi Dor បទបង្ហាញផ្ទាល់ខ្លួន)។

អាចច្រៀសបាន រីឯករណីទីពីរគឺការគ្មានសំណេរមិនត្រូវបានកត់សម្គាល់ និងត្រូវបានបញ្ចូលទៅក្នុងវប្បធម៌មួយ[១៥៦] ។

បច្ចុប្បន្ននិងទៅថ្ងៃអនាគត ដោយមូលហេតុប្រជាសាស្ត្រនិងការជួបប្រាស្រ័យទាក់ទងគ្នាកើនឡើងរវាងប្រជាជន ផ្សេងៗគ្នា ភាពមិនចេះអក្សរកាន់តែត្រូវចាត់ទុកជាកង្វះខាត និងជាកត្តាដែលជំរុញទៅកាន់ការឃ្លាតចេញពីសង្គមកាន់តែលឿន ។ គឺហេតុផលនេះហើយដែលការរៀនសរសេរ អាចចាត់ទុកដោយស្របច្បាប់ចាំជាភាពចាំបាច់មួយ ប៉ុន្តែ សំណួរចោទសួរផងដែរអំពីការរស់រាននៃបេតិកភណ្ឌវប្បធម៌ទាក់ទងនឹងនិទានកម្ម ។

## ២.៤.១.២.៤.៣.ការលើកតម្លៃចំណេះដឹងបុរាណ

ការបដិសេធមិនគិតគូរដល់ចំណេះដឹងបុរាណក្នុងការអប់រំនិងសេដ្ឋកិច្ច[១៥៧] នៅទីបញ្ចប់នឹងនាំទៅរកការស្ថិតនៅ ក្រៅសង្គម ។

អភិក្រមនេះបានកើតមានហើយ យ៉ាងហោចណាស់នៅតាមតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា ហើយនឹងនាំទៅរកការ ដើរថយក្រោយនៃភាសាជនជាតិភាគតិចដែលប្រើប្រាស់នៅទីនោះ ។ ពិតណាស់វាពិបាកនឹងយល់ថាតើមានហេតុផលអ្វីដែល គេត្រូវរក្សាទុកឯកសារភាសាទាក់ទងនឹងចំណេះដឹងបុរាណនៅពេលដែលក្រុម ភាសាមួយផ្សេងទៀតហាក់ដូចជាត្រូវនឹង ទំនើបភាពជាងហើយដែលទំនើបភាពនេះ ត្រូវបានបង្កើតឡើងនិងគិតគូរទៅដល់ការទាត់ប្រពៃណីចោល ។

---

[១៥៦] វប្បធម៌ពួក tziganes ឆ្លុះបង្ហាញច្បាស់ពីស្ថានភាពនិទានកម្មនេះ ។

[១៥៧] នេះគ្រាន់តែជាឧទាហរណ៍ពីរប៉ុណ្ណោះ វិស័យចំណេះដឹងជនជាតិដើមភាគតិចធំធេងណាស់ ឧទាហរណ៍ក្នុងវិស័យសុខាភិបាលជាដើម ។

ប្រសិនបើក្នុងករណីតំបន់ខ្ពង់រាប នយោបាយនៃការធ្វើឱ្យរស់រានមានជីវិតបែបបុរាណឡើងវិញមិនទាន់ជាបច្ចុប្បន្ន ភាពនោះ វាក៏ត្រូវមានភាពចាំបាច់ជាបន្ទាន់ក្នុងការផ្សារភ្ជាប់វប្បធម៌បុរាណជាមួយនឹងភាពចាំបាច់នៃចំណេះដឹងទំនើប និងបែបបទនៃការផ្ទេរចំណេះដឹងទាំងនោះ។

ដូច្នេះ ការបង្រៀននៅបឋមសិក្សាជាភាសាជនជាតិភាគតិចនឹងចោទជាបញ្ហាភ្លាមៗផ្នែកខ្លឹមសារដែលត្រូវបង្រៀន។ ឧទាហរណ៍ វាហាក់ដូចជាមិនមានវិសមិតភាពទេក្នុងការបញ្ចូលអក្សរសិល្ប៍បុរាណផ្ទាល់មាត់ដ៏សំបូរបែប (រឿងនិទាន ប្រលោមលោកជាពាក្យកាព្យ កំណាព្យ) ទៅក្នុងប្រព័ន្ធអប់រំទំនើប។

# ផ្នែកទីបី

## ផែនទីសាស្ត្រ

ផែនទីជាបន្តទៅនេះត្រូវបានបង្កើតចេញពីឯកសារដែលមានស្រាប់ដោយយើងបានបន្ថែមនូវសម្រង់ព័តិមានផ្ទាល់ របស់យើង ។

យើងបានតាងទីតាំងនៃជាតិពន្ធុមួយក្នុងផែនទីមួយ ។ លើសពីនេះ យើងបានបន្ថែមផែនទីទូទៅមួយដែលភាគច្រើននៃ ជាតិពន្ធុត្រូវបានតាងឡើង ។

ព្រោះតែហេតុផលដែលបានលើកឡើងខាងលើ ជាតិពន្ធុមួយចំនួនមិនអាចតាងនៅលើផែនទីបានទេ ដូចជា ជនជាតិ វៀតណាមនិងភាគច្រើននៃជនជាតិភាគតិចចិន លើកលែងតែប្រជាជននៃជាតិពន្ធុហៃណាំនិងខិមួយចំនួនដែលប្រមូលផ្តុំ គ្នានៅក្នុងតំបន់ពីរនៃប្រទេស ។

យើងតាងតែជាតិពន្ធុណាដែលយើងច្បាស់ថា មានវត្តមានពួកគេនៅកន្លែងណាមួយក្នុងទឹកដីកម្ពុជា[១៥៨] ។

ដើម្បីសម្រួលអំណាន ផែនទីនីមួយៗមានភ្ជាប់ដោយការអត្ថាធិប្បាយដែលសង្ខេបពី :

- ឫសគល់នៃភាសានីមួយៗដែលត្រូវបានតាងឡើង ។
- ជាតិពន្ធុនាមនៃជាតិពន្ធុនីមួយៗ ។
- ការវាយតម្លៃចំនួនប្រជាជន ។
- ព័តិមានផ្សេងៗដូចជាការមានប្រព័ន្ធសំណេរ និងការមានកម្មវិធីអប់រំជាភាសាជនជាតិភាគតិច ។

---

[១៥៨] ប្រភពផ្សេងៗនិយាយពីជាតិពន្ធុ ថ្មូន កូឡា រ៉ូបែល កានីង ។ល។ ហើយថែមទាំងផ្តល់ទិន្នន័យជាតួលេខទៀតផង ប៉ុន្តែគ្មានការបញ្ជាក់ពីទីតាំង ។ ចំណែកយើងមិនដែលជួបសមាជិកជាតិ ពន្ធុខាងលើនេះទេ ។ តើជាពន្ធុនាមនៃជាតិពន្ធុដែលបានជំរឿននៅក្នុង ឈ្មោះផ្សេងទៀត? ឬក៏ដូចក្នុងករណីជនជាតិកូឡាដែលជាជាតិពន្ធុមានវត្តនៅកម្ពុជាមុនឆ្នាំ១៩៧៥ ប៉ុន្តែបានបាត់បង់តាំងពីពេល នោះមក? សំណួរនៅតែបើកចំហ ។

ការគោងផែនទីសាស្ត្រនេះ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ ហើយប្រការនេះមកពីហេតុផលពីរយ៉ាង :

- គុណភាពនៃការងារផែនទីសាស្ត្រស្ដីពីកម្ពុជា ។ ផែនទីប្រទេសកម្ពុជាដែលមានសព្វថ្ងៃ ភាគច្រើនគឺជាការបោះពុម្ពសម្រួល ចេញពីផែនទីដែលបង្កើតឡើងនៅសម័យអាណាព្យាបាលបារាំងហើយមិនដែលបានធ្វើបច្ចុប្បន្នភាពទាល់តែសោះតាំងពីពេលនោះមក ។ ជាច្រើនឆ្នាំចុងក្រោយនេះ មានការរីកចម្រើនច្រើនក្នុងការងារធ្វើផែនទីសាស្ត្រកម្ពុជា[១៥៩] ប៉ុន្តែលទ្ធផលមិនទាន់ ចេញនៅឡើយ ។
- ការកំណត់ទីតាំងនៅមូលដ្ឋាល ។ នៅមានភាពស្រពិចស្រពិលច្រើន ដោយកង្វះការស្រង់តាមភូមិម្ដងមួយៗ ។

[១៥៩] គឺជាផែនទីសាស្ត្រធ្វើដោយកិច្ចសហប្រតិបត្តិការជប៉ុន (JICA) និង Finnmap ។

# ភាសាអូស្ត្រូអាស៊ី

# ប្រៅ

ជាតិពន្ធុនាម : ប្រៅ គ្រឹង ក្រាវែត លុន ។

ចំណាត់ប្រភេទ[១៦០]

អូស្ត្រូអាស៊ី

ខាងកើត

បាណារិក

បាណារិកខាងលិច

ប្រជាជន : ២៣ ៨០០

ទីតាំង : ខេត្តរតនគិរីនិងស្ទឹងត្រែង

អំណឹះតទៅ ជនជាតិប្រៅមានប្រព័ន្ធសំណេរមួយដែលមានបម្រែបម្រួលភាពស្របតាមគ្រាមភាសាដែលគេត្រូវសរ សេរ ។

កម្មវិធីនៃការអភិវឌ្ឍ RIDE (Rattnakiri International Development and Education) ត្រូវបានអនុវត្ត ដោយអង្គការមិនមែនរដ្ឋាភិបាលឈ្មោះ *កិច្ចសហប្រតិបត្តិការអន្តរជាតិនៃកម្ពុជា* (ICC) ។ កម្មវិធីនេះមានផ្នែកអប់រំ ពោលគឺកម្មវិធីអប់រំមិនផ្លូវការជាពីរភាសា (ប្រៅ ខ្មែរ) ដើម្បីលើកស្ទួយអក្ខរនីយកម្មនៅលើមូលដ្ឋាននៃភាសាប្រៅ ។ គួរកត់សម្គាល់ផងដែរថា ផ្ទុយពីយើង កិច្ចសហប្រតិបត្តិការអន្តរជាតិនៃកម្ពុជាចាត់ទុក ប្រៅ គ្រឹង និងក្រាវែតជាភាសាផ្សេងគ្នា ។

---

[១៦០] កម្រិតទីមួយចង្អុលប្រាប់ពីអំបូរភាសា កម្រិតទីពីរបញ្ជាក់ពីមែកធាង កម្រិតទីបីប្រាប់ពីក្រុម ហើយកម្រិតទីបួនប្រាប់ពីអនុក្រុម ។


LAOS
VIETNAM
Siem Pang
Veun Sai
Ta veng
Rattanakiri
Ou Chum
Ban Lung
Bar Kaev
Ou Ya Dav
Stung Treng
Sesan
Prek
Siem Bouk
Koun Mom
Lumphat
Tonle Sre Pok
7
Mekong
Kaoh Nhek

# ទំពួន

ចំណោត់ប្រភេទ :

អូស្ត្រូអាស៊ី

ខាងកើត

បាណារិក

បាណារិកកណ្តាល

ប្រជាជន : ២៤ ០០០

ទីតាំង : ខេត្តរតនគិរី

ភាសាទំពួនមានប្រព័ន្ធសំណេរមួយ

ដូចជនជាតិប្រៅដែរ ជនជាតិគ្រឹងបានទទួលតាមរយៈកម្មវិធី RIDE វគ្គអប់រំក្រៅប្រព័ន្ធជាពីរភាសា (ទំពួន ខ្មែរ) ដើម្បីឈានទៅរកអក្ខរកម្មនីយកម្ម។


Rattanakiri
Andong
Ou Chum
Tonle San
Ban Lung
Bar Kaev
Ou Ya Dav
Koun Mom
Lumphat
Tonle Sre Pok
Kaoh Nhek

# ការ៉ាវ

ជាតិពិន្ទុនាម : កាជោ ឡាមាំ

ចំណាត់ប្រភេទ :

អូស្ត្រូអាស៊ី

បូពាំ

បាណារិក

បាណារិក ខាងជើង

ចំនួនប្រជាជន : ១៣០០នាក់

ទីតាំង : ខេត្តរតនគិរី


LAOS
VIETNAM
Ta veng
Veun Sai
Rattanakiri
Ou Chum
Ban Lung
Bar Kaev
Ou Ya Dav
Koun Mom
Lumphat
Tonle Sre Pok
Kaoh Nhek

# ព្នង

ចំណាត់ប្រភេទ :

អូស្ត្រូអាស៊ី

បូពាំ

បាណារិក

បាណារិកខាងត្បូង

ចំនួនប្រជាជន : ២០ ០០០នាក់

ទីតាំង : ខេត្តមណ្ឌលគិរី រតនគិរី និងក្រចេះ ភាសាព្នងមានប្រព័ន្ធសំណេរមួយ ។

អង្គការមិនមែនរដ្ឋាភិបាល កិច្ចសហប្រតិបត្តិការអន្តរជាតិនៃកម្ពុជា (ICC) បានអនុវត្តគម្រោងមួយដែល អក្សរកាត់ហៅថា READ (Research, Education and Development ) ។ ជំហានទីមួយនៃគម្រោងនេះមានទិស ដៅបង្កើតប្រព័ន្ធសំណេរមួយសម្រាប់ភាសាព្នង និងធ្វើឱ្យមានការទទួលស្គាល់ពីអាជ្ញាធរអប់រំកម្ពុជា ។ គឺនៅលើមូលដ្ឋាននៃប្រព័ន្ធសំណេរ និងការបង្កើតសៀវភៅរៀនអក្សរនេះហើយ ដែលកម្មវិធីអប់រំក្រៅប្រព័ន្ធនៃអក្ខរនីយកម្ម ត្រូវបានអវត្តនិងបន្តរហូតដល់សព្វថ្ងៃ ។

ក្នុងចំណោមភាសាជនជាតិភាគតិចទាំងអស់នៅតាមតំបន់ខ្ពង់រាប ភាសាព្នងហាក់ដូចជាត្រូវបានគេសិក្សាពិព័ណ៌នាល្អ ជាងគេ ។


Rattanakiri
Lumphat
Tonle Sre Pok
Kaoh Nhek
Mondulkiri
Pechreada
Saen Monourom
Kaev Seima
Snoul
Vietnam

# ស្ទៀង

ចំណាត់ប្រភេទ :

អូស្ត្រូអាស៊ី

ខាងកើត

បាណារិក

បាណារិកខាងត្បូង

ចំនួនប្រជាជន : ៤ ០០០នាក់

ទីតាំង : ខេត្តក្រចេះនិងមណ្ឌលគិរី


Mondulkiri
Pechreada
Saen Monourom
Kaev Seima
Snoul

# គ្រួយ

ចំណាត់ប្រភេទ :

អូស្ត្រូអាស៊ី

ខាងកើត

កាទូអ៊ិក

កាទូអ៊ិកខាងលិច

ចំនួនប្រជាជន : ៣០ ០០០នាក់

ទីតាំង : ខេត្តព្រះវិហារ កំពង់ធំ ក្រចេះ និងស្ទឹងត្រែង។

វាដូចជាមិនមានប្រព័ន្ធសំណេរសម្រាប់ភាសាគួយទេ។ សៀវភៅសិក្សាថ្នាក់ទីមួយនៃសាលាបឋមសិក្សា *ភាសាខ្មែរ* ពិតជាត្រូវបានបកប្រែជាភាសាគួយ ប៉ុន្តែការបកប្រែនេះហាក់ដូចជាមិនមានការវិភាគប្រព័ន្ធសទ្ទតានៃគ្រាមភាសាគួយ ព្រមទាំងការបង្កើតតួអក្សរជាមុនទេ។


Trapeang Prasat
Choam khsan
Chhaep
Preah Vihear
Kulen
Tbaeng Mean Chey
Chey Sen
Sangkom Thmei
Peuk
Rovieng
Stung Treng
Thala Barivat
Sesan
Prek
Siem Bouk
7
Chi Kraeng
Sandan
Mekong
Stong
Prasat Balang
Prasat Sambour
Kampong Svay
Sambour
Kampong Thom
6
Santuk
Russei Char
Kratie
Baray

# ស្ទៀង

ចំណោត់ប្រភេទ :

អូស្ត្រូអាស៊ី

បូព៌ា

ព្យើរិក

ព្យើរិកខាងលិច

ចំនួនប្រជាជន : ៣០០នាក់

ទីតាំង : ខេត្តពោធិ៍សាត់


Phnum Proek
Tumnop Teuk
Thma kol
Siem Reap
Aek Phnum
Battambang
Kamrieng
Sala Kaev
Sangkae
Tonle S
Sala Krau
Banan
Ratanak Mondol
Pailin
Mong Russei
Koas Krala
Samlout
Bakan
Pursat
Phnum Kravanh
Veal Veng
Chuor Phnum Kravanh
Trapeang Khnar
Kaoh Kong
Kaoh kut
Smach Mean Chey
Thma Bang
Kaoh Kong

# សំរ៉ែ

ចំណាត់ប្រភេទ :

អូស្ត្រូអាស៊ី

បូព៌ា

ពៀរិក

ពៀរិកខាងកើត

ចំនួនប្រជាជន : ៤០០នាក់

ទីតាំង : ខេត្តកោះកុង



Siem Reap
Tumnop Teuk
Thma kol
Aek Phnum
Battambang
Kamrieng
Sala Kaev
Sangkae
Tonle Sap
Sala Krau
Banan
Ratanak Mondol
Pailin
Mong Russei
Koas Krala
Samlout
Bakan
Pursat
Phnum Kravanh
Veal Veng
Chuor Phnum Kravanh
Trapeang Khnar
Kaoh Kong
Smach Mean Chey
Thma Bang
Kaoh kut
Kaoh Kong

# ស្ទៀង

ជាតិពន្ធុនាម : ជុង

ចំណាត់ប្រភេទ :

អូស្ត្រូអាស៊ី

បូព៌ា

ពៀរិក

ពៀរិកនៃវាលរេញ

ចំនួនប្រជាជន : ១៥០នាក់

ទិតាំង : ខេត្តកំពត


Srae Ambel
Kampong Seil
Chuor Phnum Damrei
Chamlang Kou
baie de Kompong Saom
Stueng hav
Kaoh Rong
Sihanoukville
Veal Renh
Samrong
Sa'och
Kampong
4
Kaoh Rong Sanloem
Baie de Veal Renh
Kaoh Ta Kiev

# ព័រ

ចំណាត់ប្រភេទ :

អូស្ត្រូអាស៊ី

បូពា

ពៀរិក

ព័រកំពង់ធំ

ចំនួនប្រជាជន : ៣០០នាក់

ទីតាំង : ខេត្តព្រះវិហារ


Choam khsan
Prasat
Chhaep
Preah Vihear
Kulen
Tbaeng Mean Chey
Chey Sen
Sangkom Thmei
Peuk
Thala Barivat
Prek
Siem Bo
Rovieng
Mekong
Sandan
Stong
Prasat Balang
Prasat Sambour

# ស្ទួយ

ជាតិពន្ធុនាម : ស្ទុង

ចំណាត់ប្រភេទ :

អូស្ត្រូអាស៊ី

បូព៌ា

ពៀរិក

ព័រកំពង់ស្ពឺ

ចំនួនប្រជាជន : ៥០០នាក់

ទីតាំង : ខេត្តកំពង់ស្ពឺ



Baribour
Kamraeng
ravanh
Kampong Laeng
Phsar Leu
Kampong Chhnang
Chol Kiri
5
Sre Ta Chey
Kampong Tralach
Sala Lech Pram
Samakki Mean Chey
Thpong
Odong
Aoral
Phnom Penh
Kampong Speu
Samraong Tong
Dangkao
Ang Snuol
Phnum Sruoch
Kanda
4
Kong Pisei
Bati
2
Baseth
Kampong Seila
Phnum Damrei
Tram Kak
Angk Ta Saom
Doun Kaev
Kampot
Chum Kiri
Treang

# ភាសាអូស្ត្រូណេស៊ី

# ចារាយ

ចំណោត់ប្រភេទ :

អូស្ត្រូណេស៊ី

ម៉ាឡាយូប៉ូលីណេស៊ី

ចាម

ចាមតំបន់ខ្ពង់រាប

ចំនួនប្រជាជន : ២០ ០០០នាក់

ទីតាំង : ខេត្តរតនគិរី

ប្រព័ន្ធសំណេរឡាតាំងត្រូវបានប្រើប្រាស់អស់កាលដ៏យូរ នៅក្នុងក្របខណ្ឌនៃអំណានអត្ថបទសាសនា ហើយនៅមាន ប្រជាប្រិយភាពដល់សព្វថ្ងៃនេះ។ ប្រព័ន្ធមួយដែលឈរលើមូលដ្ឋាននៃអក្សរខ្មែរកំពុងតែបង្កើត ប៉ុន្តែមានការប៉ះទង្គិចទៅនឹង ការមិនពេញចិត្តរបស់ប្រជាជនមួយចំនួនដែលចូលចិត្តប្រព័ន្ធចាស់ជាង។ អត្ថប្រយោជន៍ចម្បងរបស់ប្រព័ន្ធចាស់គឺថា ចារាយ ភាគច្រើនដែលរស់នៅលើទឹកដីវៀតណាមសព្វថ្ងៃនេះចេះប្រព័ន្ធនេះ។


LAOS
VIETNAM
Ta veng
Veun Sai
Rattanakiri
Andong
Ou Chum
Ban Lung
Bar Kaev
Ou Ya Dav
Koun Mom
Lumphat
Tonle Sre Pok
Kaoh Nhek

# ចាម

ចំណាត់ប្រភេទ :

អូស្ត្រូណេស៊ី

ម៉ាឡាយូប៉ូលីណេស៊ី

ចាម

ចាមខាងលិច

ចំនួនប្រជាជន : ២៤ ០០០នាក់

ទីតាំង : ខេត្តកំពត, ខេត្តកំពង់ឆ្នាំង, ខេត្តកំពង់ចាម, ខេត្តពោធិ៍សាត់ និងខេត្តក្រចេះ ។

ភាសាចាមមានប្រព័ន្ធសំណេរពីរ ដែលប្រព័ន្ធសំណេរមួយផ្អែកលើអក្សរជ្វា ដែលជាតួអក្សរមានប្រភពពីភាសាអារ៉ាប់ ប្រើសម្រាប់សរសេរភាសាម៉ាឡេ និងប្រព័ន្ធសំណេរឥណ្ឌា ។


Siem Reap
Tonle Sap
Pursat
Kampong Thom
Kampong Chhnang
Kampong Cham
Phnom Kravanh
Phnom Penh
Kampong Speu
Kandal
Prey Veng
Svay Rieng
Kampot
Takeo
Kratie
Mekong
Stung Treng
Dang Tong
Chum Kiri
Angkor Thom
Prasat Bakong
Svay Leu
Sangkom Thmei
Kampong Svay
Baray
Santuk
Stong
Prasat Balang
Prasat Sambour
Bakan
Kandieng
Phnum Kravanh
Trapeang Khner
Thma Bang
Aoral
Samrong Tong
Phnum Sruoch
Kong Pisei
Basedth
Kampong Seila
Sre Ambel
Kampong Bay
Kep
Baie de Veal Ranh
Bati
Prey Kabbas
Kaoh Thum
Angkor Borei
Doun Kaev
Kaoh Andaet
Kiri vong
Bourei Cholsar
Angkor Chey
Chhuk
Tram Kak
Svay Chrum
Kampong Trabaek
Ba Phnum
Peam Ro
Kampong leav
Prey Veng
Romeas Haek
Ou Reang Ov
Thmei
Dambae
Kroch Chhmar
Chhloung
Sambour
Prek Prasap
Russei Char
Stung Trang
Prey Chhor
Kampong Siem
Batheay
Srei Santhor
Kien Svay
Lvea Aem
Prek Sanmong
Sa'ang
Leuk Daek
Odong
Thpong
Samakki Mean Chey
Kampong Tralach
Sre Ta Chey
Kampong Leang
Chol Kiri
Kampong Svay
Kampong Thom
Chamkar Leu
Saray
Tboung Khmum
Kaoh Sotin
Kreseng
Krakor
Kamraeng
Puok
Banteay Srei
Ph'av

# ភាសាតៃកាដាយ

# ឡាវ

ចំណាត់ប្រភេទ :

តៃកាដាយ

កាំតៃ

តៃសេក

តៃនិរតី

ចំនួនប្រជាជន : ២២ ០០០នាក់

ទីតាំង : ខេត្តរតនគិរីនិងស្ទឹងត្រែង

ភាសាឡាវមានប្រព័ន្ធសំណេរដូចគ្នានឹង ប្រព័ន្ធសំណេរប្រើដោយជាតិពន្ធុឡាវ ដែលរស់នៅសាធារណរដ្ឋប្រជា មានិត្យប្រជាធិបតេយ្យឡាវ។


LAOS
VIETNAM
Siem Pang
Veun Sai
Ta veng
Rattanakiri
Ou Chum
Ban Lung
Bar Kaev
Ou Ya Dav
Tonle San
Stung Treng
Sesan
Koun Mom
Prek
Siem Bouk
7
Mekong
Kaoh Nhek

# ភាសាចិន

# ចិនខិ

ចំណាត់ប្រភេទ :

ចិនទីបេ

ចិន

ខិ

ម៉ីសាន

ចំនួនប្រជាជន : ១០ ០០០នាក់

ទីតាំង : ខេត្តស្ទឹងត្រែង រតនគិរី និងភ្នំពេញ


Siem Pang
Tonle Kong
Veun Sai
Ta ver
Rattanakiri
Ou Chum
Tonle San
Ban Lung
Stung Treng
Koun Mom
Thala Barivat
Sesan
Prek
Lumphat
Tonle Sre Pok
Siem Bouk
7

# ហៃណាំ

ចំណាត់ប្រភេទ :

ចិនទីបេ

ចិន

មីនខាងត្បូង

ហៃណាំ

ចំនួនប្រជាជន : ១៣ ០០០នាក់

ទីតាំង : ខេត្តកំពត ភ្នំពេញ


Tram Kak
Angk Ta Saom
Doun Kaev
Angkor Borei
Chum Kiri
Kampot
Treang
Takeo
Chhuk
3
Kaoh Andaet
Angkor Chey
Dang Tong
Kiri vong
Banteay Meas
Bay
Kampot
Kep

# សេចក្ដីសន្និដ្ឋាន

ទស្សនវិជ្ជាដែលបង្កប់ក្នុងការសិក្សានេះ ពិតជាមានការបារម្ភទៅលើអនាគតនៃបេតិកភណ្ឌមនុស្សជាតិ ដែលការបារម្ភ នេះត្រូវគេយល់ស្របភាគច្រើននាពេលបច្ចុប្បន្ននេះ ប៉ុន្តែ ផ្ទុយពីបច្ច័យនិយមសាមញ្ញពេក ការសិក្សានេះក៏បង្កប់នូវមនោសញ្ចេតនាដែលថាគ្មានអ្វីដែលមិនអាចជៀសផុតបាននោះទេ។

ប្រសិនបើចាំបាច់ត្រូវរំឭកពីការគំរាមកំហែងជាក់ស្តែង ដែលមានទម្ងន់ទៅលើវិវិធភាពនៃភាសា ពីតួលេខដាស់អាសន្ន ដែលជាសក្ខីភាពនិងពីហេតុផលនៃហេតុការណ៍ទាំងនេះ គេក៏ត្រូវលះបង់ចោលនូវគំនិតដែលគេច្រើនគិតទុកមុនថាមិនអាចគេចផុត ពោលគឺ គំនិតដែលថាការបាត់បង់ភាសានិងវប្បធម៌ត្រូវបានប្រវត្តិសាស្ត្រគ្រោងទុករួចស្រេចទៅហើយ នោះជាជោគ វាសនា។ ស្ថានភាពប្រវត្តិសាស្ត្រមួយមិនបង្កើតជាសំណុំលក្ខណៈសត្យានុម័ត និងមិនអាចគិតថាមានសុភវិនិច្ឆ័យបានឡើយ។ មនុស្សលោកប្រហែលជាត្រូវបញ្ចេញឆន្ទៈ និងសកម្មភាពអោយស្របនឹងលក្ខណៈនេះដោយមិនអាចចៀសបានឡើយ។ យើង គិតថាបានបង្ហាញនៅក្នុងអត្ថបទនេះនិងតាមរយៈឧទាហរណ៍ជាច្រើននូវឆន្ទៈក្នុងការអភិរក្សភាសានិងរបៀបរស់នៅរបស់ប្រជាជនដែលនិយាយភាសាទាំងនេះ។

ការវិភាគមួយដែលមានមហិច្ឆតាចង់ទាញចេញនូវលក្ខណៈគុណវុឌ្ឍិ ត្រូវតែផ្អែកជាដំបូងលើទិន្នន័យបរិមាណក្រៅពី ការប៉ាន់ស្មាន ប៉ុន្តែគួរឱ្យចម្លែក ជនជាតិដើមភាគតិចនៃកម្ពុជាបែរជាគ្មាននៅក្នុងស្ថិតិ តារាងបញ្ជី និងវិធីសាស្ត្របង្ហាញ ផ្សេងៗទៀតនៃទិន្នន័យសត្យានុម័ត។ ដូចនេះមានន័យថា ក្នុងវិស័យនេះ មានកិច្ចការស្ទើរតែទាំងអស់ដែលគេត្រូវធ្វើ។

តាមរយៈអត្ថបទដែលបានលើកឡើងខាងលើ និងតាមរបៀបដែលបានបង្កប់នៅក្នុងការវិភាគផ្សេងៗដែលបានស្នើ ឡើង មហិច្ឆតារបស់យើង ផ្តោតជាចម្បងទៅលើវិស័យបី :

- គូសបញ្ជាក់ពីការខ្វះខាតឯកសារដែលមានខាងផ្នែកបរិមាណ ។
- ផ្តល់តារាងវិភាគទីមួយពីស្ថានភាពភាសានៃជនជាតិដើមភាគតិចនៅកម្ពុជា ។
- ផ្តើមចេញពីទិន្នន័យដែលបានបង្ហាញក្នុងចំណុចខាងដើម ផ្តល់ទិសដៅនៃការស្រាវជ្រាវផ្នែកលើស្ថានភាពជាក់ស្តែងរបស់ជន ជាតិភាគតិចទាំងនេះ និងស្ថានភាពដែលស្របពេលជាមួយគ្នាបង្កើតជាកម្មវិធីសកម្មភាព : ការពិពណ៌នា ការធ្វើឱ្យរស់រានឡើងវិញ ការបង្កើតឯកសារគរុកោសល្យ ។ល ។

សំណួរមួយចោទឡើងស្តីពីការចង់ដឹងថា ទាក់ទងទៅនឹងភាសាជនជាតិភាគតិចនោះ តើអ្វីទៅជាលក្ខណៈពិសេស នៃស្ថានភាពកម្ពុជា ។

ការវិនាសបាត់បង់ភាសាជនជាតិភាគតិច កើតឡើងនៅកម្ពុជាដូចនៅតាមបណ្តាតំបន់ ដទៃទៀតក្នុងពិភពលោកដែរ : ភាសាមួយចាប់ផ្តើមទទួលរងការគំរាមកំហែងនៅពេលដែលអ្នកនិយាយភាសានោះលែងចាប់អារម្មណ៍អំពីភាសានោះហើយ ធ្វើឱ្យបាត់បង់តម្លៃដោយនិយមប្រើភាសាមួយផ្សេងទៀត ។

ដូចនៅតាមតំបន់ទាំងឡាយក្នុងពិភពលោកដែរ ប្រទេសកម្ពុជាក៏មានលក្ខណៈពិសេសរបស់ខ្លួនដែរ ។

ជាបឋមគេត្រូវគិតពីកាលៈទេសៈដែលចេញមកពីប្រវត្តិសាស្ត្រថ្មីៗនេះ ដូចជាសង្គ្រាមស៊ីវិល របបកម្ពុជាប្រជាធិបតេយ្យ ទណ្ឌកម្មសេដ្ឋកិច្ច សុទ្ធតែជាកាលៈទេសៈ

ដែលជះឥទ្ធិពលទៅលើជោគវាសនានៃភាសានិងវប្បធម៌របស់ជនជាតិភាគតិច[១៦១] ព្រមទាំងភាសាខ្មែរ[១៦២] ផងដែរ។

ផ្ទុយពីប្រទេសជិតខាង ពោលគឺ ឡាវ វៀតណាម និងថៃ គេចាំបាច់ត្រូវលើកឡើងនូវចំនុចពីរដែលជាលក្ខណៈពិសេស របស់ប្រទេសកម្ពុជា : ជនជាតិភាគតិចមានចំនួនតិចបើធៀបទៅនឹងជនជាតិភាគច្រើនដែលជាខ្មែរ ហើយប្រការនេះត្រូវបានប៉ះប៉ូវមកវិញត្រង់ថា ជនជាតិដើមភាគតិច ដូចជាអ្នកនៅតំបន់ខ្ពង់រាប រស់នៅក្នុងទឹកដីធំធេងហើយគេបានគ្រប់គ្រងទឹកដី នោះក្នុងរយៈកាលរាប់សតវត្ស។

ព្រឹត្តិការណ៍ចុងក្រោយមួយទៀត ប៉ុន្តែក៏ជាព្រឹត្តិការណ៍សំខាន់ដែរ គឺទាក់ទងទៅនឹងការអនុវត្តកម្មវិធីអនក្ខរនីយកម្ម ទ្វេភាសា ដែលដំបូងគេបង្កើតតួអក្សរដែលមានមូលដ្ឋានលើសំណេរភាសាខ្មែរ[១៦៣] ជាមុនសិន។ នេះគឺជាការណ៍មួយសំខាន់យ៉ាងខ្លាំង

---

[១៦១] ប្រវត្តិសាស្ត្រជនជាតិភាគតិចកម្ពុជាត្រូវតែចងក្រងឱ្យមានឡើងសម្រាប់សម័យកាលកម្ពុជាប្រជាធិបតេយ្យ និងបណ្ដាឆ្នាំនៃសង្គ្រាមស៊ីវិលដែលកើតឡើងមុនការឡើងកាន់អំណាចរបស់ ពួកខ្មែរក្រហម។ ប៉ុន្តែ គេអាចរកបាននូវទិន្នន័យដ៏មានប្រយោជន៍ក្នុងស្នាដៃរបស់លោក Ben Kiernan (Kiernan, 1995), Claire Escoffier(Escoffier, 1996) Frédérique Bourdier (Bourdier, 2006)

[១៦២] ការសិក្សានេះមានបំណងពិនិត្យមើលស្ថានភាពភាសាជនជាតិភាគតិច នៃកម្ពុជាគឺហេតុនេះហើយបានជាភាសាខ្មែរមិនត្រូវបានបញ្ចូលទៅក្នុងការសិក្សារបស់យើងនេះ។ ប៉ុន្តែភាសាខ្មែរ ទោះជាមានឈ្មោះជាភាសាជាតិក្ដីនៅតែស្ថិតក្នុងស្ថានភាពគួរអោយបារម្ភណ៍ : គ្មានការបោះពុម្ពផ្សាយឯកសារវិទ្យាសាស្ត្រ គុណភាពនៃការបកប្រែនៅទាប គ្មានការពិពណ៌នាភាសាវិទ្យាទំនើបដោយខ្វះពាក្យពិព័ណ៌នាឯកសារគរុកោសល្យមានចំនួនតិចតួច (សៀវភៅវេយ្យាករណ៍វចនានុក្រម) ។ល។ នៅក្នុងចក្ខុវិស័យនៃវិវិធភាពភាសា ការអភិរក្សភាសាទាំងអស់នៅកម្ពុជា ត្រូវអភិរក្សរួមទាំងភាសាខ្មែរផងដែរ។

[១៦៣] ប្រការនេះខុសពីប្រទេសជិតខាង។ គេត្រូវធ្វើឱ្យការអះអាងនេះមានភាពសមល្មម កម្មវិធីអនក្ខរនីយកម្មឈរលើមូលដ្ឋាននៃភាសាជនជាតិភាគតិចមាននៅវៀតណាម ដូចជាចំពោះ ភាសា *រ៉ាដេ* និង *ម្នង* ។ នៅប្រទេសថៃ សំណេរមួយត្រូវបានគេបង្កើត ឡើងនៅលើមូលដ្ឋានអក្សរថៃ សម្រាប់ជនជាតិ ឈង ហើយបានផ្ដល់កំណើតដល់កម្មវិធីនៃការធ្វើអោយរស់រាន

ដែលផ្អែកលើបទពិសោធន៍ពីរ ៖ ទីមួយគឺបរាជ័យនៃកម្មវិធីអក្ខរនីយកម្មដែលមិនឈរលើមូលដ្ឋានភាសាកំណើតនៃ ជនជាតិភាគតិច និងទីពីរឆន្ទៈរបស់ ជាតិពន្ធុមួយចំនួនក្នុងការអភិរក្សបេតិកភណ្ឌភាសានិងវប្បធម៌របស់ពួកគេ។

នៅក្នុងសេចក្តីសន្និដ្ឋាន នៃសៀវភៅដ៏ល្អមួយស្តីពីជនជាតិភាគតិច នៃតំបន់ខ្ពង់រាបរបស់ប្រទេសកម្ពុជា[១៦៦] អ្នកនិពន្ធ បានរំឭកពីភាពមិនច្បាស់លាស់ចំពោះជោគវាសនារបស់ជនជាតិដើមភាគតិចនៃខេត្តរតនគិរី ហើយដោយគ្មានសុទិដ្ឋិនិយម អ្នកនិពន្ធក៏បានបង្ហាញពីហេតុផលជាក់ស្តែង នៃការព្រួយបារម្ភទៅលើអនាគតរបស់ជនជាតិភាគតិច។ យើងរួមចំណែកក្នុងក្តី កង្វល់នេះដែលជាប់ពាក់ព័ន្ធទៅនឹងនយោបាយអភិវឌ្ឍន៍បណ្តាខេត្តភាគឦសាននៃប្រទេសនាពេលប៉ុន្មានឆ្នាំចុងក្រោយ ហើយនៅក្នុងនយោបាយអភិវឌ្ឍន៍នេះជនជាតិភាគតិច (ដែលតាមពិតមានច្រើនជាងគេក្នុងតំបន់នេះ) មិនបាន (ឬមិនទាន់បាន) ទទួលនូវអ្វីដែលពួកគេគួរតែទទួលបាននៅឡើយ។

ការកង្វល់នៅឆ្នាំខាងមុខ ទាក់ទងនឹងជនជាតិដើមភាគតិច ប៉ុន្តែក៏ទាក់ទងផងដែរទៅនឹងអ្នកជំនាញផ្នែកវិទ្យាសាស្ត្រ សង្គម ដែលនឹងត្រូវយកបច្ចេកទេសវិភាគរបស់ពួកគេមកបម្រើឱ្យផលប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយភាព សុខដុមរម្យនាដែលនឹងគិតគូរដល់ប្រភពវប្បធម៌ និងភាសានៃជនជាតិភាគតិច។

---

មានជីវិតឡើង វិញនៃភាសាជនជាតិនេះ។ ទោះជាយ៉ាងណា ក៏គេត្រូវបញ្ជាក់ពីចំនួនតិចនៃជនជាតិនេះ (៣ ០០០នាក់) បើធៀបទៅនឹង ជនជាតិ ជវៃទដូចជាកួយ(៣០០ ០០០នាក់) ដែលសម្រាប់ជនជាតិកួយនេះ គេមិនឃើញមានការប៉ុនប៉ងធ្វើដូចគ្នានោះទេ។ ក្នុងករណីនៃ ប្រទេសឡាវ យើងពុំមានឯកសារស្តីពីការអនុវត្តកម្មវិធីអនក្ខរនីយកម្មទ្វេភាសានោះទេ។

[១៦៦] « The uncertain future of the populations of the North-East » ¬B ourdier, 2006| >

# គន្ថនិទ្ទេស

Auroux, S. éd. 1989. *Histoire des idées linguistiques*. Mardaga

Baradat, R. 1941. « Les Samrê ou Pear, population primitive de l'Ouest du Cambodge ». *BEFEO* Paris, 41:1-150.

Bastian, Adolf. 1868. *Reise durch Kambodja nach Cochinchina*. Die Voelker des oestlichen Asien: Studien und Reisen von Dr. Adolf Bastian, Vierter Band. Jena, Herman Costenoble, reprinted 1967 by Oxford University Press, Kuala Lumpur.

Baxter, W.H. 1992. A *handbook of old Chinese phonlogy*. Mouton de Gruyter. Berlin, New York.

Bellwood, P. 1985. *Prehistory of the Indo-Malaysian Archipelago*. Orlando: Academic Press.

Bertrand, D. 1996. Les Vietnamiens au Cambodge. Center for advanced Studies.

Bitard, P. 1952. « Carte Ethno-linguistique de la région de Voeunsai ». Bulletin de la Société des Etudes Indochinoises, T. XXVII, N. 1.

Bloomfield, L. 1933. *Language*. New York.

Boodberg, P.A. 1937. "Ideography or iconolatry?" T'oung pao 35 : 266-288.

Bourotte, B. 1955. « Essais d'histoire des populations montagnardes du Sud-indochinois jusqu'en 1945 », Bulletin de la Société des Etudes Indochinoises, T. XXX, N.1.

Chao, Y.R. 1976. *Aspects of Chinese sociolinguistics*. Stanford.

Chazée, L. 1999. The peoples of Laos : Rural and ethnic diversities. Bangkok : White lotus.

Coedès, G. 1962. *Les peuples de la péninsule Indochinoise*. Dunod, Paris.

Collins, W. 1996. *The Chams in Cambodia*. Center for Advanced Studies.

Cupet, P. 1900. *Voyage au Laos et chez les sauvages du Sud-Est de l'Indochine*. Leroux, Paris.

Bourdier, F. 1995. « Les populations du keth de Rattanakiri au Cambodge. Eléments d'ethno-histoire des groupes proto-indochinois. Cahiers d'études franco-cambodgiens.

Bourdier, F. 2006. *The mountain of precious stones, Rattanakiri, Cambodia. Essays in Social Anthropology*. Center for Khmer Studies.

Cabaton, A. 1906. *Dictionnaire Cam-Français*. Paris, EFEO.

Creel, H.G. 1936. "On the nature of Chinese Ideography". T'oung Pao32: 85-161.

Crowley, J.D. 2000. "Tampuan Phonology". Mon-Khmer Studies 30: 1-23.
De Féo, A. 2005. *L'islam de l'imam San. Soufis du Cambodge*. Ms
DeFrancis, J. 1990. *The Chinese language, fact and fantasy*. University of Hawaii Press. Honolulu.
Diffloth, G. 1974. "Austro-Asiatic Languages". *Encyclopaedia Britannica*. Chicago/London/Toronto/Geneva, Encyclopaedia Britannica Inc. pp 480-484
Diffloth, G.. 1980. "The Wa Languages". Linguistics of the Tibeto-Burman Area. Vol. 5/2. Berkeley: University of California. Diffloth, Gérard. 1982. Registres, dévoisement, timbres vocaliques: leur histoire en Katouique. Mon-Khmer Studies 11:47-82.
Diffloth, Gérard. 1989. "Proto-Austroasiatic Creaky Voice". Mon-Khmer Studies 15:139-154.
Diffloth, G.. 1984. "The Dvaravati-Old Mon Language and Nyah Kur". (Monic Language Studies 1). Bangkok: Chulalongkorn University Printing House.
Diffloth, G. 1991. "Palaungic vowels in Mon-Khmer perspective". In Davison ed. *Austroasiatic Languages, essays in honour of H. L. Shorto*. SOAS, University of London.
Diffloth, G. 1994. "What happened to Austric?" Mon-Khmer Studies 16-17: 1-9.
Diffloth, G. 2005. "The contribution of linguistic paleontology to the homeland of Austro-Asiatic". In the Peopling of East Asia, Sagart, L., Blench, R. Sanchez-Mazas, A. Ed.
Ducrot, O. Schaeffer, J-M. 1995. Dictionnaire encyclopédique des sciences du langage. Paris, Seuil.
Dufossé, Dr. 1934. « Monographie des peuplades Kouys du Cambodge ». Extrême Asie 83. 553-68.
Dufumier, M. 1993. « Agriculture, écologie et développement ». Revue Tiers-monde 34 (134) 245-261.
Dy Phon, P. 2000. *Plantes utilisées au Cambodge*.
Edwards, P. 1996. Ethnic Chinese in Cambodia. Center for Advanced Studies.
Escoffier, C. 1996. Les Lao au Cambodge. Center for Advanced Studies.
Ferlus, Michel. 1979. *Lexique thavung-français. Cahiers de Linguistique, Asie Orientale* 5:71-94. Ferlus, Michel. 1982. « Spirantisation des obstruantes médiales et formation du système consonantique du vietnamien ». *Cahiers de Linguistique, Asie Orientale* 11.1:83-106.
Ferlus, Michel. 1991. « Vocalisme du Proto-Viet-Muong ». Paper circulated at the Twenty-fourth ICS-TL&L. Chiang Mai University, Oct. 10-11, 1991.

Ferlus, Michel. 1992b. « Histoire abrégée de l'évolution des consonnes initiales du vietnamien et du sino-vietnamien ». Mon-Khmer Studies 20:111-125.
Ferlus, Michel. 1996. « Langues et peuples viet-muong ». *Mon-Khmer Studies*, 26:7-28.
Ferlus, Michel. 1997. « Problèmes de la formation du système vocalique du vietnamien ». *Cahiers de Linguistique, Asie Orientale*, 26.1.
Ferlus, Michel. 1998. « Les systèmes de tons dans les langues viet-muong ». *Diachronica* 15:1.1-27.
Février, J.1959. *Histoire de l'écriture*. Payot, Paris.
Filippi, J-M.1998 a: « Phonétique et Phonologie d'un parler Phnong de Mondulkiri ». Rapport d'une mission effectuée pour l'UNICEF.
Filippi, J-M.1998 b: « Le phonétisme du Phnong de Mondulkiri, le problème des registres. » Paru dans les actes du 3ème congrès de recherches socioculturelles. Phnom Penh.
Filippi, J-M. 2000 a: « Problèmes théoriques et pratiques liés à la khmérisation de l'écriture des langues des minorités du Cambodge. » Paru dans les actes du congrès « Recherches sur la langue khmère, bilan et perspectives »
Filippi, J-M. 2000 b. *Lexique et analyse phonétique du Saoch*. Manuscrit non publié.
Filippi, J-M. 2002. « La description des dialectes du Khmer ». Actes du Congrès de l'Agence Universitaire Francophone.
Filippi, J-M et Hiep, C. V. 2006. *Introduction à la phonétique*. Phnom Penh, FUNAN. (En langue khmère).
Filippi, J-M. et Hiep, C.V. 2007. A *Khmer Pronouncing dictionary*. Phnom Penh, FUNAN
Filippi, J-M. 2007. "Norme et phonétisme dans le khmer moderne ». Udaya. Phnom Penh.
Gelb, I.J. 1963. A *study of writing*. The University of Chicago Press.
Grimes, B. 2000. *Ethnologue : languages of the world*. Dallas, Summer Institute of Linguistics.
Guyant, Ph. 1998. *Le paludisme dans la province de Mondulkiri, Cambodge*. Thèse pour obtenir le grade de docteur en médecine.
Hagège, C. 1992. *Le souffle de la langue. Voies et destins des parlers d'Europe*. Paris, Odile Jacob.
Hagège, C. 2001. *Halte à la mort des langues*. Paris, Odile Jacob.
Hayes, La V.H.H. 1992. "On the track of Austric : part 1." Mon-Khmer Studies 21: 143-177.
Haudricourt, André-Georges. 1952. « L'origine môn-khmère des tons en

vietnamien ». *Journal Asiatique* 240:264-265.
Haudricourt, André-Georges. 1953. « La place du vietnamien dans les langues austroasiatiques ». *Bulletin de la Société de Linguistique de Paris* 49.1:122-128.
Haudricourt, André-Georges. 1954. « De l'origine des tons en vietnamien ». *Journal Asiatique* 242:69-82.
Haugen. E. 1966. "Dialect, language and nation". American anthropologist 68 (4): 922-935.
Headley, R. K. Jr. 1977.*Cambodian English Dictionary*. The Catholic University of America Press, Washington D.C.
Headley, R. K. Jr. 1977. A Pearic vocabulary. *Mon-Khmer Studies* 6:69-150.
Headley, R. K. Jr. 1978a. An English-Pearic Vocabulary. *Mon-Khmer Studies* 7:61-94. Headley, R. K. Jr. 1978b. Proto-Pearic and the Classification of Pearic. In *Southeast Asian Linguistic Studies presented to André-G Haudricourt*. Ratanakul, Thomas and Premsirat eds., Bangkok, Mahidol University. pp. 355-88.
Henderson, E.J.A. 1952. "The Main Features of Cambodian Pronunciation". BSOAS, Vol. XIV: Part 1: 151-174.
Hoeffel, E. 1936. *Lexique Francais – Biat*. Ms.
Huffman, F.E. 1985. Bibliography and Index of mainland Southeast Asian languages and linguistics. Yale University Press.
Hjemslev. L. 1963. *Sproget*. Berlingske Forlag, Kobenhavn.
Keller, C.E.1976. *A Grammatical sketch of Brao, a Mon-Khmer language*. Work Papers, Vol. XX Suplement 1. Summer Institute of Linguistics, University of Nrth Dakota Session.
Keller, S. 2003. *Learn to read Krung*. Ms.
Kiernan, B.1996. *The Pol Pot regime*. Yale university Press.
Kratochvíl, P. 1968. *The Chinese language today*. London.
Labov, W. 1972. *Sociolinguistic patterns*. University of Pennsylvania Press.
Lafont, P.B. 1963. *Toloï Djuat, coutumier de la tribu Jarai*. Publications de l'Ecole Française d'Extrême Orient, Vol. LI.
Lafont, P.B. 1963. *Prières Jarai*. Collection de textes et de documents sur l'Indochine. Ecole Française d'Extrême Orient.
Le Bar, F.M., Hickey, G.C., Musgrave, J. 1964. *Ethnic groups of mainland Southeast Asia*. New Haven: Human Relations Area Files.
Lévy, P. 1943. « Recherches préhistoriques dans la région de Mlu Prei (accompagnées de comparaisons archéologiques et suivies d'un vocabulaire Français-Kuy) ». Hanoi : publications de l'Ecole Française d'Extrême Orient.

Maître, H. 1912. *Les jungles Moï*. Larose, Paris.
Markovski, L. M. 2005. *A comparative study of Kuy varieties in Cambodia*. M.A. in linguistics, Payap University, Chiang Mai, Thailand.
Martin, M. A. 1974. « Esquisse phonologique du Somree ». *Asie du sud-est et monde Insulindien*, 5.1:97-106.
Martin, M. A. 1975. « Le dialecte cambodgien parlé à Tatey, massif des Cardamomes ». ASEMI 6 (4): 71 - 79.
Martinet, A. et Haudricourt, A.G. 1946. « Propagation phonétique ou évolution phonologique ? Assourdissement et sonorisation d'occlusives dans l'Asie du sud-est ». BSLP 43. PP. 82-92.
Matras-Troubetskoy, J. 1983. *Un village en forêt. L'essartage chez les Brao du Cambodge*. Paris SELAF
Martin, M. A. 1975. « Les dialectes Pears dans leurs rapports avec les langues nationales ». *Journal of the Siam Society*, 63.2:86-95.
Miller. V.G. 1976. *An overview of Stieng grammar*. Work papers Vol. XX, Supplement 3. Summer Institute of Linguistics, University of North Dakota Session.
Moura, J. 1883. *Le Royaume du Cambodge*. Leroux, Paris.
Norlander, J. 2003. Highland children education project, Rattanakiri province, Cambodia. Care International in Cambodia.
Palmer, H.E. 1931. *Principles of Romanization*. Tokyo.
Pelliot, P. 1903. Le "Fou-Nan". Bulletin de l'Ecole Française d'extrême Orient, T. III N. 2, avril-juin 1903.
Pelliot, P. 1951. *Mémoires sur les coutumes du Cambodge de Tcheou ta-kouan*. J. Maisonneuve, Paris.
Pen Dareth. 1996. Interdisciplinary research on ethnic groups in Cambodia. Final draft report. Center for Advanced Studies.
Reid, L. 1994. "The Nicobarese evidence for Austric". Oceanic Linguistics. 33(2):323-344.
Rosén, H. B. 1977. *Contemporary Hebrew*. Mouton. The Hague. Paris.
Saussure, F. de. 2002. *Ecrits de linguistique générale*. Gallimard, Paris.
Schmidt, Wilhelm. 1901. « Die Sprachen der Sakai und Semang auf Malacca und ihr Verhältnis zu den Mon-Khmer-Sprachen ». Bijdragen tot de Taal-, Land-, en Volkenkunde van Nederlandsch-Indie, 52:399-583.
Schmidt, Wilhelm. 1904. "Grundzüge einer Lautlehreder Khasi-Sprache in ihren Beziehungen zu derjenigen der Mon-Khmer-Sprachen. Mit einem Anhang: die Palaung-Wa-, und Riang-Sprachen des mittleren Salwin". Abh. Bayrischen Akademie der Wissenschaft, 1.22.3:677-810.
Schmidt, Wilhelm. 1905. *Grundzüge einer Lautlehre der Mon-Khmer-Sprachen*.

Denkschreibung Akademie der Wissenschaft, Wien, Philosophisch-historische Klass, 51:1-233.
Schmidt, Wilhelm. 1906. "Die Mon-Khmer-Völker, ein Bindeglied zwischen Všlkern Zentralasiens und Austronesiens". *Arch. Anthrop.*, Braunschweig, 5:59-109.
Sokolovskaja, N.K. 1978. "Materialy k sravnitel'no-ètimologicheskomu slovar'u vietmyongskix jazykov ». Issledovanija po fonologii i grammatike vostochnyx jazykov, Moskva, Nauka, pp126-80.
Sokolovskaja, N.K., and Nguyên Van Tài, 1987. *Jazyk Myong*: Materialy sovetsko-vietnamskoi lingvisticheskoi ekspeditsii 1979 goda. Moskva, Nauka.
Thomas. D. 1964. "A survey of Austro-Asiatic and Mon-Khmer comparative linguistics. Mon-Khmer Studies I.
Thompson, Laurence C. 1976. "Proto-Viet-Muong Phonology". In Jenner et al. (eds.) *Austroasiatic Studies*. (1976b), pp 1113-1204.
Thompson, Laurence C. 1987. *A Vietnamese Reference Grammar. Mon-Khmer Studies* 13-14.
Thongkum, L. T. 1988. "Phonation types in Mon-Khmer languages". Vocal Physiology: Voice production, Mechanisms and Functions, Osamu Fujimura (ed.)
Thongkum, T. L. 1991. "An instrumental study of Chong registers". In *Austroasiatic languages: essays in Honour of H.L. Shorto*, edited by J.H.C.S. Davidson, pp.141-160. London: SOAS.
Thurgood, G. 1999. *From ancient Cham to modern dialects. Two thousand years of language contact and change*. University of Hawaii Press, Honolulu.
Troubetskoy, N. S. 1976. Principes de phonologie. Klincksieck, Paris.
Trudgill, P. 1974. "Language change and diffusion: description and explanation in sociolinguistics dialect geography". Language and Society 3: 215-46.
Ueda, H. Okada, T. 2003. "Saoc vocabulary". Reports on minority languages in mainland Southeast Asia.
Vandermeersch, L. 1994. *Etudes sinologiques*. PUF, Paris.
Vogel, S. 2006. *Introduction à la langue et aux dits traditionnels des Phnong de Mondulkiri*. FUNAN, Phnom Penh.
Vogel, S. et Filipi, J-M. 2007. *Eléments de langue Phnong*. Phnom Penh.
Wang, W.S-Y. Ed. 1991. Languages and dialects of China. Journal of Chinese linguistics, Monograph series Number 3.
Willmott, W.E. 1967. *The Chinese in Cambodia*. Publication center, University of British Columbia.
Wilmott, W.E. 1970. The political structure of the Chinese community in Cambodia. University of London. The Athlone Press.

White. J. 1996. The Highland people of Cambodia. Center for Advanced Studies.
Wurm, S.A. et Hattori, Sh. 1981. *Language atlas of the Pacific area*. Pacific linguistics, series C, N. 66, Canberra.

# មាតិកា

**អារម្ភកថា** ....................................... ៧

**សេចក្តីផ្តើម** ....................................... ១១

**ផ្នែកទីមួយ : វិធីសាស្ត្រនិងដំណើរការនៃការអង្កេត**

១.១.គោលបំណងនៃការអង្កេត ....................... ១៩

១.២.វិធីសាស្ត្រនិងការធ្វើអង្កេត ....................... ២០

១.២.១.ការពិនិត្យពិច័យពីប្រភពសំណេរ ....................... ២១

១.២.១.១.អាណាព្យាបាលបារាំង (១៩៦៣-១៩៥៣) ............... ២២

១.២.១.២.សម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០)

និងសង្គ្រាមឥណ្ឌូចិនលើកទីពីរ (១៩៥៧-១៩៧០) .......... ២៤

១.២.១.៣ សម័យទំនើប ....................... ២៥

១.២.១.៣.១.ការងារស្តីពីវិទ្យាសាស្ត្រជាតិពន្ធុ ....................... ២៦

១.២.១.៣.២.ការមានមនសិការចំពោះការបាត់បង់ភាសា/វប្បធម៌មួយ .... ២៦

១.២.១.៣.៣.ការធ្វើសកម្មភាពនៅក្នុងវិស័យមនុស្សធម៌ ............ ២៧

១.២.២.ទេសកិច្ច ....................... ២៩

១.២.២.១.ការកំណត់ទីតាំងអង្កេត ....................... ២៩

១.២.២.២.កម្រងសំណួរនិងវិធីអង្កេតផ្សេងទៀត ....................... ៣០

១.២.២.៣.ការជ្រើសយកអ្នកផ្តល់ព័ត៌មាន ....................... ៣៥

១.២.២.៤.ការជ្រើសរើសទិន្នន័យ ....................... ៣៦

១.២.៣.ការស្រាវជ្រាវលើដៃគូដែលមានសកម្មភាព

នៅក្នុងសហគមន៍ជនជាតិភាគតិចនៅកម្ពុជា ..............៣៧


**ផ្នែកទីពីរ : លទ្ធផល**

**២.១.ចំណាត់ប្រភេទភាសា** ........................៤២

២.១.១.គោលការណ៍នៃចំណាត់ប្រភេទភាសា

និងការអនុវត្តទៅលើភាសានិយាយនៅកម្ពុជា ..............៤២

១.២.២.គ្រួសារអូស្ត្រូ-អាស៊ី ........................៤៤

១.២.២.១.ចំណាប់អារម្មណ៍ប្រវត្តិសាស្ត្រ ................៤៤

២.១.២.២.ផែនទីដែលមានវត្តមានភាសាអូស្ត្រូអាស៊ី ..........៤៥

២.១.៣.អំបូរអូស្ត្រូណេស៊ី ........................៥០

២.១.២.ភាសាចិន ...............................៥៣

២.១.៤.១.សភាពបញ្ហា ...........................៥៣

២.១.៤.២.ចំណាត់ប្រភេទនៃក្រុមភាសាចិន ................៥៥

២.១.៤.៣. ក្រុមភាសាចិននៅកម្ពុជា .....................៥៧

២.១.៥.ភាសាតៃកាដាយ ..........................៥៨

២.១.៦.បញ្ហាទាក់ទងទៅនឹងចំណាត់ប្រភេទភាសា :

ចំណេះដឹងវិទ្យាសាស្ត្រនិងចំណាត់ប្រភេទក្នុងស្រុក .............៥៩

២.១.៦.១.វិធីសាស្ត្រប្រៀបធៀបហើយដំបូងបំផុតគឺវប្បធម៌ ...........៦០

២.១.៦.២.ចំណោទស្តីពីជាតិពន្ធុនាម ....................៦១

១.១.៦.៣.ករណើចំនួនបីស្ដីពីសាលារៀន ........................ .៦២
១.១.៦.៣.១.ភាសាស្ងួច ............................ .៦២
២.១.៦.៣.២.ជុំវិញពាក្យថ្លា ............................ .៦៣
២.១.៦.៣.៣.ពាក្យថា ព្នង ............................ .៦៥
២.១.៦.៤.ការជាប់ទាក់ទងជាតិពន្ធុភាសាវិទ្យានិងសង្គម ................ .៦៦
២.១.៦.៤.១.បាតុភូតកន្ទ្រាញ ............................ .៦៦
២.១.៦.៤.២.គ្រាមភាសាវិទ្យានិងជាតិពន្ធុនាម .................... .៦៧
**២.២.ភូមិសាស្ត្រភាសាវិទ្យា** ............................ .៦៩
២.២.១.ប្រជាជន : បញ្ហានៃការប្រមូលសម្ភារៈនិងលទ្ធផលបឋម .......... .៦៩
២.២.២.ទីតាំងជនជាតិភាគតិចនៅកម្ពុជា ........................ .៧៣
**២.៣.សង្គមភាសាវិទ្យា** ............................ .៧៥
២.៣.១.បញ្ហានៃទ្វេភាសានិយម ............................ .៧៥
២.៣.១.១.ទិន្នន័យនៃបញ្ហា ............................ .៧៥
២.៣.១.២.ឯកភាសានិយមនិងទ្វេភាសានិយមក្នុងជនជាតិភាគតិចនៅកម្ពុជា . .៧៨
២.៣.១.២.១.ឯកភាសានិយមក្នុងភាសានៃជនជាតិភាគតិច ............ .៧៨
២.៣.១.២.២.ទ្វេភាសាក្នុងប្រយោជន៍នៃភាសាជនជាតិភាគតិច ........... .៨០
២.៣.១.២.៣. ទ្វេភាសានិយមពិតប្រាកដ ........................ .៨២
២.៣.១.២.៤.ទ្វេភាសានិយមធ្វើអោយភាសាជនជាតិភាគតិចចុះខ្សោយ ..... .៨៦
២.៣.១.២.៥.ឯកភាសានិយមខ្មែរ ........................ .៨៨

២.៣.២.សំណេរនៃភាសាជនជាតិភាគតិច ........................៩០
២.៣.២.១.សំណេរបុរាណ ..............................៩០
២.៣.២.១.១.សំណេរចិន ..............................៩០
២.៣.២.១.២.សំណេរប្រើសម្រាប់ភាសាចាម ......................៩២
២.៣.២.២.ទស្សនាទានសំណេរសម្រាប់ភាសាជនជាតិភាគតិច ............៩៥
២.៣.២.២.១.សំណេរឡាតាំង ..............................៩៥
២.៣.២.២.២.ការបង្កើតតួអក្សរលើមូលដ្ឋាននៃអក្សរខ្មែរ ..............៩៦
២.៣.២.២.២.១.កាលប្បវត្តិ ..............................៩៦
២.៣.២.២.៣.ទស្សនាទាននៃប្រព័ន្ធសំណេរផ្សេងៗលើមូលដ្ឋានអក្សរខ្មែរ ....៩៧
២.៣.២.២.៣.១.ការលំបាកទាក់ទងនឹងការប្រើអក្សរខ្មែរ ..............៩៧
២.៣.២.២.៣.២.សំណេរនិងបញ្ហាបម្រែបម្រួលភាពនៃគ្រាមភាសា .......១០០
**២.៤.បរិស្ថានភាសា** ..............................១០៤
២.៤.១.ភាសាក្នុងសភាពរងគ្រោះនៅកម្ពុជា ......................១០៥
២.៤.១.១.លក្ខខណ្ឌកំណត់ ..............................១០៥
២.៤.១.២.ស្ថានភាពភាសានៅកម្ពុជា ..........................១០៦
២.៤.១.២.១. សញ្ញាណភាសាងាប់ ..........................១០៦
២.៤.១.២.២.ភាសាក្នុងសភាពរងគ្រោះ
ជិតឈានទៅរកការបាត់បង់ទាំងស្រុង ................១០៧
២.៤.១.២.៣.ភាសាក្នុងសភាពរងគ្រោះ ..........................១១១

២.៤.១.២.៤.ភាសាក្នុងអន្តរកាល ..........................១១៣
២.៤.១.២.៤.១.កសិកម្ម ..............................១១៤
២.៤.១.២.៤.២.ការអប់រំ ..............................១១៥
២.៤.១.២.៤.៣.ការលើកតម្លៃចំណេះដឹងបុរាណ ..................១១៦
ផ្នែកទីបី : ផែនទីសាស្ត្រ
ភាសាវិទ្យាស្ត្រអាស៊ី
- ប្រាវ ......................................១២៤
- ទំពួន ......................................១២៦
- កាចោ ......................................១២៨
- ព្នង ......................................១៣០
- ស្មៀង ......................................១៣២
- កួយ ......................................១៣៤
- សំរ៉ែ ......................................១៣៦
- សំរ៉ៃ ......................................១៣៨
- ស្អូច ......................................១៤០
- ព័រ ......................................១៤២
- សួយ ......................................១៤៤
ភាសាវិទ្យាស្ត្រណេាស៊ី
- ចារាយ ......................................១៤៨

- ចាម ....................................................១៥០

**ភាសាតៃកាដាយ**

- ឡាវ ....................................................១៥៤

**ភាសាចិន**

- ចិនខិ ....................................................១៥៨
- ហៃណាំ ....................................................១៦០

**សេចក្តីសន្និដ្ឋាន** ....................................................១៦៣

**គន្ថនិទ្ទេស** ....................................................១៦៩

**មាតិកា** ....................................................១៧៧

FUNAN

2009

© Editions Funan

# $27E_1$, St 172, Sangkat Chhey Chum Neash,
Khan Daun Penh, Phnom Penh (Cambodia)
E-mail: funan7@yahoo.fr

ISBN: 978-99950-57-35-0

MDG F

Culture and Development – Cambodia
Creative Industries Support Programme

ISBN:978-99950-57-35-0

9 789995 057350